# ពាក្យពេចន៍មិត្ត



# ១-ការពិតក្នុងចិត្ត

*កូនជាទីស្រឡាញ់*

*ឥឡូវនេះ កូនធំហើយ ល្មមអាចយល់ដឹងនូវរឿងរ៉ាវរបស់ជីវិបាន បើមិនច្រើនក៏ខ្លះៗដែរ ។ កូនគង់តែបានដឹងហើយថា ឪពុកម្ដាយស្រឡាញ់កូនច្រើនប៉ុនណា កូនប្រៀបបីដូចជាកែវភ្នែក ឬថ្លើមប្រមាត់របស់ម៉ែឪដូច្នោះឯង ។*

*ឪពុកម្ដាយនឿយហត់ក្នុងការងាររាល់ថ្ងៃនេះ កូនក៏ដឹងដែរ ថាគឺដើម្បីកូនគ្រប់គ្នា បើសម្រាប់តែមាត់ពីរ ក្រពះពីររបស់ឪពុកម្ដាយទេនោះ ឪពុកម្ដាយមិននឿយហត់ដូច្នេះទេ ។ ដែលពោលយ៉ាងនេះ មិនមែនចង់រំលឹកគុណ ហើយប្រាថ្នានូវការតបស្នងអ្វីក្រៅអំពីចង់ឲ្យកូនជាមនុស្សល្អនោះឡើយ ។*

*តាមពិត ម៉ែឪត្រូវការអ្វីៗច្រើនយ៉ាងពីកូនមែន គ្រាន់តែនិយាយមិនចេញ ហាក់ដូចជាទឹកលិចដល់មាត់អ៊ីចឹងឯង ។ ចូរកូនដឹងចុះ សូម្បីមាតាបិតាទាំងឡាយមានទ្រព្យសម្បត្តិច្រើនលើសពីការប្រើប្រាស់ទៅទៀតក៏ដោយ តែក៏នៅប្រាថ្នាចង់បានជំនូនចង់បានរបស់ដែលកូនឲ្យដែរ ទោះបីរបស់នោះមិនសូវល្អ មិនសូវថ្លៃ ប្រៀបនឹងរបស់ដែលឪពុកម្ដាយមានមិនបានក៏ដោយ ឲ្យតែជាជារបស់ដែលកូនជូនហើយ ឪពុកម្ដាយសប្បាយចិត្ត ។ កាលដែលកូនមាននំ មានផ្លែឈើយកមកជូននោះ ឪពុកម្ដាយឆ្អែតស្រេច*



*ហើយក៏ដោយ ក៏នៅតែទទួលពិសាដោយពេញចិត្តពិតៗ ។ សម្លៀកបំពាក់ដែលកូននាំមកជូន ទោះជាមិនស្អាតក៏ដោយ ក៏មាតាបិតាស្លៀកពាក់ដែរ ដើម្បីបង្ហាញកូន យកចិត្តកូន ។ ទោះជាកូនមិនមានអ្វីមកជូនសោះ ដោយគ្រាន់តែកូនបង្ហាញមុខ ហើយមានដៃទាំងពីរសំពះថ្វាយបង្គំប៉ុណ្ណឹង ម៉ែឪក៏ពេញចិត្តណាស់ទៅហើយ ។*

*នេះជាបំណងប្រាថ្នា ដែលមានក្នុងចិត្តរបស់ឪពុកម្ដាយគ្រប់គ្នា ពោលគឺចង់ឲ្យកូនជាមនុស្សល្អ គិតល្អ ធ្វើល្អ និយាយល្អ ដឹងគុណ ដឹងទោសទៅតាមសេចក្ដីពិត ប៉ុន្តែឲ្យម៉ែឪហាមាត់ប្រាប់កូនថា ថ្វាយបង្គំមក ទិញផ្លែ ឈើល្អៗមក...យ៉ាងម៉េចរួចទៅ ម្ល៉ោះហើយមាតាបិតា ខ្លះបានបិទភ្នែកលាចាកលោកនេះទៅទាំងដែលមិនធ្លាប់បានឃើញកូនក្រាបសំពះខ្លួនម្ដងផង ។*

*ពាក្យពេចន៍ម៉ែឪត្រូវកូនចាំ　　បណ្ដាំទឹកចិត្តពិតពាក្យព្រហ្ម*
*ពាក្យប្រាជ្ញពីព្រេងម៉ែឪផ្ដាំ　　និយមព្រះពុទ្ធវិសុទ្ធពេចន៍ ។*
*អរុណពណ៌មាសជះរស្មី　　សម្ដីម៉ែឪត្រូវរំលេច*
*រំលឹកចាំៗកុំឲ្យភ្លេច　　ពាក្យពេចន៍ដូចថ្លៃថ្លៃដូចមាស។*
*ទ្វីបលោកល្អស្រស់ព្រោះសុរិយា　　មាតាបិតាគឺជាព្រះ*
*ជាដួងសុរិយាយាត្រារះ　　កូនត្រូវសំពះទិសបូព៌ា ។*
*ទិសបូព៌ាមានន័យបុព្វការី　　បង្កើតប្រុសស្រីពេញពសុធា*
*ពាក្យពេចន៍ម៉ែឪត្រូវដូចជា　　សុរិយាក្នុងគ្រាបំភ្លឺលោក ។*

## ២-គ្រួសារកក់ក្ដៅ

កូនជាទីស្រឡាញ់

ពាក្យថា គ្រួសារជាពាក្យដែលមានសេចក្ដីឬអត្ថន័យ ច្រើន គឺសំដៅដល់ការស្រឡាញ់ ភាពកក់ក្ដៅ ភាពនៃត្រកូលតែមួយ ជាមួយគ្នា ។ល។ នៅប្រទេសខាងលិច ភរិយាតែងយកត្រកូលប្ដីមកប្រើ ហើយតែងហៅគ្នាថា (អ្នកផ្ទះខ្ញុំ) ឬគ្រួសារខ្ញុំជាដើម ។

សម័យដែលកូននៅក្មេងៗ យើងនៅរួមគ្នាជាគ្រួសារ មានសំឡេងសើចសប្បាយ មានសំឡេងរត់ប្រឡែងគ្នា បរិភោគអាហាររួមគ្នា និងធ្វើអ្វីៗជាមួយគ្នា មានភាពរស់រវើក ។ ឪពុកម្ដាយសូម្បីធ្វើការហត់នឿយអស់កម្លាំង យ៉ាងណាក៏ដោយ លុះមកដល់ផ្ទះហើយគ្រាន់តែឃើញមុខកូនៗរត់មកទទួលជួយកាន់ ជួយទទួលយករបស់របរ និងសាកសួរពីការហត់ នឿយប៉ុណ្ណឹង ម៉ែឪក៏បាត់អស់នូវការហត់នឿយទៅហើយ ។ មាតាបិតាឃើញកូនញ៉ាំបានគេងលក់ក៏សប្បាយចិត្ត ទាំងអស់នេះឯងណា៎កូន ដែលគេថាគ្រួសារមានភាពកក់ក្ដៅនោះ ។

ឥឡូវនេះកូនក៏បានធំៗអស់ហើយ កូនអើយធ្វើជាបងជាប្អូនគ្នា កូនត្រូវតែចេះស្រឡាញ់គ្នា ។ សាច់ឈាម ជាមួយគ្នាយ៉ាងណាៗក៏កាត់មិនបាន ពាក្យចាស់ពោលថា “កាត់ទឹកមិនដាច់ កាត់សាច់មិនបាន” ដូច្នេះចូរកូនកុំស្អប់ខ្ពើម កុំកំណាញ់ កុំប្រណែន



ឬខឹងក្រោធគំនុំគុំកួនអ្វីដល់គ្នាឡើយ កូនត្រូវជួយគ្នា និងមើលថែគ្នាវិញទើបបានល្អ ។

បានមកធ្វើជាបងប្អូននឹងគ្នាហើយ ស្រាប់តែមកឈ្លោះទាស់ទែងគ្នា វាជារឿងដែលគួរឲ្យខ្មាសអៀនណាស់ កូនអើយ មនុស្សល្អគេមិនឈ្លោះទាស់ទែងគ្នាដូច្នេះឡើយ ម្យ៉ាងទៀតកូនត្រូវគិតដល់ទ្រូងម្ដាយទ្រូងឪពុកផងណា៎កូនណា៎។ គិតដល់ពេលដែលកូននៅតូចៗ ឈ្លោះគ្នាហើយក៏ល្អនឹងគ្នាវិញ លេងចូលគ្នាវិញដូចដើម ភ្លេចរឿងដែលកន្លងទៅអស់ ហើយស្រឡាញ់គ្នាព្រមព្រៀងគ្នា មានអ្វីធ្វើក៏ជួយធ្វើគ្នា ។ ល្អណាស់កូន មានរឿងខ្លះៗកាលកូននៅពីតូចនោះ កូនគួរសិក្សាតាម បើកូនគិតថាកូនធំហើយ កូនមិនភ្លេចរឿងដែលទាស់ចិត្តដូចកាលកូននៅពីក្មេងទេ តែកូនត្រូវកុំប្រកាន់គ្នា ។ កូនអើយ ស្វាមីអាចរកថ្មីបាន ភរិយាអាចរកថ្មីបាន កូនក៏អាចរកថ្មីបានដែរ តែបងឬប្អូនរកមិនបានទៀតឡើយ មានប៉ុនណាក៏ប៉ុណ្ណឹង កាលកាត់បងកាត់ប្អូនក៏ដូចគ្នានឹង ការកាត់សាច់ កាត់ឈាមរបស់ម៉ែរបស់ឪដែរណា៎កូន ។

គ្រួសារកក់ក្ដៅម៉ែឪកូនចៅ ត្រូវនៅក្នុងធម៌
មិនតាមកិលេស ចេះរស់ក្នុងពរ អាយុបវរ
គុណធម៌ក្នុងចិត្ត ។

## ៣-ឈឺចាប់ក្នុងចិត្ត

*កូនជាទីស្រឡាញ់*

*ពេលខ្លះឪពុកម្តាយបានធ្វើអ្វី ឬនិយាយអ្វីជាមួយ កូនខ្លាំងហួស អាចធ្វើឲ្យកូនមិនពេញចិត្ត ប៉ុន្តែចូរកូនយល់ថាទោះជាយ៉ាងណាក៏ដោយឪពុកម្តាយគិតគូរដល់កូនណាស់ ស្រឡាញ់ណាស់ គឺកូននៅតែជាកែវភ្នែក ជាបេះដូងរបស់ម៉ែឪ ជានិច្ច ។*

*នៅពេលដែលកូនសម្លឹងមើលឪពុកម្តាយ ដោយក្រសែភ្នែកខឹងស្អប់ ឬមិនចូលចិត្ត ហាក់ដូចឪពុកម្តាយជា អ្នកដទៃទៀតនោះ ឪពុកម្តាយតូចចិត្ត ហើយឈឺចាប់ណាស់ ។ អ្នកដទៃគេមាក់ងាយ ឬយល់ខុសមកលើឪពុកម្តាយ ក៏ឪពុកម្តាយមិនមែនញាប់ញ័រក្នុងចិត្ត ដូចជាកូនរបស់ខ្លួនមកមាក់ងាយ ឬយល់ខុសលើឪពុកម្តាយឡើយ ។ បើកូនខឹងក្រោធចំពោះម៉ែឪ ព្រោះកូនមិនពេញចិត្ត ឬទាស់ចិត្តក្នុងរឿងអ្វីដែល ម៉ែឪបានធ្វើទៅហើយនោះម៉ែឪល្មមអាចទ្រាំបាន ប៉ុន្តែបើខឹងក្រោធព្រោះកូនមិនយល់ដល់ទឹកចិត្តដ៏ពិតប្រាកដរបស់ម៉ែឪវិញនោះ ឪពុកនិងម្តាយត្រូវខូចចិត្តនិងឈឺចាប់ក្នុងដើមទ្រូងយ៉ាងក្រៃលែងណា៎កូន ។*

*សន្តានហឫទ័យនៃព្រះអរហន្ត មកលើពួកជនហ្មត់ចត់យ៉ាងណា*
*ទឹកចិត្តម៉ែឪលើបុត្រធីតា ហ្មត់ចត់អស្ចារ្យក៏យ៉ាងនោះដែរ។*
*ចូរកូនទាំងឡាយកុំវាយតម្លៃ ទឹកចិត្តប្រពៃនៃពុកនិងម៉ែ*



*ឲ្យស្មើនឹងទ្រព្យឬស្មើប្រាក់ខែ ព្រោះថាឪម៉ែជាព្រះអរហន្ត។*
*នៅក្នុងលោកនេះពុំមាននរណា ចិត្តគិតប្រាថ្នាមេត្តាពេកពន់*
*លើកូនប្រុសស្រីមានន័យគុណធ្ងន់ ឲ្យដូចអរហន្តមាតាបិតា ។*
*បើកូនស្វែងរកអង្គព្រះអរហន្ត ដើម្បីបន្ទន់ឱនក្រាបសិរសា*
*កូនត្រូវនឹកដល់មាតាបិតា ព្រះអរហន្តាឋិតនៅក្នុងផ្ទះ ។*
*មាតាបិតាចិន្តាបរិសុទ្ធ ស្នេហ៍ស្មោះលើបុត្រសុទ្ធចិត្តត្រង់លះ*
*កម្លាំងកាយចិត្តជីវិតប្រាក់មាស ចិត្តល្អដូចព្រះវេស្សន្តរក្សត្រា។*

## ៤-កំពូលប្រាថ្នារបស់ម៉ែឪ

កូនជាទីស្រឡាញ់

កូនៅមិនទាន់ដឹងដល់សេចក្តីប្រាថ្នាថ្នាក់កំពូល របស់ម៉ែឪ គឺម៉ែឪគ្រប់គ្នាវេលាដែលមានជំងឺ រមែងត្រូវការឃើញមុខកូនរបស់ខ្លួនមកប្រណិប័តន៍ មកមើលថៃ នៅជិតនៅក្បែរសាកសួររឿយៗ នោះឯងណា⁺កូន គឺជាថ្នាំវិសេស ដែលធ្វើឲ្យឪពុកម្តាយធាប់ជាសះស្បើយ ។ ក្រៅលែងណាស់ទៅទៀត គឺនៅពេលដែលខ្លួនចាស់ជរា ជួយអ្វីខ្លួនឯងមិនបាន រមែងត្រូវការកូនជាទ្វេគុណជាត្រីគុណ ។ សូម្បីដឹងថាកូនរបស់ខ្លួនមានធុរៈមមាញឹក មានការងារដែលត្រូវធ្វើច្រើនសន្ធឹកសន្ធាប់ មិនសូវមានពេលទៅមកយ៉ាងណាក៏ដោយ ក៏ម៉ែឪនៅតែអត់ទ្រាំមិនបានដែរ គឺនៅតែប្រាថ្នាឃើញកូន ហើយប្រាថ្នាឲ្យកូនមកមើលថៃជានិច្ច ។

ឪពុកម្តាយគ្រប់គ្នា ក្រៅអំពីប្រាថ្នាឲ្យកូនយកចិត្តទុកដាក់មើលថៃខ្លួនហើយ នៅមានសេចក្តីប្រាថ្នាជាទីបំផុត ម្យ៉ាងទៀត គឺចង់ឃើញកូនមានសេចក្តីចម្រើននិងមានសេចក្តីសម្រេចក្នុងជីវិត មានជីវិតរុងរឿងសម្បូណ៌ទៅដោយសេចក្តីសុខ។ បើកូនបានសមតាមសេចក្តីប្រាថ្នា ឪពុកម្តាយគ្រប់គ្នានឹងមិនប្រណៃនជាមួយកូនឡើយ ញាប់ញ័រក្នុងចិត្តតែម្យ៉ាងត្រង់ដែលមិនបានឃើញកូនដល់នូវ សេចក្តីសម្រេចក្នុងជីវិត របស់កូននោះ ។ ដែលឪពុក



ម្តាយព្រមលំបាកក្នុងការចិញ្ចឹមកូនរហូតមក ក៏ដើម្បីជ្រោមជ្រែងកូនឲ្យបានសម្រេចសមតាមបំណងប្រាថ្នានោះឯង បើបានឃើញកូនជាមនុស្សល្អ មានសមត្ថភាពគ្រប់គ្រាន់ មានការចេះដឹងជាមនុស្សឆ្លាត មានការងារធ្វើជាជំហរ នៃជីវិតនឹងបានជួបប្រសព្វនូវសេចក្តីសម្រេច ឪពុកម្តាយគ្រប់គ្នាក៏ភ្លេចអស់នូវការនឿយហត់ទៅហើយដែរ ។

ចូរកូនគ្រប់គ្នា កុំធ្វើឲ្យម៉ែឪខកចិត្តខុសសង្ឃឹមឡើយ ។

## ៥-កូនត្រូវជាមនុស្សស្មោះត្រង់

កូនជាទីស្រឡាញ់

ការស្មោះត្រង់ ប្រៀបបីដូចជាទឹកសម្រាប់ស្រោចដំណាំមិនឲ្យស្វិត យ៉ាងណា ជីវិតពិតជាស្រស់បំព្រង ព្រោះភាពស្មោះត្រង់របស់ខ្លួនយ៉ាងនោះឯង ។

មនុស្សយើងនៅជាមួយអ្នកណា ធ្វើការងារជាមួយអ្នកណា ក៏គួរតែស្មោះត្រង់ជាមួយអ្នកនោះ ថែមទាំងស្មោះចំពោះការងារ និងស្មោះចំពោះពាក្យនិយាយរបស់ខ្លួនឯងទៀតផង ។

ការស្មោះត្រង់នោះ ក៏គឺជាការពិតប្រាកដក្នុងចិត្ត មាត់ពោលស្តីអ្វីៗជាសម្តីផ្កា អ្នកណាៗក៏ចូលចិត្ត ជាពាក្យពិតត្រង់ជាមួយចិត្ត ត្រង់ជាមួយការងារ ។

កូនប្រុសស្រី ត្រូវតែតម្កល់ខ្លួនឲ្យមាំនៅក្នុងសេចក្តីស្មោះត្រង់ គឺត្រង់ទៅត្រង់មក ធ្វើអ្វីៗក៏ចាប់យកការស្មោះត្រង់ជាទីតាំង សូម្បីបានផលប្រយោជន៍ជាទ្រព្យសម្បត្តិតិចតួចក៏ដោយ ក៏កូនកុំបោះបង់ចោលនូវសេចក្តីល្អបែបនេះឲ្យសោះ ។ អ្នកណាគេយល់ថា ការវៀចវេរ ឬការយកប្រៀបលើអ្នកដទៃ ទើបជាសេចក្តីឆ្លាត ក៏ស្រេចតែអ្នក នោះទៅចុះ បើគេថាកូនជាមនុស្សល្ងង់ ឬភ្លើ កូននៅតែជាកូនឆ្លាតរបស់ពុកម៉ែដដែល ព្រោះមនុស្សឆ្លាតទើបចេះជួយខ្លួនឯងឲ្យផុតពីបាបកម្ម ។ បើកូនមិនស្មោះត្រង់



ហើយទៅ ធ្វើខុសក្នុងរឿងអ្វីមួយនោះ ត្រូវគេចាប់បានអ្នកដែលថាយើង ស្មោះត្រង់គឺល្ងង់ ឬអ្នកដែលញុះញង់ឲ្យកូនទៅធ្វើខុសនោះ គេមិនបានមកជួយកូនឡើយ កូនត្រូវទទួលទោសតែម្នាក់ឯង តែបើកូននៅតែធ្វើការដោយស្មោះត្រង់ល្អពិតៗ មុនដំបូងកូនអាចលំបាកកាយ តែសប្បាយចិត្ត រួចហើយក្នុងកាលជាខាងក្រោយ គឺកូនមិនត្រូវបានទទួលនូវទុក្ខទោសអ្វីរហូតតទៅ ។

✍📖✍

## ៦-គុណនៃសេចក្តីលំបាក

កូនជាទីស្រឡាញ់

ឪពុកម្តាយ ក៏ដូចគ្នានឹងមនុស្សទាំងឡាយឯទៀតដែរ គឺក្រៅអំពីមិនត្រូវការឲ្យខ្លួនឯងលំបាកហើយ នៅមិនត្រូវការឲ្យកូនរបស់ខ្លួនមាននូវសេចក្តីលំបាកផងទៀត ។ មិនមានម៉ែឪណាដែលប្រាថ្នាឲ្យកូនខ្លួនឯងក្រីក្រលំបាក តោកយ៉ាកឡើយ ប៉ុន្តែពេលខ្លះកូននៅតែមានសេចក្តីលំបាក ព្រោះឪពុកម្តាយមិនអាចធ្វើឲ្យកូនសុខសប្បាយបានគ្រប់យ៉ាងនោះឯង ។

ក្នុងសេចក្តីនេះ កូនត្រូវចាំទុកថា សេចក្តីលំបាកនោះ វាមិនមែនអាក្រក់ មានពិសកាចសាហាវធ្វើឲ្យមនុស្ស យើងទុក្ខ

លំបាកទៅតែម្យ៉ាងនោះទេ ។ បើយើងសម្លឹងមើល ក្នុងការសិក្សា ឬមើលក្នុងផ្នែកមួយផ្សេងទៀត សេចក្តីល្អ ឬប្រយោជន៏នៃការលំបាកនោះៗក៏អាចប្រព្រឹត្តទៅបាន គឺសេចក្តីលំបាកធ្វើឲ្យមនុស្សយើងរឹងប៉ឹងមាំមួនខ្លាំងឡើង ធ្វើឲ្យមនុស្សយើងពូកែគិត និងធ្វើឲ្យបានជាអ្នកធំទៀតផង ប្រៀបដូចដែកដែលគេដុតឲ្យរឹងដូច្នោះឯង ។

ការលំបាកប្រដៅឲ្យមនុស្សយើងពូកែក្នុងការជួយ ខ្លួនឯង ព្រោះត្រូវតស៊ូក្រាញននៀល ដើម្បីយកឈ្នះសេចក្តីលំបាកនោះៗ ។ មានមនុស្សមិនតិចនាក់ដែរទេ ដែលគេបានល្អមក អំពីសេចក្តីលំបាក ដោយកាន់គំនិតថា " លំបាកមុនស្រណុកក្រោយ" ពោលគឺ មានការអត់ធន់ ព្យាយាមនៅរវាងសេចក្តីលំបាក និងភាពស្រណុកសុខសប្បាយថ្ងៃថ្នូររុងរឿង ។

ផ្ទុយមកវិញ ក៏មិនតិចនាក់ដែរ ដែលជាមនុស្សស្គាល់តែសប្បាយតាំងពីកើតមក មិនដែលស្គាល់ មិនដែលជួបនូវសេចក្តីលំបាកឡើយ លុះដល់មានហេតុនាំឲ្យសេចក្តីលំបាកកើតឡើង ក៏ស្ទើរតែជួយខ្លួនឯងមិនរួច ធ្វើអ្វីក៏មិនកើត ចាប់អ្វីក៏មិនជាប់ ការងារធ្ងន់ស្រាលមិនចេះធ្វើទាំងអស់ ទម្រាំតែបានរស់ស្ទើរតែស្លាប់ទៅហើយ ។ មានខ្លះទ្រាំនឹងលំបាកមិនបាន ក៏ត្រូវបាត់បង់ជីវិតទៅ ។

ដូច្នេះ កូនកុំទៅខ្លាចសេចក្តីលំបាកធ្វើអ្វី ត្រូវចាំទុកថាសេចក្តីលំបាកជាគ្រូបង្វឹក ។ កូនត្រូវលត់ដំខ្លួនជាមួយនឹងសេចក្តីលំបាកដោយសេចក្តីអត់ធន់ ត្រូវយកផលកម្រៃពីសេចក្តីលំបាកចម្រើនគុណធម៌ក្នុងចិត្ត និងយកសេចក្តីលំបាកជាមេរៀន ដែលកូនត្រូវតែសិក្សាថា អាត្មាអញមិនវិលត្រឡប់ទៅរកសេចក្តីលំបាកទៀតឡើយ ។

ភ្លើងឆេះខ្ទេចព្រៃអ្វីទៀតអនេក        តែធ្វើឲ្យដែករឹងរឹតតែរឹង
ទុក្ខដុតមនុស្សខ្សោយឲ្យប្រាសទីពឹង  តែបែរមនុស្សរឹងគ្រាស់ដឹងសច្ចៈ។
មិនមានអ្វីសល្អជាងគុណធម៌        ខន្តីបវរតស៊ូឥតអាក់
ទឹកតែមួយផ្តិលត្រឹមសើមប្រឡាក់   ព្យាយាមដងចាក់ដាក់ពេញអាងធំ។
វីរៈប្រែថាអ្នកក្លាអង់អាច        ទុក្ខខ្លាំងមិនខ្លាចព្រោះអាចផ្សំផ្គុំ
ព្យាយាមខន្តីបញ្ញាអប់រំ        ឈ្នះអស់ទុក្ខធំជួបជុំគុណគាប់។
លទ្ធផលការងារជាតម្លៃមនុស្ស     ធ្វើការដូចព្យុះជម្រុះអកុសល
ជម្នះឧបសគ្គប្រចក្សកំណាប់     គុណធម៌ជាទ្រព្យជាប់តាមជីវិត។
មនុស្សដែករឹងប៉ឹងតែមិនរឹងរូស    ព្យាយាមជម្រុះមានះក្នុងចិត្ត
ទន់កាយវាចាមេត្តាមានពិត      តែរឹងប្រព្រឹត្តសុចរិតដូចដែក។

## ៧-ទឹកចិត្តមានតម្លៃជាងទឹកប្រាក់

កូនជាទីស្រឡាញ់

កាលកូនទៅបម្រើការរាជការ ឬទៅធ្វើការស៊ីឈ្នួលគេ គឺកូនធ្វើការអ្វីក៏ដោយ ចូរកូនធ្វើឲ្យពេញដៃពេញជើង ប្រឹងប្រែងឲ្យអស់សមត្ថភាព ឲ្យសមនឹងតម្លៃប្រាក់ខែ ឬតម្លៃ ឈ្នួល ។ ប្រសិនបើកូនធ្វើឲ្យលើសជាង ប្រាក់ខែ ឬតម្លៃឈ្នួល នោះគឺរឹតតែល្អ ។ កុំធ្វើការគ្រាន់តែដើម្បីឲ្យបានប្រាក់តែម៉្យាង កុំគិតត្រឹមតែឲ្យការងារហើយស្រេចតែប៉ុណ្ណោះ ត្រូវធ្វើការងារដើម្បីឲ្យការងារសម្រេចដោយល្អផង ទើបជាការសមរម្យ ។ មនុស្សយើងគួរជាមនុស្សមានទឹកចិត្ត កុំជាមនុស្សខ្វះទឹកចិត្តឲ្យសោះ ។

មនុស្សដែលធ្វើការលើសអំពីតម្លៃនៃប្រាក់ខែ ប្រាក់ឈ្នួលដោយការពេញចិត្ត សម្តែងដល់ចិត្តដែលមិនយកប្រៀប គេទោះបីខាតពេលវេលាបន្តិចបន្តួចក៏ពិត ប៉ុន្តែ សម្រេចការងារបានល្អ នាំឲ្យចិត្តរបស់ខ្លួនមានការរីករាយជាសុខ ។ សេចក្តីរីករាយជាសុខនេះឯង ជាខ្លឹមសារសំខាន់នៃជីវិត ដែលមិនអាចរកទិញនៅទីណាបានឡើយ ក្រៅអំពីការមានទឹកចិត្តនៃខ្លួនឯង ។

កាលដែលមនុស្សយើងមានទឹកចិត្ត ចិត្តក៏រមែងមាននូវទឹកសម្រាប់ផ្សើមឲ្យស្រស់បស់ ត្រជាក់ ប្រាសចាកនូវសេចក្តីកំណាញ់ និងការប្រណែនជាដើម ខុសអំពី

-

មនុស្សដែលមិនមានទឹកចិត្ត ។ មនុស្សដែលមិនមានទឹកចិត្តក្រៅអំពីចិត្តរបស់គេមិនមានការរីករាយជាសុខក្នុងការងារហើយ ចិត្តរបស់គេរមែងស្ងួតក្រៀមក្រោះ ដូចស្រែដែលខ្វះទឹកអ៊ីចឹង ឯង ។

ចូរកូនហ្វឹកហាត់ខ្លួន ឲ្យបានទៅជាមនុស្សមានទឹកចិត្ត ។ ចូរកូនកុំគិតថារឿងនេះវាជារឿងចាញ់ប្រៀបគេ ឬជាអ្វីដែលមិនល្អឲ្យសោះ កូនត្រូវគិតដូច្នេះវិញថា វាជារឿងនៃទឹកចិត្តដែលនឹងគប្បីមានឲ្យដល់គ្នា ដើម្បី បាននៅធ្វើការជាមួយគ្នាអស់កាលដ៏យូរ ហើយក្នុងទីបំផុត ទឹកចិត្តរមែងមានតម្លៃជាងទឹកប្រាក់ណា+កូន ។

-

## ៨-រក្សាសម្ដី

កូនជាទីស្រឡាញ់

ពាក្យនិយាយជាការសំខាន់ម្យ៉ាងរបស់មនុស្សយើង កូនត្រូវប្រយ័ត្ន ២ យ៉ាង ”

១-មុននិយាយ

២-និយាយរួចហើយ

មុននិយាយ កូនត្រូវគិតមុខគិតក្រោយឲ្យល្អ និងកាលនិយាយរួចហើយ កូនត្រូវរក្សាពាក្យនិយាយ ។

ពាក្យដែលយើងនិយាយចេញទៅហើយ គឺជាចៅហ្វាយនាយរបស់យើងណា⁺កូន នឹងបង្អាប់ឲ្យយើងត្រូវតែធ្វើ តាមដូចជាទទួលពាក្យអ្វីពីអ្នកដទៃ គឺត្រូវធ្វើឲ្យបានទៅតាម សន្យាទោះបីជាត្រូវចុះទុនចេញកម្លាំងខ្លាំងក្លាយ៉ាងណាក៏ដោយ រហូតដល់ទៅត្រូវស្លាប់ក៏ត្រូវព្រមដែរ ដើម្បីរក្សាសម្ដី ។

កូនអើយ រឿងពាក្យសម្ដីនេះ មនុស្សទាំងឡាយគេកាន់យកណាស់ បើបង់សម្ដីទៅហើយ អ្វីៗដទៃទៀត សូម្បីល្អយ៉ាងណាក៏រមែងខូចដោយទៅតាមដែរ ឬក៏ត្រូវអស់សម្រស់ព្រោះហេតុតែខូចកេរ៍ឈ្មោះក្នុងការមិនរក្សាសម្ដី ដូច្នេះហើយទើបបុរាណពោលថា “មនុស្សគេយកសម្ដី ដំរីគេយកភ្លុក” ។

-

ព្រោះហេតុនេះ នៅពេលកូនគិតថា ខ្លួនឯងត្រូវលំបាកព្រោះហេតុតែត្រូវរក្សាសម្ដី ហើយបើកូនមិនចង់លំបាក គឺកូនកុំចេះតែទទួលពាក្យគេដោយងាយៗនោះ ត្រូវពិចារណាឲ្យល្អជាមុនថា កាលទទួលពាក្យគេហើយ អាត្មាអញនឹងធ្វើបានយ៉ាងនោះដែរឬទេ គឺត្រូវគិតឲ្យល្អិត- ល្អន់ស្រួលបួលជាមុនសិន។

មនុស្សយើង បើរក្សាពាក្យសម្ដីខ្លួនឯងទុកមិនបានទៅហើយ តើអាចរក្សាអ្វីបានទៅ ព្រោះអម្បាលពាក្យសម្ដី ជាសម្បត្តិមានតម្លៃក្នុងខ្លួនរក្សាមិនបានផង ចំណង់បើរបស់ដទៃក្រៅខ្លួនធ្វើដូចម្ដេចនឹងអាចរក្សាបាន ។ ដូច្នេះ ទើបម៉ែឪជាស់តឿនឲ្យកូនពិចារណាឲ្យល្អមុននិយាយ មុនសន្យាអ្វីៗជាមួយអ្នកណាៗ ហើយត្រូវកូនកុំជាមនុស្សភ្លេចពាក្យសន្យាដោយងាយៗឡើយ ។

មនុស្សដែលបង់ពាក្យបង់សម្ដី សូម្បីដោះស្រាយយករួចខ្លួនបានម្ដងក៏ពិត តែលុះដល់តទៅកាលបើមានហេតុការណ៍ចាំបាច់ត្រូវសន្យាធ្វើឲ្យបានយ៉ាងណានោះ ក៏គេដកសេចក្ដីទុកចិត្តដែរ ។

ចូរកូនកុំជាមនុស្សនិយាយឡេះឡោះ ឬនិយាយកុហកសូម្បីតែដើម្បីសើចលេងឡើយ និងចូរកូនចាំទុកថា ពាក្យសម្ដីសំខាន់សម្រាប់មនុស្សយើងខ្លាំងណាស់ ។

-

ចូរកូនចាំពាក្យខាងក្រោមនេះ

-ពាក្យសម្ដីជាការងារដ៏ធំ បណ្ឌិតរមែងរក្សាសច្ចៈ។

-និយាយតិចតែបានការ ប្រសើរជាងនិយាយច្រើនឥតប្រយោជន៍ ។

-មិនមែនបណ្ឌិតព្រោះហេតុតែនិយាយច្រើនទេ ។

-គុណធម៌មិនមែននៅនឹងអណ្ដាតទេ គឺឋិតនៅតែក្នុងចិត្តប៉ុណ្ណោះ។

## ៩-ចិត្តមួយថ្លើមមួយ

កូនជាទីស្រឡាញ់

ធម៌ដែលនឹងធ្វើឲ្យគូគ្រងនៅជាមួយគ្នា រហូតតទៅនោះ ក៏គឺការស្មោះត្រង់ដល់គ្នា មិនក្បត់ចិត្តគ្នា រក្សាពាក្យសន្យាថា ស្មោះត្រង់នឹងគ្នាតាំងតែពីដំបូងមកនោះឯង ។

សច្ចៈតាំងចិត្តស្មោះត្រង់ មានតួនាទីធ្វើជាសោមាសចាក់បេះដូងស្វាមីនិងបេះដូងភរិយាឲ្យជាប់គ្នា ។ កាលបើមានសច្ចៈចិត្តមួយថ្លើមមួយហើយ អ្វីដទៃផ្សេងទៀត ដូចជាការយល់ចិត្តគ្នា ការឲ្យអភ័យ សេចក្ដីអត់ធន់ ការបរិច្ចាគ លះបង់ ការទូន្មានចិត្ត និងការដឹងគុណគ្នាទៅ វិញទៅមកជាដើម ក៏រមែងតាមមកជង្គ្រែសច្ចៈ ។

ការស្មោះត្រង់នឹងគ្នារវាងភរិយាស្វាមី ជាហេតុធ្វើឲ្យគ្រួសាររស់នៅជាសុខ មិនឈ្លោះប្រកែកទាស់ទែង លែងលះគ្នា មិនរង្កៀសសង្ស័យគ្នា មិនប្រច័ណ្ឌគ្នាជាដើម ដូច្នេះការស្មោះត្រង់ជាសភាវៈល្អខ្លាំងណាស់សម្រាប់ភរិយាស្វាមី គួរថែរក្សាថ្នាក់ថ្នមទុកឲ្យល្អជាទីបំផុត ។ ដល់ពេលកូនមានគ្រួសារ កូនត្រូវតែចាប់យកនូវការស្មោះត្រង់ នេះមករក្សាទុកកុំខាន ដើម្បីឲ្យគ្រួសាររបស់កូនបានសុខ សប្បាយនិងក្សេមក្សាន្ត ។ បើចំណែកខាងណាមួយមិនស្មោះត្រង់ទៅវិញនោះ នឹងរស់នៅមិនបានសុខឡើយ កូនគិតមើលចុះ ការដែលត្រូវឃើញមុខគ្នានិងរស់នៅ

ជាមួយ មនុស្សដែលមិនស្មោះត្រង់នោះ តើមានការបង្អៀតចង្អល់តូចចិត្ត លំបាកចិត្តយ៉ាងណា កូនគង់តែគិតឃើញមិនខាន ដូច្នេះទើបប្តីប្រពន្ធមិនត្រូវប្រព្រឹត្តឲ្យជាមនុស្សនៅក្រៅបេះដូងរបស់គូគ្រងឡើយ ពោលគឺមិនត្រូវក្បត់ចិត្តគ្នា ។

មនុស្សយើង បើសូម្បីតែសច្ចៈចំពោះគូគ្រងដែលខ្លួនស្រឡាញ់រក្សាមិនបានទៅហើយ តើត្រូវរក្សាអ្វីឲ្យគូគ្រងរបស់ខ្លួនបានទៅ ហើយនឹងត្រូវរក្សាសេចក្តីល្អអ្វីដទៃ ទៀតបានដែរទៅ ។ ការដែលគួរជឿទុកចិត្តនិងយសសិរីរបស់មនុស្សយើងនោះ គឺចាប់ផ្តើមពីសច្ចៈនេះឯង ។ មានតែមនុស្ស ដែលរក្សានូវសច្ចៈមានការស្មោះត្រង់ ប៉ុណ្ណោះដែលគួរឲ្យជឿទុកចិត្តបាន ចំណែកមនុស្សដែលខ្វះសច្ចៈ សូម្បីតែជាមួយ នឹងគូគ្រងរបស់ខ្លួនឯង ហើយទៅមានសច្ចៈជាមួយនឹងអ្នកដទៃ នោះជាការលំបាកនឹងឲ្យជឿណាស់។

គ្រប់ទីកន្លែងដែលគេតែងប្រកាន់រហូតមក គឺថាជាការអាប់ឱនកិត្តិយសខ្លាំងណាស់ ក្នុងរឿងដែលមិនមានចិត្តមួយ ថ្លើមមួយ ហើយទៅរំលែកចែកកាយចែកចិត្តឲ្យដល់អ្នកដទៃ ជាពិសេសស្ត្រីខ្មែរ... ។

បើកូនប្រុសស្រី មានបំណងចង់ជួបគ្នាជាភរិយា ស្វាមីឲ្យមានសេចក្តីសុខសាន្តតភពជាតិកំណើត រហូតដល់បរមសុខគឺព្រះនិព្វាន កូនត្រូវតែជាគូគ្រងដែលមានសទ្ធាស្មើគ្នា មានសីលស្មើគ្នា មានការបរិច្ចាគស្មើគ្នា និង មានបញ្ញាស្មើគ្នា ព្រមទាំងចេះនិយាយស្តាប់គ្នាមានហេតុមានផលជាគោលកាន់យក មិនចចេសអាងអញយ៉ាងនេះ អាងអញយ៉ាងនោះឡើយ ។

## ១០-ព្រមល្ងង់ខ្លះល្អណាស់កូន

កូនជាទីស្រឡាញ់

ការដែលយើងធ្វើខ្លួនជាមនុស្សមានទឹកចិត្ត មានការស្មោះត្រង់ និងមានការស្រឡាញ់យុត្តិធម៌នោះ អ្នកដទៃគេអាចមើលមកថា យើងល្ងង់មិនចេះរកស៊ី មិនចេះចង់មានចង់បាន មិនចេះឆក់ឱកាស ។ កូនអើយព្រមឲ្យគេថាទៅចុះ ព្រមឲ្យគេថាល្ងង់ ល្អជាងកូនជាមនុស្សមិនមានទឹកចិត្ត មិនមានសុចរិតស្មោះ និងមិនមានយុត្តិធម៌ ។

កូនធ្វើការដោយស្មោះត្រង់ មានទឹកចិត្តចំពោះអ្នកដទៃ ស្លូតបូតត្រឹមត្រូវ សូម្បីមិនសូវមានទ្រព្យលើសពីការប្រើប្រាស់ដូចគេក៏ដោយ តែកូនសប្បាយចិត្ត ។ គ្រួសារយើងអាចខ្វះខាត ខ្វះ ប៉ុន្តែមានការកក់ក្តៅ រស់នៅឃើញមុខគ្នា មិនគិតខ្វល់ឬរង្កៀសចិត្តក្នុងរឿងអ្វីច្រើនឡើយ ។

រវាងការមានបានទ្រព្យសម្បត្តិ តែមិនមានការកក់ក្តៅ និងមានការកក់ក្តៅគ្រាន់តែមិនសូវមានទ្រព្យ ពីរយ៉ាងនេះតើកូនជ្រើសរើសយកមួយណា?

មានមនុស្សមួយចំនួន មានមុខមានមាត់ក្នុងសង្គមមានពេលវេលាដើរទាក់ទងយកចិត្តយកថ្លើមអ្នកដទៃ ជាងមានពេលនៅជាមួយគ្រួសាររបស់ខ្លួនឯង ឬក៏ត្រូវស៊ុះទៅលិច ស៊ុះទៅកើត

-

ដើម្បីរក្សាផលប្រយោជន៍របស់ខ្លួនរហូតមិនមានល្ហែ ឲ្យពេលទៅផលប្រយោជន៍ខាងក្រៅផ្សេងៗ ច្រើនជាងឲ្យដល់គ្រួសារ ឬពុំនោះសោត ត្រូវប្រឹងប្រែង ព្យាយាមប្រចុបប្រចែង អ្នកតូចអ្នកធំដើម្បីផលប្រយោជន៍នោះៗ ។ ដូច្នេះឯង ដែលគាត់ គិតថាខ្លួនគាត់ឆ្លាត បានជាភ្លេចថា ព្រោះការឆ្លាតរបស់ខ្លួន នោះឯងបានធ្វើឲ្យខ្លួនមិនមានពេលបរិភោគ ឬបរិភោគខុសពេល មិនមានពេលដេក មិនមានពេលសម្រាក និងមិនមានពេលឲ្យដល់គ្រួសារគ្រប់គ្រាន់ ធ្វើឲ្យគ្រួសារខ្វះការកក់ក្តៅ ។

កូនអើយ ពិតមែនហើយថា ក្នុងគ្រួសារចាំបាច់ត្រូវមានប្រាក់ ប៉ុន្តែមិនមែនឲ្យតែមានប្រាក់ គឺមានសុភមង្គលមានភាពកក់ក្តៅក្នុងចិត្ត ក្នុងជីវិតទៅសព្វគ្រប់នោះទេ ។ មានស្ត្រីជាភរិយាច្រើនណាស់ ដែលមិនខ្វះទ្រព្យសម្បត្តិ មានសុទ្ធតែរបស់ល្អរបស់ថ្លៃ ប៉ុន្តែជាប្រក្រតីមានមុខអាប់ស្រពោន ព្រោះខ្វះភាពកក់ក្តៅពីស្វាមីនោះឯង ។ មនុស្សដែល គិតថាខ្លួនឯងឆ្លាតតែមិនមានពេលដេកនៅផ្ទះ ត្រូវចោលប្រពន្ធចោលកូនជារឿយៗ ខ្វះការស្មោះត្រង់មួយ នឹងមួយ ខ្វះធម៌សន្តោស ល្មោភលោភ លន់រកស៊ីទុច្ចរិត ខ្វះយុត្តិធម៌ ។ល។ កូនអើយ ក្នុងរឿង ទាំងអស់នេះបើគេថាកូនល្ងង់មែនទែនព្រោះមិនចេះដូច គេ គឺជាការល្អណាស់ ។ កូនចេះត្រឹមតែការងាររបស់កូន ដោយទឹកចិត្ត សុចរិតស្មោះត្រង់

-

គ្រួសារមានការកក់ក្ដៅ ដូច្នេះកូនត្រូវរស់នៅដោយសេចក្ដីសុខសប្បាយ ក្បាលដល់ខ្នើយកូនគេងលក់ មិនចាំបាច់យកដៃគងថ្ងាសឡើយណា៎កូន ។

✍📖✍

-

## ១១-ឲ្យអភ័យ

កូនជាទីស្រឡាញ់

ក្នុងលោកនេះ មិនមានអ្នកណាដែលធ្វើអ្វីត្រឹមត្រូវ ឬល្អទៅទាំងអស់នោះឡើយ ព្រោះថា គឺជាអ្នកនៅមានកិលេសដែលជាគ្រឿងសៅហ្មងចិត្ត ហើយក៏មិនមានអ្នកណាធ្វើអ្វីៗឲ្យត្រូវចិត្តយើងគ្រប់បែបយ៉ាងនោះដែរ ។ ចំណែកយើងក៏ដូចគ្នាទោះជាយើងខំធ្វើល្អ ធ្វើត្រូវទៅគ្រប់យ៉ាងក៏ដោយ ក៏គង់មានគេទាស់ចិត្តនឹងយើងដែរ ។

អ្នកដទៃគេធ្វើអ្វីខុស មានការខ្វះខាត ឬធ្វើអ្វីមិនត្រូវចិត្តមិនត្រូវអធ្យាស្រ័យរបស់កូន កូនត្រូវចេះឲ្យអភ័យដល់គេ កុំប្រកាន់ កុំខឹងក្រោធ និងកុំទៅឈ្លោះប្រកែក ទាស់ទែងអ្វីនឹងគេឡើយ កូនត្រូវនៅស្ងៀមឲ្យបានល្អ បើមានអ្វីត្រូវបកស្រាយ កូនត្រូវមើលឱកាស មើលអ្នកដទៃ ហើយចិត្តរបស់កូន ត្រូវតែត្រជាក់មិនក្ដៅក្រហាយ ពិចារណាឃើញហេតុឃើញ ផលច្បាស់សិនសឹមនិយាយ។

កូនត្រូវចាំពាក្យនេះទុកថា :

ឬស្សីអាងបន្ទាការពារខ្លួន ប្រាជ្ញអាងច្បាប់ក្បួនការពារខុស
ជនពាលគ្មានអាងអ្វីទាំងអស់ អាងតែឈ្លោះតទល់កម្លាំងបាយ។

-

កាលកូនឲ្យអភ័យដល់គេហើយ អ្នកដែលសប្បាយចិត្តគឺកូនហ្នឹងឯង ។ ការបង្កនូវសេចក្តីក្រោធទុក គឺជាការបង្កជុំភ្លើងនឹងចិត្ត ត្រូវគិតអាឃាតព្យាបាទ គិតរកឧបាយបៀតបៀនគេរឿយៗជាដើម មានតែអាក្រក់ប៉ុណ្ណោះ មិនមានអ្វីល្អឡើយ ។

ការឲ្យអភ័យម្យ៉ាងទៀត គឺឲ្យការមិនមានភ័យដល់អ្នកដទៃ បានសេចក្តីថា ធ្វើខ្លួនរបស់យើងមិនឲ្យមានពិស មិនឲ្យមានភ័យដល់អ្នកដទៃ មិនបង្កការភ័យខ្លាច សេចក្តីក្តៅក្រហាយផ្សេងៗឲ្យដល់អ្នកណាៗឡើយ ។

កូនត្រូវធ្វើខ្លួនឲ្យគេស្គាល់ចិត្តជាគ្នាឯង មិនមានស្មៀតមិនក្រឡេបក្រឡុប និងជាទីទុកចិត្តរបស់អ្នកដទៃ ធ្វើយ៉ាងនេះឈ្មោះថាឲ្យអភ័យ ។

កូនត្រូវយល់ថា ការឲ្យអភ័យ គឺការឲ្យសេចក្តីល្អដល់ខ្លួនកូនហ្នឹងឯង អ្នកផងទាំងពួងគេទុកចិត្ត ប្រគល់ការងារសំខាន់ៗឲ្យកូនធ្វើ ខុសអំពីមនុស្សដែលមានពិស។ មនុស្សដែលមានពិស ទុកចិត្តមិនបាន ទៅទីណាៗគេមិន ចង់ឲ្យចូលជិតនៅក្នុងទីណាៗ គេខ្លាច គេបារម្ភ ធ្វើការអ្វីៗគេមិនទុកចិត្ត វាជាការមិនល្អគ្រប់យ៉ាង ចូរកូនកុំជា មនុស្សមានពិសមានភ័យដល់អ្នកដទៃឡើយ ។

-

បើកូនឲ្យអភ័យដល់អ្នកដទៃបាន កូននឹងបានសុខសប្បាយ បើកូនធ្វើខ្លួនមិនឲ្យមានពិសមានភ័យដល់អ្នកដទៃបាន កូននឹងនៅក្នុងទីណាក៏នៅបាន មិនមានអ្នកណារង្កៀសភ័យ ព្រួយបារម្ភអ្វីឡើយ ដូច្នេះកូនត្រូវហ្វឹកហាត់ឲ្យអភ័យ កុំទៅ គិតថាជាការអន់ខ្សោយ ខូចយស ខូចសក្តិ ព្រោះការឲ្យ អភ័យនោះ ។ ដោយហេតុតែមនុស្សយើង ស្រឡាញ់យស ស្រឡាញ់សក្តិប្រកាន់អំណាចខ្លាំងក្លាពេកទៅហ្នឹងឯង ទើបត្រូវមកបង្កកម្មពៀរនឹងគ្នាមិនមានទីបំផុត ។

-

## ១២-មិត្តសម្លាញ់រហូតក្នុងជីវិត

កូនជាទីស្រឡាញ់

កូនធ្លាប់គិតដែរទេថា មិត្តដែលល្អជាទីបំផុតរបស់មនុស្សយើងគឺសៀវភៅ ។ សៀវភៅជាមិត្តរបស់យើងបានគ្រប់ពេលវេលា មិនថាពេលសុខ ពេលទុក, ពេលសោកសៅ ឬពេលអផ្សុកឡើយ រមែងជាប់តាមយើងទៅបានគ្រប់កន្លែង ទោះជានៅព្រៃ នៅភ្នំ នៅកណ្តាលសមុទ្រ ហើយរហូតដល់មែនទែនគឺនៅក្នុងបន្ទប់គេង ។ មិនថាកូនជាអ្វី កូននៅក្នុងទីណា កូនកុំចោលសៀវភៅ បើកូនចោលសៀវភៅ គឺស្មើគ្នានឹងចោលមិត្តដ៏ល្អរបស់កូន ។ ចូរកូនព្យាយាមអានសៀវភៅឲ្យច្រើនៗ ហើយកូនត្រូវចេះជ្រើសរើសសៀវភៅសម្រាប់អានកុំឲ្យខាតពេល។

ពាក្យទូន្មានប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធ ដែលកូនបានអាន ឬស្តាប់ គឺជាផែនទីនៃជីវិតរបស់កូន ។

សេចក្រ្ដីវភៅល្អមួយក្បាល ស្មើនឹងមិត្តល្អម្នាក់ ។ សៀវភៅអ្វីៗដែលកូនអានហើយ ចូរកូនពិចារណាថា គួរជឿតាមអ្នកសរសេរ ឬមិនជឿ ព្រោះអ្នកសរសេរមានច្រើន ប្រភេទ មានការគិតនិងចំណេះដឹងផ្សេងៗគ្នា រីឯចេតនា ក៏ផ្សេងៗគ្នាដែរ ដូច្នេះកូនត្រូវពិចារណាឲ្យច្រើនកុំទាន់អាលជឿ ។ ចូរកូនចាំទុកថា សៀវភៅគឺជាខួរក្បាលរបស់អ្នកសរសេរ

-

ដូច្នេះបើកូនអានសៀវភៅល្អៗឈ្មោះថា ជាការបញ្ចូលខួរក្បាលរបស់អ្នកចេះដឹងមកក្នុងខួរក្បាលរបស់កូន ។

ទោះជាពេលថ្ងៃក៏ដោយ ក្នុងផ្ទះរមែងងងឹត បើគេបិទទ្វារបិទបង្អួចអស់ យ៉ាងណាមិញ បើកូនបិទភ្នែក បិទ ត្រចៀកពោលគឺ មិនអាន មិនស្តាប់នូវភាសិតរបស់អ្នកចេះ ដឹងទេ វិញ្ញាណរបស់កូននឹងត្រូវងងឹត ដូចជាផ្ទះដែលបិទជិត យ៉ាងនោះឯង ។

ដើម្បីឲ្យបានទៅជាមនុស្សល្អ កូនត្រូវ :

១-ស្វែងរកការចេះដឹងមកដាក់ខ្លួន កុំចំណាយពេលវេលាឥតប្រយោជន៍ ។

២-ប្រព្រឹត្តតាមការចេះដឹង យកការចេះដឹងជានាយកនៃជីវិត កុំឲ្យតណ្ហាដឹកនាំជីវិតឡើយ ។

ចូរកូនសម្លាញ់ ធ្វើជាមិត្តរបស់អ្នកប្រាជ្ញទាំងឡាយតាមរយៈនៃការអានសៀវភៅចុះ សេចក្តីចម្រើននឹងមានដល់កូនជាពិតប្រាកដ ។

**សទ្ទហានោ អរហតំ ធម្មំ និព្វានបត្តិយា**

ទីមួយជឿធម៌ព្រះអរហន្តា ធម៌ល្អអស្ចារ្យនាំដល់និព្វាន ។

**សុស្សូសំ លភតេ បញ្ញំ** ទីពីរចិត្តតាំងប្រឹងស្តាប់ដោយឃ្មាន ព្រះធម៌ទេសនាតាមព្រះទូន្មាន គោរពធម្មទានបានមានបញ្ញា។

-

**អប្បមត្តោ ទិចក្ខុណោ** *ពីរនេះជាសោបើកទ្វារមោហាមួយមិនប្រមាទមួយពិចារណា ប្រាជ្ញាភ្លឺថ្លាដោយអង្គបួននេះ ។*

✍📖✍

## ១៣-សម្បត្តិមនុស្សល្អ

*កូនជាទីស្រឡាញ់*

*ពេលដែលកូននៅក្នុងសង្គម ហើយត្រូវទាក់ទងជាមួយអ្នកដទៃ កូនត្រូវរៀបចំឫកពាឲ្យល្អ និយាយពាក្យពីរោះ ព្រមទាំងត្រូវរៀបចំខ្លួនប្រាណ សម្លៀកបំពាក់ឲ្យបានល្អផង នេះជាការចាំបាច់ណាស់ ព្រោះដើម្បីជាការសម្តែងបញ្ជាក់ថា កូនជាមនុស្សល្អ។*

*ការដែលបានអប់រំបន្ទុំឧបនិស្ស័យមកល្អ ទើបសម្តែងអាកប្បកិរិយាចេញមកល្អ គេហៅមនុស្សដូចនេះថា អ្នកមានសម្បត្តិមនុស្សល្អ ។ អ្នកមានសម្បត្តិមនុស្សល្អ រមែងមានប្រៀបលើមនុស្ស ដែលខ្វះនូវគុណសម្បត្តិទាំងនេះ ក្នុងគ្រប់រឿងទាំងអស់ ទាំងការនិយមរាប់អាន ការឲ្យនូវភាពស្និទ្ធស្នាល ការឲ្យនូវភាពទុកចិត្ត រហូតដល់ប្រគល់ការងារមុខនាទីសំខាន់ៗឲ្យធ្វើទៀតផងជាដើម ។*

*សម្បត្តិមនុស្សល្អ គឺការសម្តែងអាកប្បកិរិយាចេញមកមានសភាពរៀបរយត្រឹមត្រូវ គួរគយគន់ មិនទាស់ភ្នែក មិនទាស់ត្រចៀក ពេញទៅដោយភាពទន់ភ្លន់ និងការគោរពកោតក្រែង ។ កូនគួរហ្វឹកហាត់នូវសម្បត្តិមនុស្សល្អ ទុកជាសម្បត្តិប្រចាំខ្លួន មានជាអាទិ៍គឺ តែងខ្លួនដោយសម្លៀកបំពាក់សមរម្យនឹងវ័យ មិនដោះសម្លៀកបំពាក់ក្នុងទីសាធារណៈពាក់អាវ ត្រឹមត្រូវនៅចំពោះមុខ*

ក្បៀវៗ មាន ភាពទន់ភ្លន់បន្ទន់ខ្លួន បេះក្រាបសំពះ ធ្វើការគោរព ចំពោះអ្នកធំ និយាយស្ដីសង្រួមមាត់ មិននិយាយឲ្យសំឡេងខ្លាំង កោកកាកឡូឡាក្នុងទី សាធារណៈ ឬក្នុងទីប្រជុំមនុស្ស មិននិយាយ ជ្រែកកាត់ក្នុង ពេលដែលអ្នកធំកំពុងសន្ទនាគ្នា បេះក្រែងចិត្តអ្នក ដទៃ ។ ពេលទទួលទានអាហារក៏សង្រួម មិនរឹបរ៉ាប់ប្រញាប់ដូច ខ្លាចអស់ម្ហូប មិននិយាយក្នុងពេល មានអាហារក្នុងមាត់ នឹងក្រោក នឹងអង្គុយក៏សង្រួមប្រយ័ត្ន ត្រួតត្រាមើលសព្វមើលគ្រប់ ។

សម្បត្តិមនុស្សល្អ ជាហេតុឲ្យមនុស្សយើងមានស្នេហ៍ គួរស្រឡាញ់ នឹងជាហេតុឲ្យអ្នកធំស្រឡាញ់អាណិត ប្រាថ្នានឹង ជួយទំនុកបម្រុងក្នុងរឿងផ្សេងៗ ។ សម្បត្តិមនុស្សល្អ គឺជាអា ភរណៈគ្រឿងប្រដាប់តែងខ្លួន គួរជាទីរីករាយនិងរាប់អានដល់ មនុស្សទាំងឡាយគ្រប់ទីកន្លែង ។

គួរស្ដុកស្ដើយធ្លឹតបង្កើតខកចិត្ត មនុស្សស្អុកមានពិតគំនិតជាបដុន កើតមកជាមនុស្សស៊ីជុះអស់ទុន ជីវិតទារុណគ្មានគុណតម្លៃ ។ មនុស្សយើងផលិតជីវិតខ្លួនឯង រៀបចំតាក់តែងចាត់ចែងរាល់ថ្ងៃ ប្រាជ្ញសាងជីវិតពិតដូចចរណៃមាសប្រាក់កាឡៃបីដូចមនុស្សខ្វៅ។ ប្រាជ្ញសាងជីវិតពិតដូចជាផ្កាយ គោចរមិនណាយតម្រង់ទិសដៅ ឆ្វេងកាត់លោកយសចិត្តឥតហ្មង សៅតម្រង់ទិសដៅគុណភាពជីវិត។ ពាលស្រឡាញ់ខ្លួនពួនស៊ីថ្នាំពិស ជីវិតស្មូរទ្រើស្ដិរើសកំហាកលិទ្ធ ស្ងឹកឈើចាកមែកជ្រែកខ្យល់វិបរិតគ្មានគោលដៅពិតជីវិតអន្ធពាល ។

## ១៨-ការក្រែងចិត្ត

*កូនជាទីស្រឡាញ់*

*កាលបើកូននឹងធ្វើអ្វី មិនថានឹងធ្វើក្នុងផ្ទះរបស់ខ្លួន ឯង ឬនឹងធ្វើនៅទីដទៃណាៗ បើការងារដែលនឹងធ្វើនោះ អាចប៉ះពាល់ដល់អ្នកជិតខាង ធ្វើឲ្យគេរំខាន ឬក្តៅក្រហាយចិត្ត កូនត្រូវប្រយ័ត្នឲ្យណាស់ ។ កូនកុំធ្វើអ្វីៗតាមចិត្តចង់ ឬប្រកាន់សិទ្ធិថា ធ្វើបាននោះឡើយ កូនត្រូវចេះក្រែងចិត្តអ្នកដទៃខ្លះផង ដូចជានៅផ្ទះជាប់គ្នា នៅបន្ទប់ជាប់គ្នា ឬនៅបន្ទប់ជាមួយគ្នាជាដើម ។ ការក្រែងចិត្តគ្នានេះល្អណាស់ នាំឲ្យមិនឈ្លោះគ្នា មិនទាស់ចិត្តគ្នាទទេៗ ។ កូនសាងមិត្តល្អជាងសាងសត្រូវ សាងសត្រូវមិនល្អទេ កូនកុំចេះតែគិតថា អ្នកណាស្អប់ៗទៅ ទាំងកូនខ្លួនឯងក៏កុំចូលចិត្តស្អប់អ្នកដទៃឡើយ ។*

*បើចាំបាច់កូននឹងធ្វើអ្វី កូនត្រូវប្រាប់ឲ្យគេដឹងជាមុន ឬរឹតតែល្អណាស់ទៅទៀតនោះ គឺកូនសូមអនុញ្ញាតពីគេ។ រឿងនេះមិនមានខូចខាតអ្វីឡើយ ការដែលកូនចេះក្រែងចិត្តអ្នកដទៃនោះ គេក៏នឹងក្រែងចិត្តកូនវិញដែរ ហើយគេសប្បាយចិត្តនឹងអនុញ្ញាត ហើយគេអាចទ្រាំបានក្នុងកិច្ចការដែលកូនធ្វើនោះ គឺគេមិនក្តៅក្រហាយចិត្តដោយគិតថា កូនរំខានគេឡើយ ។*

-

*សូមឲ្យកូនយកចិត្តគេមកដាក់ចិត្តកូន មានខ្លួនឯងជាឧបមា ចិត្តយើងចិត្តគេ កុំធ្វើអ្វីៗតាមតែចិត្តខ្លួនឯងឲ្យសោះ ។ សូមឲ្យកូនចាំទុកថា ការក្រែងចិត្តជាសម្បត្តិរបស់មនុស្សល្អ ជាក្រមួនស្នេហ៍ ជាមារយាទក្នុងសង្គម និងជាសុជីវធម៌ធ្វើមិនឲ្យទាស់ចិត្តអ្នកដទៃផង ។*

*លើកតួយ៉ាងដូចជា នៅក្នុងបន្ទប់ប្រជុំ ឬកន្លែងសម្តែងធម៌ទេសនា អ្នកដទៃគេតាំងចិត្តស្តាប់ តែយើងគិត តែជជែកធ្វើឲ្យអ្នកដទៃរំខានត្រចៀក ។ យើងប្រកបអាជីព ឬជួសជុលអ្វីដែលនាំឲ្យមានសំឡេងរំខានដល់អ្នកជិតខាង ធ្វើឲ្យគេក្តៅក្រហាយចិត្ត ដូចនេះយើងត្រូវក្រែងចិត្ត ត្រូវប្រាប់គេខ្លះផង យកចិត្តគេផង បើនឹងត្រូវធ្វើយូរ ក៏ត្រូវក្រែងចិត្តគេឲ្យខ្លាំង យ៉ាងនេះនឹងមិនមានរឿងអ្វីច្រើនទៅនោះទេ ។*

*កូនកុំគិតបែបអ្នកលេងថា "មានរឿងក៏មាន" ការគិតបែបនេះ ជាការគិតរបស់មនុស្សឃើញតែពីបាន គិតតែពីខ្លួនឯងមិនគិតដល់ចិត្តថ្លើមអ្នកដទៃផង ។ ចូរកូនកុំគិតយ៉ាងនេះឡើយ វាជារឿងដែលគួរឲ្យអៀនខ្មាសណាស់ ។*

*បុថុជ្ជននៅល្ងង់លង់ក្នុងកិលេស ដូច្នេះចូរប្រឹងកុំខឹងពាសវាល*
*សេពគប់បណ្ឌិតពិតកុំរយាល កុំខ្ជិលដេកទ្រាលកុំអួតខ្លួនឯង។*
*មើលចុះភ្នំធំក៏គង់រលាយ ទឹកបឹងទាំងឡាយហួតដោយសូរ្យសែង*
*ខ្លួនយើងតូចម៉្លឹងត្រូវប្រឹងកោតក្រែង កុំលើកខ្លួនឯងត្រូវក្រែងចេះគេ។*

-

*ទោះបីទ្រង់គ្រឿងរុងរឿងដោយយស ដើរអួតឫកខ្ពស់យសសូន្យទទេ*
*ទ្រង់ចិត្តដោយធម៌កាយមិនទំនេរ មកុដសីលលើសិរគេឯងបានសុខ។*

-

## ១៥-ប្រយ័ត្នពាក្យផ្អែម

*កូនជាទីស្រឡាញ់*

*កូនគួរប្រយ័ត្នពាក្យនិយាយរបស់អ្នកដទៃ ដោយចំពោះពាក្យផ្អែមល្ហែម ។ ទឹកអំពៅ ទឹកត្នោតដែលមានរសផ្អែម កាលបើទុកយូរទៅ ហើយត្រូវផ្សំនឹងមេផងក៏ ក្លាយទៅជាទឹក ស្រវឹងយ៉ាងណាមិញ ពាក្យសម្ដីផ្អែមល្ហែមរបស់មនុស្សខ្លះ ក៏អាចធ្វើឲ្យយើងស្រវឹងបានយ៉ាងនោះដែរ ។ កាលបើស្រវឹងហើយ ក៏ធ្វើឲ្យវង្វេងភ្លេចខ្លួន បាត់បង់ស្មារតី ខូចប្រក្រតីដែលធ្លាប់តែរាបសាបហូតដល់មានពេលខ្លះត្រូវអស់មាសអស់ប្រាក់ទៀតផង ព្រោះជឿពាក្យផ្អែមល្ហែមរបស់គេ ។*

*ចូរកូនពិចារណាឲ្យបានល្អ អ្នកណាៗមកនិយាយផ្អែមល្ហែម លើកតម្កើងកូនថា កូនល្អយ៉ាងនេះ ពូកែយ៉ាងនោះ កូនត្រូវតែប្រយ័ត្នឲ្យមែនទែន កុំប្រញាប់ស៊ីជោររីករាយសប្បាយភ្លេចខ្លួនឲ្យសោះ បើកូនមិនស្រវឹងនឹងពាក្យផ្អែមល្ហែមរបស់អ្នក ដទៃទេ កូននឹងមិនក្ដៅក្រហាយស្ដាយក្រោយឡើយ ។*

*ត្រីដែលស្លាប់ទៅហើយ មួយចំណែកនោះ ព្រោះត្រូវគេបញ្ឆោតដោយនុយ ដោយលំនៅឋានជាដើម បើវាមិនទាក់ចិត្តជាប់នឹងគ្រឿងបញ្ឆោតទេ វាក៏មិនស្លាប់ដែរ ក្នុងរឿងនេះកូនត្រូវតែចេះប្រយ័ត្ននឹងអ្វីៗគ្រប់យ៉ាង មិនចំពោះតែពាក្យសម្ដីផ្អែមល្ហែមរបស់*

-

អ្នកដទៃប៉ុណ្ណោះឡើយ ពោលគឺប្រយ័ត្នចំពោះគ្រឿងបោកបញ្ឆោតក្នុងលោក កុំឲ្យស្លាប់ដូចត្រីដែលចាប់នុយនោះ ។

កូនអើយ ប្រយ័ត្នគឺជាស្មារតី ប្រយ័ត្ននឹងអ្វីគឺល្អ ទាំងអស់ កូនត្រូវចាំពាក្យក្នុងសៀវភៅកូនមាសឪពុកថា :

ភ្លេចអ្វីភ្លេចបាន តែបើភ្លេចប្រាណ ឈានធ្លាក់រណ្ដៅ
បើបានជាភ្លាត់ មិនទាន់ធ្លាក់ជ្រៅ ប្រឹងឡើងណាពៅ
កុំនៅនាំជ្រុល ។

ខូចអ្វីមិនគ្រោះ តែបើខូចឈ្មោះ មិនងាយជួសជុល
កូនត្រូវប្រយ័ត្ន កុំងប់ងុល កាមជាគ្រឿងពុល
ខូចអស់ទាំងខ្លួន ។

ខូចខ្លួនខូចឈ្មោះ ខូចនេះពេញគ្រោះ រស់លែងសិប់សួន
តែទោះយ៉ាងណា កុំឲ្យខូចខ្លួន ត្រូវប្រឹងកែខ្លួន
កុំចោលអាត្មា ។

ចោលអ្វីចោលបាន តែកុំចោលប្រាណ ក្នុងវដ្ដសង្សារ
ព្រោះតែលោកនេះ ឥតមាននរណា ជួយស្រង់អាត្មា
ក្រៅពីខ្លួនឡើយ ។

កូនត្រូវរក្សា ការពារអាត្មា ឲ្យបានដលៈត្រើយ
ដោយការប្រយ័ត្ន និងមិនកន្តើយ ប្រយ័ត្នហ្នឹងហើយ
ជាព្រះក្នុងខ្លួន ។

ប្រយ័ត្នជាម្ដាយ ញ៉ាំងគុណទាំងឡាយ ឲ្យកើតមាំមួន
អត់ធន់ជាឪ រក្សាគ្រងស្ងួន គុណធម៌ក្នុងខ្លួន
ដូចខែខាងខ្នើត ។

ខន្តីដូចថ្នាំ លេបជាប្រចាំ រសជាតិល្វីងធើត
លំបាកទ្រាំណាស់ លុះដល់ផលកើត រសជាតិល្វីងធើត
មានគុណគាប់ហោង ។

## ១៦-សរសើរនិន្ទាជាខ្យល់មាត់

កូនជាទីស្រឡាញ់

ពេលមានអ្នកជេរមកនិន្ទា ឬសរសើរកូន កូនត្រូវតាំងសតិឲ្យល្អ កុំបណ្ដោយទៅតាមខ្យល់មាត់របស់គេជា ដាច់ខាត ។ កូនត្រូវគិតមើល តើពាក្យសរសើរ ឬនិន្ទា នោះ ពិតឬយ៉ាងណា អាក្រក់តាមគេថាដែរឬទេ បើថាពិតយ៉ាងនោះមែន ក៏មិនគួរខឹងក្រោធនឹងគេ បើថាមិនពិតទេ គ្រាន់តែកូនគិតថា គេមិនស្គាល់ ឬមិនដឹងរឿង របស់កូនតាមពិតប៉ុណ្ណឹងទៅ ដូច្នេះរឿងរ៉ាវក៏មិនរាលដាលទៅធំដុំអ្វីឡើយ ។ ម្យ៉ាងទៀត បើថាកូនល្អតាមការសរសើររបស់គេមែន ក៏បញ្ជាក់ថាគេដឹងរឿងរបស់កូន តាមពិតគ្រាន់តែប៉ុណ្ណឹងឯង តែបើមិនល្អដូចគេសរសើរទេ កូនក៏មិនគួររីករាយសប្បាយចិត្ត ព្រមទទួលយកអ្វីដែលមិនមែនជាការពិតនោះដែរ ។ បើគិតបាន ធ្វើចិត្តបានដូច ពោលមកនេះ ក៏រមែងមិនមានអាការឡើងចុះនៃចិត្តទៅតាមពាក្យនិន្ទា និងពាក្យសរសើរដែរ ។

និន្ទា ឬសរសើរគ្រាន់តែជាខ្យល់មាត់របស់មនុស្ស ដែលបក់ផាត់មកដល់ហើយក៏ហួសទៅ វាមិនអាចធ្វើឲ្យ យើងល្អឬអាក្រក់បានឡើយ ។ អ្នកណាវង្វេងទៅជាមួយពាក្យសរសើរ ឬនិន្ទា អ្នកនោះនឹងកើតរោគសរសៃប្រសាទ ឬរហូតដល់វិកលចរិតជាពិតប្រាកដពុំខាន ។

-

នៅពេលគេដើរហាលថ្ងៃ គេថាថ្ងៃក្ដៅអាក្រក់ណាស់ លុះដល់គេហាលអុសឬសំពត់អាវ គេថាថ្ងៃក្ដៅល្អ មានអ្វីផ្គាប់ចិត្តមនុស្សលោក ត្រូវគ្រប់យ៉ាងនិងគ្រប់គ្នាទៅ ។ កូនត្រូវចាំពាក្យក្នុងសៀវភៅម៉ែ! ! ! :

ព្រះចន្ទនិងថ្ងៃឥតមានដឹងអ្វី
ពពករសាត់ដូចមានស្លាបហើរ
បួសជាព្រះសង្ឃនៅគេរិះគន់
ត្រាស់ជាព្រះពុទ្ធនៅគេមិនស្មោះ
សរសើរនិន្ទាមានពីបុរាណ
បើកូនតាមប្រាជ្ញាកូននឹងមានកព្វ

តែត្រូវប្រុសស្រីនិន្ទាសរសើរ
ភ្លៀងខ្យល់ដេកដើរគេថាទាំងអស់ ។
ធ្វើចោរលួចប្លន់គេទាន់ដាក់ខ្នោះ
ធម៌ល្អឥតខ្ចោះគង់មានគេស្អប់ ។
កាន់យកមិនបានតាមពាក្យទាស់គាប់
ត្រូវមួយខុសជប់កុំយកខាងច្រើន ។

-

## ១៧-សម្លឹងមនុស្សល្អឬអាក្រក់

កូនជាទីស្រឡាញ់

ការដែលកូនលើកតម្កើង ឬព្រមទទួលអ្នកណា ថាជាមនុស្សល្អនោះ កូនត្រូវសម្លឹងមើលឲ្យបានសព្វគ្រប់ និង ឲ្យជាក់ច្បាស់ជាមុនសិន ។ កូនត្រូវសម្លឹងមើលឲ្យបានយូរខែ យូរឆ្នាំ កុំគិតតែចំពោះមុខកូនប៉ុណ្ណោះ ។ គេអាចល្អចំពោះកូន គឺគេជួយកូន គេនិយាយល្អរកកូនជាដើម ម្ល៉ោះហើយកូនមិនបានមើលឲ្យសព្វគ្រប់ កូនក៏គិតថា គេជាមនុស្សល្អអីចឹងទៅ ។ តាមពិត មនុស្សដែលល្អចំពោះកូន មិនទាន់ប្រាកដថា គេជាមនុស្សល្អពិតៗនោះទេ ព្រោះគេ អាចសម្លឹងអ្វីពីកូន ឬកូនអាចធ្វើនូវអ្វីដែលគេត្រូវការឲ្យគេបាន ឬយ៉ាងហោចព្រោះកូនមិនបានទៅជំទាស់នូវផលប្រយោជន៍អ្វីរបស់គេ ទើបគេធ្វើល្អនឹងកូនទៅ ។ ពុំនោះសោតទេ គឺព្រោះកូនជាប្ដីជាប្រពន្ធ ឬជាបងប្អូនជាមួយនឹងគេ ។

មនុស្សដែលល្អពិតៗនោះ គឺល្អចំពោះកូនផង ល្អចំពោះអ្នកដទៃផង ។

មានទំនងដូចគ្នាដែរ ដែលគេធ្វើល្អចំពោះអ្នកដទៃ តែមិនបានធ្វើល្អចំពោះមកលើកូន គឺមិនមែនបានសេចក្ដីថា គេជាមនុស្សមិនល្អនោះទេ ។ មនុស្សដែលមិនល្អនោះ គឺត្រូវមិនល្អទាំងចំពោះកូនផង ទាំងចំពោះអ្នកដទៃផង ។

-

ដែលម៉ែឪលើកយករឿងនេះមកប្រាប់ដល់កូន ក៏ដើម្បីកូនដឹងទុកតទៅមុខ នឹងមិនបានជឿគេងាយៗ មិនត្រូវបានគេបោកបញ្ឆោត ម្យ៉ាងទៀត កូននឹងមិនបានពោលរកអ្នកដទៃណាៗ ថាគេជាមនុស្សល្អឬមិនល្អដោយងាយៗនោះឡើយ គឺម៉ែឪមិនចង់ឲ្យកូនសម្លឹងមើលមនុស្សក្នុងផ្នែកល្អ ឬផ្នែកអាក្រក់ ដោយចំណែកតែម្ខាងៗនោះឯង ។

✍📖✍

-

## ១៨-ថ្នាំរក្សាចិត្ត

កូនជាទីស្រឡាញ់

ដែលឈ្មោះថាជាទុក្ខហើយ គឺមិនមានអ្នកណា ប្រាថ្នាឡើយ ប៉ុន្តែគ្រប់គ្នាក៏រមែងមានទុក្ខជាប់តាម មានទុក្ខខ្លាំង មានទុក្ខតិច ចេះតែមានជាធម្មតា ទាំងដែលគ្រប់ គ្នាមិនប្រាថ្នានោះឯង ។

ទុក្ខមាន ២ យ៉ាងគឺ ទុក្ខផ្លូវកាយ និងទុក្ខផ្លូវចិត្ត ។ ទុក្ខផ្លូវកាយរម្ងាប់បានដោយអាហារ គ្រឿងស្លៀកពាក់ ទីនៅអាស្រ័យ និងថ្នាំកែរោគ ឯទុក្ខផ្លូវចិត្តវិញត្រូវរក្សាដោយ ព្រះធម៌ ។

ព្រះធម៌ជាថ្នាំកែរោគផ្លូវចិត្ត ជាថ្នាំកម្លាំងជំនួយឲ្យចិត្តមានកម្លាំង មានសុខភាពល្អ និងជាទីពឹងផ្លូវចិត្ត ។ មនុស្សយើងកាលដែលមានរោគផ្លូវកាយបានអាហារបាន ថ្នាំជាដើមមកបរិភោគ ថែរក្សា ក៏ស្ងប់រម្ងាប់ទៅនូវរោគផ្លូវកាយនោះ ឯចំណែករោគផ្លូវចិត្តវិញ គឺចាំបាច់ត្រូវតែយក ព្រះធម៌មកថែរក្សាទើបៗន សេចក្តីនេះកូនត្រូវតែយល់ឲ្យបានច្បាស់ ។

មនុស្សណាដែលមិនឃើញការពិតដូច្នេះ មនុស្ស នោះនៅពេលមានទុក្ខផ្លូវចិត្តកើតឡើង ក៏រមែងជាទុក្ខ ដោយប្រាសចាកទីពឹង សោកសៅ ពោលរៀបរាប់ ឬក៏ស្រែកឡូឡាបន្ទោសនេះបន្ទោសនោះ ។

-

ចំណែកមនុស្សដែលមានបញ្ញា ដឹងទុក្ខផ្លូវចិត្តថា ជារោគរមែងស្តាប់ធម៌ រៀនធម៌ ពិចារណាធម៌ និង បដិបត្តិតាមធម៌ ដើម្បីរក្សារោគចិត្តឲ្យដូចជាការរក្សារោគផ្លូវកាយដែរ ម៉្លោះហើយក៏ជាអ្នកមានព្រះធម៌ជាទីពឹង សូម្បីជួបប្រទះជាមួយនឹងទុក្ខ ក៏អាចកម្ចាត់ទុក្ខក្នុងចិត្តបាន និងអាចរកសេចក្តីសុខបានក្នុងជីវិត ដែលជាសុខប្រាសចាកទោសទៀតផង ។

ការព្យាបាលរោគផ្លូវកាយមិនរើសវ័យ ថាក្មេង ឬចាស់ឡើយ ឲ្យតែមានជំងឺគឺត្រូវតែព្យាបាល យ៉ាងណាការរក្សាចិត្តដោយព្រះធម៌ក៏យ៉ាងនោះដែរ ។

មនុស្សយើងមាន លោភៈ ទោសៈ និងមោហៈ ជារោគប្រចាំចិត្តនាំឲ្យប្រព្រឹត្តបាប ដូច្នេះកូនត្រូវតែមាននូវថ្នាំ គឺព្រះធម៌ឲ្យជាប្រចាំផងដែរ ទោះជាកូនឋិតនៅក្នុងវ័យណាក៏ដោយ ។ កូនត្រូវតែរក្សាចិត្តឲ្យជាប្រចាំ រហូតទាល់តែជាសះស្បើយ អស់ទុក្ខអស់កង្វល់ពីសន្តាន ។ ចូរកូនហ្វឹកហាត់ ឲ្យមានការយល់ដឹងច្បាស់ពីព្រះធម៌ ទីបំផុតកូននឹងដឹងថា ព្រះធម៌នោះល្អយ៉ាងណា ។

ចូរកូនពិចារណានូវកំណាព្យនេះ :

រូបសល្អរាងគួរស្រឡាញ់ តែចាញ់ល្អចិត្តគំនិតជា
មិនយូរប៉ុន្មានរូបជរា ឯចិត្តល្អជាមិនចាស់ឡើយ ។
ចូរកូនប្រុសស្រីកុំបំភ្លេច ធម៌ថ្លៃជាងពេជ្រនាំដល់ត្រើយ

-

មានរូបមានរោគឥតស្រាកស្បើយ កូនអើយព្រះធម៌មិនចេះឈឺ។
បើកូនរៀនធម៌អប់រំចិត្ត ប្រព្រឹត្តសុចរិតចិត្តកូនភ្លឺ
ជីវិតត្រូវស្លាប់រូបត្រូវឈឺ ប៉ុន្តែចិត្តភ្លឺមិនស្លាប់ទេ ។

-

## ១៩-ការគ្រប់គ្រងចិត្តមនុស្ស

កូនជាទីស្រឡាញ់

ចៅហ្វាយនាយដែលមានចិត្តល្អ មានយុត្តិធម៌ ចេះយល់ចិត្តយល់ថ្លើម និងជាគ្នាឯងជាមួយកូនចៅ មិនយកប្រៀប មិនសង្កត់សង្កិនបៀតបៀនកូនចៅ រមែងធ្វើឲ្យកូន ចៅកក់ក្ដៅក្នុងចិត្ត និងឲ្យនូវសេចក្ដីគោរពកោតក្រែង ទាំងទីចំពោះមុខ ទាំងទីកំបាំងមុខត្រឡប់មកចៅហ្វាយវិញ ព្រមទាំងចងចាំទុកក្នុងចិត្តនូវគុណធម៌ទាំងឡាយ រហូតអស់ជីវិតនៃពួកគេទៀតផង ។ បើកូនមានឱកាសបានធ្វើ ជាចៅហ្វាយនាយគេ ឬជាអ្នកបង្គាប់បញ្ជាគេ កូនត្រូវកុំភ្លេចពាក្យម៉ែពាក្យឪត្រង់សេចក្ដីនេះឲ្យសោះ នេះបើកូន ប្រាថ្នាឲ្យកូនចៅ ដែលនៅក្រោមបង្គាប់របស់កូនស្រឡាញ់ កក់ក្ដៅក្នុងចិត្ត និងគោរពស្រឡាញ់ដោយស្មោះនោះ ។

កូនធ្វើឲ្យអ្នកនៅក្រោមឱវាទរបស់កូន ស្រឡាញ់ពេញចិត្តគោរពស្ម័គ្រស្មោះ នេះជាការប្រសើរណាស់ ឯការធ្វើឲ្យគេគ្រាន់តែខ្លាច តែមិនគោរពកោតក្រែងនោះ មិនប្រសើរឡើយ ។

អ្នកគ្រប់គ្រងគេ កាលបើប្រើតែព្រះតេជច្រើនជាងព្រះគុណ រមែងមានតែមនុស្សចេះខ្លាច ប៉ុន្តែមិនកក់ក្ដៅ ក្នុងចិត្ត និងមិនស្រឡាញ់ស្ម័គ្រស្មោះឡើយ ។ ចំណែកអ្នកដែលប្រើព្រះគុណច្រើនជាងព្រះតេជ មនុស្សទាំងឡាយរមែងខ្លាចផង

-

ក្រែងផង គោរពដោយស្មោះផងនិងកក់ក្ដៅ ក្នុងចិត្តផង យ៉ាងនេះ ហៅថា អ្នកគ្រប់គ្រងគេបានទាំងកាយទាំងចិត្ត ។

អ្នកធំដែលប្រាថ្នានឹងគ្រប់គ្រងចិត្តមនុស្ស ដោយប្រើអំណាចបង្គាប់បញ្ជា ដើម្បីធ្វើឲ្យគេកោតខ្លាចនោះ គឺជាការយល់ខុសដោយពិត ។ អំណាចពិតប្រាកដ កើតអំពីការសាងនូវភាពកក់ក្ដៅឲ្យដល់កូនចៅជាសំខាន់ ។ ភាពកក់ក្ដៅ ដែលបង្កប់ទៅដោយមនោសញ្ចេតនាស្និទ្ធស្នាល គោរពស្រឡាញ់ ហើយដក់ជាប់ក្នុងក្រអៅបេះដូង រមែងកើតពីការឲ្យ ការអើពើ និងការយកចិត្តទុកដាក់ ដូចជាការឲ្យប្រាក់ ឲ្យរបស់របរប្រើប្រាស់ ឲ្យកម្លាំងចិត្ត ឲ្យភាពជាគ្នាឯង ឲ្យពាក្យណែនាំដែលល្អៗ ឲ្យពាក្យពីរោះមានប្រយោជន៍ ឲ្យអភ័យ ឲ្យភាពកក់ក្ដៅបីដូចជាឪពុកម្ដាយ រួមទាំងការឲ្យនូវកិត្តិយស ឲ្យភាពខ្ពង់ខ្ពស់ហាក់ដូចជាតាំងនៅក្នុងឋានៈស្មើគ្នាទៀតផង ប៉ុណ្ណោះជាដើម ។

បើកូនត្រូវការនឹងគ្រប់គ្រងចិត្តមនុស្ស កូនត្រូវចេះសង្គ្រោះ ចេះឲ្យនូវអ្វីៗដោយក្ដីមេត្តា ករុណា ហើយត្រូវឲ្យជារឿយៗទៀតផង ។

## ២០-ការទទួលខុសត្រូវ

កូនជាទីស្រឡាញ់

កាលកូនធ្វើការងារជារបស់ខ្លួនឯង ឬកាលបានទទួលនូវការងារដែលអ្នកដទៃប្រគល់ឲ្យធ្វើ ចំណុចសំខាន់ដែលកូនត្រូវយកចិត្តទុកដាក់ខ្លាំងបំផុត គឺការទទួលខុសត្រូវ ។

ការទទួលខុសត្រូវគឺ ការដែលមាននូវការតាំងចិត្តមានភាពប្រាកដក្នុងចិត្តដើម្បីនឹងធ្វើនូវការនោះៗ ដើម្បីឲ្យការងារទាំងនោះសម្រេចទៅដោយរៀបរយល្អ និងទាន់តាមពេលដែលបានកំណត់ទុក ។

អ្នកទទួលខុសត្រូវក្នុងការងារ មិនចាំបាច់ឲ្យអ្នកណាមករំលឹកដាស់តឿន មកបន្ទំជារឿយៗនោះឡើយ រមែងជាអ្នកដាស់តឿនខ្លួនឯងជានិច្ច មានស្មារតីដឹងថា នេះជាការងារដែលខ្លួនត្រូវធ្វើ ។ មនុស្សដែលចេះទទួល ខុសត្រូវក្នុងការងារ គឺជាមនុស្សដែលពួកគណៈត្រូវការ ហើយប្រទេសជាតិក៏ត្រូវការដែរ ។ មនុស្សចេះទទួលខុសត្រូវរមែងចម្រើនក្នុងការងារ ជីវិតឈានទៅរកភាពរុងរឿងប្រសើរឡើងៗ ផ្ទុយពីមនុស្សដែលខ្វះស្មារតី ទទួលខុសត្រូវ ។

មនុស្សដែលខ្វះស្មារតីទទួលខុសត្រូវ រមែងឡេះឡោះក្នុងការងាររបស់ខ្លួន មិនគោរពតួនាទីរបស់ខ្លួន ធ្វើការងារអ្វីៗ

បែបមិនពេញចិត្ត រើសអើងក្នុងការងារ ចង់តែស្រណុកស្រួល ចង់បានតែប្រាក់ ចង់តែបញ្ជាគេ ។ល។

កូនយល់ដឹងក្នុងរឿងនេះហើយ កូនត្រូវហ្វឹកហាត់ឲ្យជាមនុស្សចេះទទួលខុសត្រូវ ។ វិធីហ្វឹកហាត់មិនជា លំបាកប៉ុន្មានទេ គឺផ្តើមដោយការដាស់តឿនខ្លួនឯងបានជាមុន ។ ដាស់តឿនខ្លួនឯងថា នេះជាតួនាទីរបស់យើង ជាការងាររបស់យើង ជារឿងរបស់យើង ដែលខ្លួនយើងនឹងត្រូវចាត់ចែងធ្វើ ។ លុះដល់ពេលចុះដៃធ្វើកូនត្រូវ ព្យាយាមធ្វើឲ្យល្អជាទីបំផុត ធ្វើឲ្យពេញសមត្ថភាព ដែល មានបញ្ចេញកម្លាំង បញ្ចេញការចេះដឹងឲ្យពេញទី ឯផលដែលត្រូវទទួលបានក៏នឹងកើតឡើងដល់ខ្លួនឯង គឺកូននឹងបានទទួលផលដោយត្រង់ ។

ការដាស់តឿនខ្លួនឯងជានិច្ចកាល រមែងធ្វើឲ្យភាពនៃការទទួលខុសត្រូវ សន្សឹមៗកើតឡើងដល់កូន លុះដល់យូរទៅ កូនក៏នឹងក្លាយទៅជាអ្នកចេះទទួលខុសត្រូវម្នាក់ដ៏ប្រសើរ ។

កូនសម្លាញ់ ទ្រព្យសម្បត្តិមិនមែនជារបស់ចាំបាច់ ក្នុងការដែលឪពុកម្តាយត្រូវប្រគល់ឲ្យដល់កូននោះទេ ។ ចំណេះដឹង និងការប្រព្រឹត្តល្អ ព្រមទាំងការចេះទទួលខុសត្រូវតែប៉ុណ្ណោះ ដែលគួរជាទីបំផុតក្នុងការដែលម៉ែឪត្រូវប្រគល់ឲ្យដល់កូនសម្លាញ់ ។

## ២១-ឱកាសមាស

កូនជាទីស្រឡាញ់

មនុស្សខ្លះមានអំណាច មានវាសនាបារមីខ្លាំងក្លា មានឱកាសបានទៅអង្គុយក្នុងស្ថានទីខ្ពស់ ដែលល្មមនឹងធ្វើអ្វីជាប្រយោជន៍ ឲ្យមានការចម្រើនដល់សង្គម និង ប្រទេសជាតិបាន ប៉ុន្តែបែរជាមិនបានធ្វើទៅវិញ ធ្វើឲ្យខូច នូវឱកាសមាសដ៏យ៉ាងគួរឲ្យស្តាយ ។ ដែលគាត់មិនបាន ធ្វើមុខតែមកអំពីគាត់មិនបានគិតពិចារណាដល់ឱកាស មាសពិតប្រាកដ គិតបានត្រឹមតែថា តំណែងនាទីដែលខ្លួនបានទទួលនេះ ជាកិត្តិយសកេរ្តិ៍ឈ្មោះចំពោះខ្លួន និងជាផ្លូវ នៃការបានមកនូវលាភផ្ទាល់ខ្លួនប៉ុណ្ណោះ ម៉្លោះហើយគាត់ ក៏សំដៅទៅរកតែការរក្សាកិត្តិយស និងប្រយោជន៍របស់គាត់តែម្យ៉ាងទៅ ។ តាមការពិត ប្រសិនបើគាត់ប្រើប្រាស់ឱកាសមាសក្នុងខណៈនោះ សាងនូវរបស់ល្អ ស្នាដៃល្អឲ្យដល់ប្រទេសជាតិ និងទុកជាទីរលឹកក្នុងជីវិត នោះឯងគឺជា កិត្តិយសនិងប្រយោជន៍សំខាន់ផ្ទាល់ខ្លួនគាត់ រហូតអស់កាលជាអង្វែង សូម្បីចេញចាកតំណែងនោះទៅហើយក៏ដោយ មនុស្សទាំងឡាយគេនៅតែពោលដល់គាត់ដោយការលើកតម្កើង ។

សម្រាប់ខ្លួនកូនវិញ បើមានឱកាសបានឡើងទៅ កាន់ឋានៈខ្ពង់ខ្ពស់យ៉ាងណាមួយនោះ គឺកុំភ្លេចខ្លួនឲ្យសោះ កូនត្រូវប្រើឱកាស

មាសនោះ សាងនូវប្រយោជន៍ សាងនូវអ្វីដែលជាទីរលឹកឲ្យដល់មនុស្សជាតិ ដើម្បីទុកជាស្នាដៃ ដែលអ្នកដទៃក្នុងសង្គមជាតិ អាចទទួលយកបានដោយក្ដីរំភើបរីករាយ ។

កូនត្រូវគិតជានិច្ច បើកូនមានបុណ្យបាននូវឋានៈខ្ពស់មែននោះ កូនត្រូវតាំងចិត្តធ្វើឲ្យសម្រេចតាមដូចដែល ម៉ែឪបានផ្ដាំ បើមិនយ៉ាងនោះទេ ឋានៈតំណែងនោះ នឹង ធ្វើឲ្យកូនខូចឱកាសមាស និងអាចធ្វើឲ្យខូចខ្លួនកូនដោយ មិនដឹងខ្លួនទេឲ្យតផង ។

-

## ២២-កុំត្រចៀកស្រាល

កូនជាទីស្រឡាញ់

ក្នុងពេលសន្ទនាគ្នានោះ រមែងគេចមិនផុតពីការលើកយកបុគ្គលនេះ បុគ្គលនោះមកនិន្ទា ឬពិចារណាថាយ៉ាងនេះយ៉ាងនោះឡើយ ។ កូនត្រូវហាត់ធ្វើចិត្តឲ្យធ្ងន់ក្នុងរឿងនេះ ព្រមទាំងឲ្យធ្ងន់ត្រចៀកផង ពោលគឺកុំជាមនុស្សត្រចៀកស្រាល ជឿពាក្យនិយាយរបស់អ្នកណាៗដោយងាយៗនោះ ។ ដោយចំពោះយ៉ាងសំខាន់ បើកូនជាអ្នកធំ ជាអ្នកបង្គាប់បញ្ជា ជាអ្នកដឹកនាំ ឬក៏ជាមេគ្រួសារ កូនត្រូវតែប្រយ័ត្នឲ្យណាស់ ព្រោះមានមនុស្សខ្លះនិយាយ ដោយមិនទទួលខុសត្រូវ និយាយទៅតាមតែចិត្តដែលចង់និយាយ មិនគិតដល់ផលដែលប៉ះពាល់ទៅលើអ្នកដទៃ ថាតើអ្នកដទៃក្ដៅក្រហាយ ឬខូចកេរ្តិ៍ឈ្មោះយ៉ាងណា ។ អ្នកខ្លះនិយាយព្រោះស្រួលមាត់ ចង់ឃើញអ្នកស្ដាប់យកចិត្តទុកដាក់នឹងស្ដាប់ ឬក៏ភ្ញាក់ផ្អើលទៅតាមពាក្យនិយាយរបស់ខ្លួន ។ អ្នកខ្លះនិយាយព្រោះត្រូវការឲ្យគេបែកបាក់គ្នា ខ្លះទៀតនិយាយព្រោះចង់សង្កត់សង្កិនគេ ។ល។ មានសព្វ មានគ្រប់រឿងរ៉ាវក្នុងពាក្យសម្ដីអ្នកនិយាយ ។

កូនស្ដាប់មនុស្សទាំងឡាយនិយាយហើយ កូនត្រូវថ្លឹងថ្លែងឲ្យល្អ កុំប្រញាប់ជឿ ត្រូវទុកពាក្យសម្ដីអ្នកដទៃនឹង

-

ត្រចៀកសិនចុះ កុំទាន់យកមកប្រើការ ត្រូវពិសោធ ត្រូវពិចារណាឲ្យបានសព្វគ្រប់ ដូច្នេះកូននឹងមិនបានខូចចិត្ត មិនបានក្តៅក្រហាយក្នុងកាលជាខាងក្រោយឡើយ ។

មនុស្សត្រចៀកស្រាលឆាប់ជឿគេពេក រមែងធ្វើឲ្យខ្លួនឯងក្តៅក្រហាយស្តាយក្រោយ ខូចកេរ្តិ៍ខូចឈ្មោះ មិនជាទីរាប់អានរបស់អ្នកដទៃ បែបនេះមានច្រើននាក់ណាស់មកហើយ ។ ម្យ៉ាងទៀតមនុស្សត្រចៀកស្រាលនោះរមែង ធ្វើឲ្យភរិយាស្វាមីខ្លួនឯងលែងលះគ្នា បែកផ្លូវគ្នាដើរ ធ្វើឲ្យគ្រួសារដួលរលំ នៅមិនជាសុខ ពុំនោះទេ ត្រូវសង្ស័យគ្នាឬត្រូវក្រំចិត្ត ។ល។ បែបនេះក៏មានច្រើនមកហើយដែរ ដូច្នេះកូនត្រូវប្រយ័ត្នខ្លួនទុកជាមុនទើបជាការល្អ ។

## ២៣-ការប្រើមនុស្ស

កូនជាទីស្រឡាញ់

ការប្រគល់កិច្ចការឲ្យមនុស្សទៅធ្វើ ដែលជាទូទៅ គេតែងនិយាយថា “ប្រើមនុស្ស” នោះ គឺត្រូវមើលឲ្យល្អជាទីបំផុត ត្រូវមើលទាំងមនុស្ស ត្រូវមើលទាំងការងារ ពោលគឺត្រូវប្រើមនុស្ស ឲ្យសមជាមួយនឹងការងារ អ្នកណាជំនាញខាងអ្វី ធ្លាប់មានពិសោធន៍យ៉ាងណា ធ្លាប់ជួបប្រសព្វហេតុការណ៍យ៉ាងម៉េចរួមទាំងការចេះដឹងនិងការទទួលខុសត្រូវផង ។ កាលបើប្រើមនុស្សបានសមប្រកបនឹងការងារ ក៏នឹងធ្វើឲ្យការងារដើរទៅមុខមិនមានសួះ ។

ប្រសិនបើប្រើមនុស្សខុស មិនត្រូវគ្នានឹងការងារទេនោះ ឬប្រើមនុស្សដែលខ្វះនូវគុណសម្បត្តិ ប្រើព្រោះយល់មុខគ្នា ឬប្រើដោយមិនពិចារណាឲ្យល្អិតល្អន់ ក្រៅអំពីធ្វើឲ្យការងារមិនដើរមិនចម្រើនហើយ នៅអាចធ្វើឲ្យកើតសេចក្តីអន្តរាយទៀតផង ។

មានតួយ៉ាងជាឧទាហរណ៍ឲ្យឃើញមិនតិចទេដែល អ្នកជំជ្រើសរើសប្រើមនុស្សមិនឲ្យសមនឹងការងារ ធ្វើឲ្យការងារនោះៗមិនមានដំណើរការ ។ កន្លែងខ្លះប្រើមនុស្ស ដែលជាបក្សពួក ឬប្រើមនុស្សដែលនៅជាមួយ ជាមនុស្សដែលខ្វះនូវគុណសម្បត្តិ

-

-

ឲ្យទៅធ្វើ នាំឲ្យខូចការងារនោះៗ មានការងារខ្លះជាការងាររបស់ប្រទេសជាតិទៀតផង ។

ដូចពោលមកនេះ កាលបើកូននឹងប្រើអ្នកណា នឹងប្រគល់កិច្ចការឲ្យទៅអ្នកណាធ្វើ កូនត្រូវពិចារណាឲ្យល្អ ។ អ្នកណាក៏ដោយ ទោះបីគេមិនមែនជាបក្សពួករបស់កូន ឬគេមានការចេះដឹងមិនសូវច្រើនមែន តែគេធ្លាប់មានពិសោធន៍ ទាំងធ្លាប់បានជួបប្រសព្វនូវហេតុការណ៍ ទាំងមាននូវការទទួលខុសត្រូវផងនោះ គឺគេអាចធ្វើឲ្យការងារ របស់កូនសម្រេចទៅបានដោយល្អ អ្នកនោះកូនគួរប្រើគេល្អជាងប្រើបក្សពួកគ្នាឯងដែលមិនបានការ ។

កូនមិនត្រូវយកការងារមកប្រមាទទេ ពោលគឺមិនត្រូវប្រមាទធ្វេសប្រហែសក្នុងការងារឡើយ បើកូនមានការធ្វេសប្រហែសហើយ កូននឹងជួលរលំជាមួយនឹងការងារជាពុំខាន ។ មិនចាំបាច់ពោលដល់អ្នកដែលចេះស្ទើរនោះឡើយ សូម្បីអ្នកដែលចេះស្ទាត់ក្នុងការងារហើយក៏ដោយ ក៏ត្រូវជួលរលំដែរ ព្រោះតែប្រមាទធ្វេសប្រហែស ដូចជាមនុស្សល្ងង់ខ្លៅ ។

សរុបមក ជាមួយនឹងការងារ គឺកូនកុំប្រមាទធ្វេសប្រហែស កុំប្រថុយ កុំអាងថាមិនអី ត្រូវតែហ្មត់ចត់ និងប្រយ័ត្នប្រយែងជាទីបំផុត ។

-

## មនុស្សថ្លៃជាងប្រាក់

សុចរិតថ្លៃជាងពេជ្រ　　　កុំបំភ្លេចចោលខ្លួនប្រាណ
មនុស្សថ្លៃពន់ប្រមាណ　　　កុំចោលប្រាណដូរយកប្រាក់ៗ
ចោលប្រាណស្មើលក់ខ្លួន　　　ឪពោលផ្ដូនៀប្រចក្ស
មនុស្សយើងថ្លៃជាងប្រាក់　　　ត្រូវទុកដាក់ខ្លួនឲ្យល្អ ។

-

## ២៤-របៀបវិន័យ

កូនជាទីស្រឡាញ់

ផ្កាដែលគេរៀបដាក់ក្នុងថូជាដើម អ្នកណាឃើញក៏សរសើរថាស្អាតនោះ វាអាស្រ័យនៅលើអ្នករៀបចំ ចាត់ចែងឲ្យមានរបៀប ។ ផ្កាប្រភេទខ្លះសូម្បីមិនសូវស្អាត តែបើអ្នកតាក់តែងរៀបចំពូកែ ក៏អាចតាក់តែងឲ្យស្អាតបានដែរ ផ្ទុយមកវិញ សូម្បីផ្កានោះស្អាតយ៉ាងណាក៏ដោយ តែដល់មនុស្សមិនចេះរៀបចំទេ ក៏ធ្វើឲ្យទៅជាសំណុំបាច់ផ្កាធម្មតា មិនគួរឲ្យចង់គយគន់ឡើយ ។ របស់របរសម្រាប់ប្រើប្រាស់ក្នុងផ្ទះក៏មានន័យដូចគ្នាដែរ គឺពិតជាអាចធ្វើឲ្យផ្ទះស្អាតល្អទៅបាន បើម្ចាស់ផ្ទះចេះរៀបចំតាក់តែងនោះ។ មនុស្សយើងក៏ដូចគ្នា នឹងបានទៅជាមនុស្សដែលគួរឲ្យគយគន់ និងគួរឲ្យគោរពរាប់អាន ឬគោរពជ្រះថ្លា ក៏ព្រោះថា ម្ចាស់ខ្លួនចេះរៀបចំឲ្យមានរបៀបរៀបរយនោះឯង ។

មិនថាតែផ្កា ឬរបស់របរក្នុងផ្ទះឡើយ ជាពិសេសសំខាន់បំផុតគឺមនុស្សយើងហ្នឹងឯងហើយ ដែលទៅជាល្អស្អាតបាននោះ ព្រោះតែការចាត់ចែងឲ្យមានរបៀប ។ របៀបគឺជាសិល្បៈដែលមានការរៀបរយល្អស្អាត គួរឲ្យទស្សនា ។ ដូច្នេះមនុស្សយើងទើបគួរប្រព្រឹត្តឲ្យមានរបៀបវិន័យ ដើម្បីគ្រប់យ៉ាងបានល្អប្រពៃ ។

-

កូនអើយ ដុំឈើមួយដុំវាជាអន្ទត់អុសមែនហើយ បើគេមិនច្នៃវាទេនោះ ប៉ុន្តែដុំឈើមួយដុំនោះ វាទៅជារបស់មានតម្លៃកាលណាបើច្នៃល្អហើយ ។ រឹតតែល្អរឹតតែថ្លៃ ហើយបើច្នៃបើឆ្លាក់ឲ្យទៅជាព្រះពុទ្ធរូបនោះ អ្នកផងទាំងពួងគេថ្វាយបង្គំដោយពិត ។

កូនត្រូវតែយល់ ហើយកូនត្រូវតែអីចឹងឯង ទោះបីមានការខ្វះខាតអ្វីផ្សេងៗខ្លះ តែកូនកុំឲ្យខ្វះរបៀបវិន័យក្នុងខ្លួនឡើយ ។ ធ្វើអ្វីឲ្យមានរបៀប កុំអត់របៀបឲ្យសោះ ចាត់ចែងខ្លួនឯងឲ្យមានរបៀបរៀបរយ ចំពោះពេលវេលា ចំពោះការងារក្នុងជីវិតប្រចាំថ្ងៃ ហើយចំពោះជាពិសេសនោះ គឺចូលក្នុងសង្គមហ្នឹងឯង ។

នៅក្នុងសង្គមលោកយើងនេះ បើកូនជាមនុស្សប្រាសចាករបៀបវិន័យ កូននឹងជាមនុស្សដែលមានស្នេហ៍ ក្នុងក្រសែភ្នែកនៃអ្នកដទៃបានយ៉ាងដូចម្ដេចទៅ ។ ដូច្នេះ កូនត្រូវតែរៀន ត្រូវតែហ្វឹកហាត់នូវអ្វីៗដែលជាសេចក្ដីល្អគ្រប់យ៉ាង ដូចជាហ្វឹកហាត់ឲ្យខ្លួនមានរបៀបវិន័យនេះជាដើម នេះឯងជាការកសាងខ្លួន ។

ធ្វើល្អបានល្អបវរកោសិត     គុណធម៌ក្នុងចិត្តជីវិតឧត្តម
គុណធម៌ចម្រើនកើនព្រោះសន្សំ     ស្មារតីវិចិត្រខំកសាងអាត្មា ។
ថ្មភ្នំគល់ឈើដើរលើឥតក្រែង     លុះដល់តាក់តែងវិចិត្ររចនា
ឲ្យទៅជាព្រះពុទ្ធបដិមា     មនុស្សក្នុងលោកាគោរពវន្ទា ។

-

មនុស្សល្អធ្លាក់ខ្លួនដោយធម៌វិន័យ បដិបត្តិរាល់ថ្ងៃវិសេយអ្នកជាកាយវាចាចិត្តស្អិតស្អាងគ្រប់គ្រា បដិបត្តិបូជាគ្រប់គ្នាកុំប្រកើន ។

✍📖✍

-

## ២៥-ការចចេសរឹងរូស

កូនជាទីស្រឡាញ់

ក្នុងការនៅជាមួយគ្នា មិនថានៅរបៀបជាមិត្ត ឬជាកិរិយាស្វាមីឡើយ រមែងមាននូវរបស់មួយមកជ្រែកត្រង់កណ្តាលជានិច្ច របស់នោះគឺ "ការយល់ខុសគ្នា" ។ ជាប្តីប្រពន្ធនឹងគ្នាហើយយូរបន្តិចទៅច្រើនតែយល់ខុសគ្នាងាយៗ មិនថារឿងតូចឬរឿងធំឡើយ ហើយថែមទាំង ញឹកញាប់ជាងរឿងអ្វីទាំងអស់ទៀតផង ។ ចូរកុំភ្លេចថា ការយល់ខុសនេះ គឺមិនមែនមានត្រឹមតែយល់ខុសពីអ្នកដទៃនោះទេ វាមានការយល់ខុសពីការពិតផងទៀត ។

មនុស្សដែលមានការយល់ខុស ច្រើនតែមានភាពចចេសរឹងរូស មិនព្រមស្តាប់ពាក្យរបស់អ្នកដទៃ គិតថាខ្លួនត្រូវតែម្នាក់ឯង ថែមទាំងបន្ទោសអ្នកដទៃថា គេមិនយល់ពីខ្លួនឯងទៀតផង លុះដល់និយាយចុះនិយាយឡើង ក៏ក្លាយទៅជារឿងធំព្រោះប្រកាន់រៀងខ្លួន ក្នុងទីបំផុតក៏បែកគ្នា មើលមុខគ្នាមិនចំ ។

កូនគួរចាំទុកថា ភាពចចេសរឹងរូស ព្រោះការយល់ខុសនោះ មិនធ្លាប់ឲ្យគុណដល់អ្នកណាឡើយ មានតែធ្វើឲ្យកើតការបែកបាក់គ្នា កើតការមិនសប្បាយចិត្តជាមួយគ្នា ។ ជាប្តីប្រពន្ធនឹងគ្នាក៏ជាសម្លាញ់នឹងគ្នា ទៅចចេសរឹងរូសប្រកាន់ទិដ្ឋិជំឡើងមានះដាក់គ្នាធ្វើអ្វី បែរមករកគ្នា ជជែកគ្នា និយាយប្រាប់ការគិតឃើញដល់គ្នា

-

មានហេតុផលជាគួរនិច្ឆ័យ រួចហើយបានសប្បាយចិត្តជាមួយគ្នា មិនល្អទេឬ ។

ប្ដីប្រពន្ធ ទោះបីជាមានរូបរាងផ្សេងគ្នា តែគួរមានចិត្តមួយថ្លើមមួយ ទើបក្នុងផ្ទះមាននូវសន្តិសុខ ។ ប្ដីប្រពន្ធត្រូវតែជាមនុស្សយកហេតុផលជាសំខាន់ កុំធ្វើអ្វីៗស្រេចតែចិត្តចង់របស់ខ្លួន កុំអាងខ្លួនឯងឲ្យជ្រុល ។ ពិតមែនតែមិនបានធ្វើឲ្យគ្រួសារបែកបាក់គ្នា តែត្រូវដេកបែរខ្នងដាក់គ្នា ព្រោះហេតុមិនសប្បាយចិត្តជាមួយគ្នា ។

ប្ដីប្រពន្ធត្រូវគ្រប់គ្រងចំណង់ កុំឲ្យចំណង់វាគ្រប់គ្រងវិញ និងត្រូវគ្រប់គ្រងសេចក្ដីក្រោធ កុំឲ្យសេចក្ដីក្រោធវាគ្រប់គ្រងវិញនោះ ។ មុនធ្វើ មុននិយាយ ត្រូវមានសតិនិងបញ្ញាគ្រប់គ្រងជានិច្ច ។ ត្រូវចេះក្រែងចិត្ត ក្រែងរឿងអ្វីដែលរង្កៀសហើយ ត្រូវកុំធ្វើកុំនិយាយ ។ ត្រូវលះទិដ្ឋិមានះ ភាពចចេសរឹងរូស ការយល់ខុសនិង ឧបាទានចេញពីចិត្ត ដោយយកហេតុផលនិងភាពត្រឹមត្រូវជាគោលបដិបត្តិក្នុងជីវិតប្រចាំថ្ងៃ ។ ជាប្ដីប្រពន្ធត្រូវតែ ចេះអាណិតគ្នា ហើយស្មោះត្រង់ដល់គ្នាជានិច្ច ។

## ២៦-ចិត្តចង្អៀតនិងចិត្តទូលាយ

កូនជាទីស្រឡាញ់

មនុស្សខ្លះ សូម្បីក្រីក្រទ្រព្យសម្បត្តិ ប៉ុន្តែគាត់មានគ្នីគ្នាច្រើន មានពួកផងរបងជាមួយមកអ៊ូអែ នៅពេលដែលគាត់មានការអ្វីៗនោះ គឺគេតែងតែមកជួយគាត់ ម្ល៉ោះហើយការងារលំបាកក៏ទៅជាងាយស្រួល ។ ចំណែកបុគ្គលខ្លះ មានទ្រព្យច្រើន មានយសស័ក្តិធំដុំ តែបែរជាខ្វះញាតិ ខ្វះគ្នីគ្នា ខ្វះពួកផង ។ ដល់ទៅថា ពេលខ្លះមាន មនុស្សច្រើនមែនមកចោមរោម តែនៅក្នុងសភាពទុកចិត្ត មិនបានច្រើនព្រោះមកចោមរោមរកផលប្រយោជន៍ ប៉ុណ្ណោះ ។ មនុស្សពីរប្រភេទនេះ ពិនិត្យរកមើលទៅឃើញហើយ មិនខ្វះទេក្នុងសង្គមបច្ចុប្បន្ន ។

តាមដែលពិតនោះ គ្នីគ្នានេះសំខាន់ណាស់ មានការចាំបាច់នៅក្នុងសង្គម គឺត្រូវធ្វើការជាមួយគ្នា ត្រូវទាក់ទងគ្នាបើមិនរឿងនេះក៏រឿងនោះដែរ ។ ហេតុអ្វី ដែលធ្វើឲ្យមនុស្សយើងមានគ្នីគ្នាច្រើន ស្រឡាញ់ស្មោះចំពោះគ្នា មានទឹកចិត្តចង់ជួយគ្នាពិតៗរក្សាគ្នាទៅវិញទៅមក ពេលមានការចាំបាច់ក៏មកជួយដោយមិនចាំបាច់ហៅរក ហើយមានអ្វីៗបន្តិចបន្តួចក៏ហុចគ្នា គឺព្រោះហេតុមកអំពីមានចិត្តទូលាយនោះឯង ។

មនុស្សចិត្តទូលាយ រមែងមានគ្នីគ្នាច្រើន ផ្ទុយអំពីមនុស្សដែលអត់ទឹកចិត្ត ជាមនុស្សចិត្តចង្អៀត ។ មនុស្សចិត្តចង្អៀតរមែងខ្វះនូវគ្នីគ្នា នៅពេលចាំបាច់នឹងរក មនុស្សមកជួយគ៉ានដោយលំបាក ។

កាលកូនដឹងដូចនេះហើយ ក៏សូមឲ្យកូនជាមនុស្សចិត្តទូលាយ កុំជាមនុស្សចិត្តចង្អៀត មានអ្វីជួយអ្នកដទៃបានក៏ជួយទៅ កុំកំណាញ់កុំស្ដាយ ព្រោះនេះជាទឹកចិត្តបុណ្យរបស់កូន ។ អ្នកណាកើតទុក្ខរឿងអ្វី ល្មមកូនជួយបានក៏ជួយទៅ យ៉ាងហោចណាស់ក៏ជួយឲ្យកម្លាំងចិត្តគេដែរ ។

មនុស្សយើងពេលមានទុក្ខបានឃើញអ្នកដទៃមកសាកសួរដោយអើពើ មកជួយផ្ដល់កម្លាំងចិត្តឲ្យ ក៏មានទឹកចិត្តតស៊ូក្នុងជីវិតមិនត្រមង់ត្រមោចកណ្ដោចកណ្ដែង ។ កើតមកជាមនុស្ស កូនអើយ ធ្វើម៉េចនឹងឲ្យមានសុខសមតាមប្រាថ្នាជារហូតទៅបាននោះ គង់តែមានថ្ងៃដែលត្រូវមានទុក្ខខ្លះជាពុំខាន ។ ដល់ថ្ងៃមានទុក្ខមកដល់កូននឹងបានដឹងដល់ទឹកចិត្តរបស់មិត្តភក្តិ គ្នីគ្នាពួកផងរបងជាមួយនោះ ថាជាទឹកថ្នាំដ៏វិសេស សម្រាប់លាបស្រឡាបដល់ចិត្តសន្ដានរបស់កូនឲ្យកក់ក្ដៅ ឲ្យកើតការសង្ឃឹម និងឲ្យមានព្យាយាមតស៊ូជម្នះឧបសគ្គយ៉ាងពិតប្រាកដ ។

✍📖✍

-

## ២៧-កុំយកតម្រាប់តាមគេ

កូនជាទីស្រឡាញ់

កូនគង់តែធ្លាប់បានឃើញមនុស្សពួកខ្លះ ចូលចិត្តអង្គុយជួបជុំគ្នានិយាយដើមអ្នកដទៃ ។ បានអង្គុយជជែកគ្នាពេលណា គឺច្រើនតែយករឿងរបស់អ្នកនេះអ្នកនោះមកនិន្ទា និយាយអំពីគេក្នុងរឿងផ្សេងៗ ។ សេចក្ដីនៃពាក្យ និយាយសុទ្ធសឹងតែធ្វើឲ្យគេខូចខាតនូវកេរ្តិ៍ឈ្មោះទាំងអស់ ចូលចិត្តធ្វើខ្លួនជាអ្នកចេះដឹងរឿងរ៉ាវដូចជាច្បាស់ដោយខ្លួនឯងអ៊ីចឹង ទាំងដែលខ្លួនឯងដឹង ពិតខ្លះមិនពិតខ្លះ ប៉ុន្តែដល់ពេលនិយាយក៏ស្រួលមាត់ និយាយឲ្យរអិលដូចលាបខ្លាញ់ ។

កូនអើយ ធម្មតាមនុស្សនិយាយច្រើន ប្រព្រឹត្តទៅមិនបានឡើយ ដែលថាពាក្យនិយាយទាំងអស់សុទ្ធតែពិតនោះ ដូចពាក្យចាស់ពោលថា "និយាយច្រើន ច្រើនខុស" នេះពោលចំពោះមនុស្សដែលមិនបានទូន្មានខ្លួន ។ មនុស្សប្រភេទនេះកូនកុំយកតម្រាប់តាមឡើយ កូនគិតមើល បើមានអ្នកដទៃណាយករឿងរបស់កូន ឬរបស់ម៉ែឪបងប្អូនទៅនិន្ទា ទៅនិយាយក្នុងផ្លូវមិនល្អនោះ កូនក៏មុខតែមិនពេញចិត្តដូចគ្នាដែរ ។

ការនិយាយដល់អ្នកដទៃ កូនត្រូវប្រយ័ត្នឲ្យណាស់ សូម្បីតែរឿងពិត ទាំងដែលជារឿងល្អទៀតផងនោះ ។ រឿងល្អរបស់គេ

-

កាលកូននិយាយត្រូវមើលអ្នកស្តាប់ផង ក្រែងគេមិនសប្បាយចិត្តនឹងកូន ព្រោះហេតុតែកូនសរសើរអ្នកដទៃ ។ បើជារឿងដែលមិនពិត ឬជារឿងដែលគិតគ្នាន់គ្នេរដោយកដោយខ្លួនឯង នាំឲ្យមានបាបព្រោះមាត់ ខាតពេលវេលាឥតប្រយោជន៍ ។

កូនគួរយកពេលមកគិតរឿងរបស់កូនវិញ ទើបជាការប្រសើរ បើកូនគ្មានរឿងអ្វីត្រូវគិតច្រើនទេកូនសម្រាកទៅ ឬក៏ត្រូវយកសៀវភៅមកមើលក៏មើលទៅ ត្រូវបើកវិទ្យុស្តាប់ក៏បើកស្តាប់ទៅវាល្អជាង ព្រោះវាមិនកើតទោសពីមាត់និងមិនជាបាបតាមផ្លូវវាចា ។

ពាក្យសម្បីអាក្រក់របស់អ្នកដទៃ សូម្បីចំពោះមករកកូនក៏កូនកុំយកចិត្តទុកដាក់ឲ្យសៅហ្មងចិត្តឡើយ ។ បើគេជុំគ្នានិយាយនិន្ទាពីអ្នកដទៃ និយាយដើមអាក្រក់រឿងអ្វីៗ ក៏ជារឿងរបស់គេ កូនត្រូវគិតពិចារណាពីខ្លួនឯងវិញ អ្វីដែលកូនត្រូវធ្វើ អ្វីដែលកូនមិនត្រូវធ្វើ និងអ្វីដែលត្រូវធ្វើមុន អ្វីដែលត្រូវធ្វើក្រោយនេះទើបល្អ ។ យកល្អមែនទែន កូនត្រូវដើរចេញពីវង់មនុស្សនោះៗ ។

កូនត្រូវចាំពាក្យខាងក្រោមនេះ :

-គ្រោះភ័យចូលមករកខ្លួនតាមផ្លូវមាត់ ឯភ័យវិបត្តិចេញទៅរកអ្នកដទៃក៏ចេញពីមាត់ដែរ ។

-អ្នកដែលចូលចិត្តនិយាយរឿងអាក្រក់ពីគេ គឺជាមោឃបុរស ។

-មនុស្សអត់គុណធម៌ក្នុងខ្លួន មិនផុតពីអួតខ្លួនឯង បន្អាប់អ្នកដទៃ និងចូលចិត្តនិយាយឥតបានការ ដូចប៉ោតអត់ទឹកនៅពេលគេវែក ច្រើនតែឮរ៉ូងរ៉ាងដូច្នោះឯង ។

## ២៨-តស៊ូអត់ធន់ទោះធ្ងន់ឬស្រាល

កូនជាទីស្រឡាញ់

មនុស្សដែលខំប្រឹងប្រែងធ្វើការសុចរិត ដើម្បីលើកស្ទួយជីវភាពរបស់ខ្លួននិងគ្រួសារ រហូតដល់បានសម្រេច សមរម្យនោះជារឿងដែលគួរឲ្យសរសើរណាស់ ។

តាមពិតក្នុងលោកនេះ អ្នកដែលបានទទួលនូវទ្រព្យមរតកស្រេចស្រាប់តែម្តងដោយខ្លួនឯងមិនបាច់ប្រឹងប្រែងអ្វីនោះ មានតិចនាក់ទេ ។ ដោយច្រើន គឺចាប់ផ្តើមពីការលំបាកទៅមុន ឯទ្រព្យមរតក បានត្រឹមតែកម្លាំងស្មុគកម្លាំងចិត្ត និងចំណេះដឹងក្នុងមុខវិជ្ជាផ្សេងៗប៉ុណ្ណោះ ពោលគឺ មិនបានទទួលនូវមរតកអ្វីជាទ្រព្យសម្បត្តិមាសប្រាក់ឲ្យធំដុំនោះឡើយ ។

សំខាន់ណាស់ទៅហើយ ដែលមរតកនោះគឺជាជីវិត កម្លាំងកាយចិត្ត និងចំណេះវិជ្ជា ។ មរតកម៉ែឪគឺជីវិត កម្លាំងកាយ និងចំណេះវិជ្ជា កូនល្មមយល់បានហើយ ឯចំណែកមរតកគឺ កម្លាំងចិត្ត បានដល់ទឹកចិត្តតស៊ូព្យាយាម ដែលម៉ែឪបានបង្ហាត់បង្រៀនអប់រំទូន្មាន និងធ្វើជាគំរូរហូតមក ។ កូនត្រូវពង្រឹងកម្លាំងចិត្តឲ្យដល់ព្រមជាមួយកម្លាំងកាយ និងចំណេះវិជ្ជា ធ្វើជីវិតកូនឲ្យមានខ្លឹមសារ ។

ការប្រើកម្លាំងស្មុគ និងទឹកចិត្តប្រឹងប្រែង តស៊ូក្នុងជីវិតអត់ធន់ចំពោះការងារ មិនរួញរាចំពោះឧបសគ្គ ទើបអាចបានដល់នូវឋានៈដ៏ប្រសើរ មានជីវភាពធូរធារដោយទ្រព្យសម្បត្តិ ។ ដូចដែលកូនបានឃើញហើយ អ្នកខ្វះការតស៊ូព្យាយាម ចង់តែស្រណុក ចូលចិត្តតែសប្បាយ និងថ្នមខ្លួនប្រភេទមនុស្សជាន់អាចម៍មាន់មិនពៀចនោះ គឺមិនមានឱកាសសាងនូវឋានៈឲ្យខ្ពង់ខ្ពស់ និងឲ្យជីវិតរស់នៅបានសុខស្រួលឡើយ សូម្បីមានមរតកច្រើនសន្ធឹកសន្ធាប់យ៉ាងណា ក៏មិនយូរឡើយ នឹងបំផ្លាញអស់មិនខាន ។

កូនអើយ "ជីវិតគឺការតស៊ូ" ពាក្យនេះធ្លាប់មានមកយូរហើយ ដូច្នេះឱបសគ្គក្នុងជីវិត កូនត្រូវចាត់ទុកជា ថ្នាំកម្លាំង ។ កាលបើមនុស្សយើងមានការតស៊ូក្នុងជីវិត ក៏រមែងបានជួបប្រទះនូវឱបសគ្គ គឺសេចក្តីលំបាកជាធម្មតា តែសូមឲ្យកូនគិតថា សេចក្តីលំបាកនោះជាថ្នាំកម្លាំង ដែលនឹងជំរុញឲ្យកូនប្រឹងប្រែង ព្យាយាមតស៊ូ ដើម្បីយកឈ្នះសេចក្តីលំបាកនោះ រហូតបានដល់ទិសដៅគឺភាពប្រសើរនៃជីវិត ។

ម៉ែឪមិនមាននូវមរតកដែលជាទ្រព្យសម្បត្តិអ្វី ច្រើនទុកឲ្យកូននោះទេ តែកូនក៏បាននូវជីវិត កម្លាំងកាយ កម្លាំងចិត្ត និងចំណេះ

*វិជ្ជាព្រមល្មមសព្វគ្រប់ហើយ កូនត្រូវប្រើរបស់ទាំងនេះ ឲ្យបានសម្រេចតាមបំណងរបស់កូនទៅចុះ ។*

✍📖✍

-

## ២៩-គូតស៊ូដ៏ពិតប្រាកដ

*កូនជាទីស្រឡាញ់*

*ក្នុងកិច្ចការគ្រប់យ៉ាងនោះ អ្នកដែលធ្វើត្រូវមានការតស៊ូនិងមាននូវសេចក្ដីលំបាកផ្សេងៗ ។ អ្នកដែលធ្វើ ការបានសម្រេចគឺជាអ្នកបានឆ្លងនូវឧបសគ្គនៃការងារនោះរួចមកហើយទោះជាឧបសគ្គធ្ងន់ក្ដីស្រាលក្ដី ។ ការដែលទំពុះពារនូវគ្រប់ឧបសគ្គរហូតបានសម្រេច សុទ្ធតែដោយការតស៊ូជាមួយនឹងឧបសគ្គនោះៗប៉ុណ្ណោះ មិនមែនកន្លងផុតបានដោយការគេចចៀស ឬលោតកន្លងដូចកន្លងរបងនោះទេ គឺត្រូវពុះពារចូលទៅកណ្ដាលឧបសគ្គ នោះដូចជាអុំទូកអ៊ីចឹង ត្រូវឆ្លងកាត់រលកកាត់ខ្យល់ ឬក៏មនុស្សយើងត្រូវដើរកាត់កម្ដៅថ្ងៃទៅដូច្នោះឯង ទើបអាចបានឆ្លងផុតរលកខ្យល់ឬកម្ដៅថ្ងៃនោះទៅបាន ។*

*តាមពិត ការតស៊ូជាមួយនឹងឧបសគ្គ មិនជាលំបាកណាស់នោះឡើយ បើយើងបានតស៊ូជាមួយនឹងចិត្តខ្លួនឯង រហូតបានឈ្នះជាមុនហើយនោះ ។ ចិត្តរបស់យើងនេះឯង ដែលជាគូតស៊ូពិតប្រាកដរបស់មនុស្សយើង ការតស៊ូជាមួយនឹងចិត្តរបស់ខ្លួនឯងនេះ លំបាកជាងការតស៊ូជាមួយនឹងឧបសគ្គផ្សេងៗជាខាងក្រៅដូចជា រងា ក្ដៅ ហាលភ្លៀង ហាលខ្យល់ ស្រេកឃ្លានជាដើម ។*

-

ការតស៊ូជាមួយនឹងចិត្តឲ្យឈ្នះនោះ គឺត្រូវដាស់តឿនចិត្តឲ្យភ្ញាក់ខ្លួន មិនឲ្យទម្រន់ មិនឲ្យរាថយ ឲ្យចិត្តមានកម្លាំង មិនឲ្យអស់កម្លាំងចិត្តជាមុន ។ កាលបើតស៊ូជាមួយ ចិត្តរបស់ខ្លួនឯងបានឈ្នះហើយ មានកម្លាំងចិត្តរឹងប៉ឹង ហើយក៏អាចតស៊ូជាមួយឧបសគ្គខាងក្រៅបានដែរ ដោយ សេចក្តីសង្ឃឹមថា នឹងបានឆ្លងរួចផុតពីឧបសគ្គនោះទៅបានយ៉ាងមានសុវត្ថិភាព ។

ប្រសិនបើយកឈ្នះចិត្តខ្លួនឯង ដោយការពុះពារនូវឧបសគ្គសំខាន់ គឺសេចក្តីខ្ជិលច្រអូស ការរួញថយ និង ការអស់កម្លាំងចិត្តមិនបានទេនោះ តើនឹងអាចទៅតស៊ូជាមួយនឹងឧបសគ្គអ្វីបានទៅ ។ តស៊ូជាមួយចិត្តខ្លួនឯងឲ្យបានឈ្នះជាមុនហើយ ក៏នឹងអាចឈ្នះអ្វីៗគ្រប់យ៉ាងក្នុងលោកបាន ព្រោះថា ក្នុងលោកនេះមិនមានការតស៊ូណា ឲ្យខ្លាំងក្លាដូចជាការតស៊ូយកឈ្នះចិត្តរបស់ខ្លួនឡើយ ។

**អត្តា ហិ អត្តនោ នាថោ កោហិ នាថោ បរោ សិយា**

ខ្លួនជាទីពឹងពំនឹងអាត្មា អ្នកផ្សេងម្តេចរ៉ានឹងជាពឹងបាន។

**អត្តនា ហិ សុទន្តេន** ទូន្មានខ្លួនជាក់ជាអ្នកក្លាហាន

ច្បាំងនឹងកិលេសក្នុងចិត្តសន្តាន ខ្លួនល្អកល្យាណព្រះបានត្រាស់ថា។

**នាថំ លភតិ ទុល្លភំ** បាននូវធម្មំទីពឹងអស្ចារ្យ

ទីពឹងនេះក្រកម្រអ្នកណា ក្នុងវដ្តសង្សារស្រវាតោងបាន។

## ៣០-ក្អួតចេញមកទើបបានធូរ

កូនជាទីស្រឡាញ់

គង់តែមានថ្ងៃណាមួយមិនខាន ដែលមនុស្សយើង ត្រូវជួបជាមួយនឹងសេចក្តីទុក្ខ ឬបញ្ហាដែលធ្វើឲ្យចិត្តចង្អៀតចង្អល់មាននូវកង្វល់ ។ ជាទុក្ខកង្វល់ដែលមិនអាចប្រាប់អ្នកដទៃ ឬជាទុក្ខដែលខ្លួនឯងគិតថា អ្នកដទៃណាក៏មិនអាចនឹងជួយបាន ។ សេចក្តីទុក្ខបែបនេះនឹងធ្វើឲ្យកើត ការធុញថប់ក្នុងជីវិត នៅម្នាក់ឯងតែងតែដកដង្ហើមធំ គិតច្រើនទាល់តែឈឺក្បាល បាយមិនបាន សម្រាន្តមិនលក់ ដែលអាចបណ្តាលឲ្យកើតរោគសរសៃប្រសាទបានដោយងាយ ។

កាលបើកូនបានជួបប្រសព្វនូវភាវៈជាទុក្ខដូចបានពោលហើយនេះ កូនកុំលាក់ទុកតែម្នាក់ឯង ត្រូវកុំឲ្យនៅតែក្នុងខ្លួន គឺកូនត្រូវបញ្ចេញមកខាងក្រៅ នឹងធ្វើឲ្យកូន បានធូរស្រាល ។ ប្រៀបដូចជាការហើមពោះទល់លាមកអីចឹងណា+កូន ដល់ពេលបន្ទោបង់បានអស់មក ក៏ធូរពោះ ស្រួលខ្លួនទៅ យ៉ាងណាមិញ ការធុញថប់ ការត្រិះរិះ កង្វល់ក្នុងរឿងផ្សេងៗ ដែលមាននៅក្នុងចិត្តក៏ដូចគ្នា ត្រូវតែបញ្ចេញមកខាងក្រៅយ៉ាងនោះឯង ។

មានបញ្ហាខ្លះ ពិតមែនតែគេមិនលាក់ទុកតែឯង ប៉ុន្តែគេបញ្ចេញមកខាងក្រៅដោយការសេងសឹក ដោយការបៀតបៀន

ដោយអំពើហិង្សាផ្សេងៗឲ្យដល់អ្នកដទៃ នៅក្នុងសេចក្ដីនេះ កូនត្រូវកុំបញ្ចេញមកជាដាច់ខាត ។

វិធីបញ្ចេញនូវទុក្ខកង្វល់ ភាពធុញថប់ ឬភាពស្រពាប់ស្រពោននៃចិត្ត ដែលល្អបំផុតនោះ គឺពោលឲ្យអ្នកដទៃស្ដាប់ ក្នុងលំដាប់ថ្នាក់ដំបូងនោះគឺមាតាបិតា ។ កូនមានរឿងកើតទុក្ខតឹងណែនក្នុងទ្រូងយ៉ាងណា កូនត្រូវជម្រាបឲ្យមាតាបិតាបានជ្រាប គឺពោលឲ្យម៉ែឪស្ដាប់ហ្នឹងឯង ។ ម៉ែឪមិនជាពិស មិនជាភ័យសម្រាប់កូនឡើយ ម៉ែឪ រមែងដឹងចិត្តកូន និងយល់ពីកូនជានិច្ច សូម្បីពេលខ្លះមិន អាចដោះស្រាយបញ្ហាឲ្យកូនបានក៏ដោយ តែម៉ែឪគឺជាកន្លែងដែលសម្រាប់កូនក្អួតដាក់បាន ។ កូននឹងរៀបរាប់ នឹងយំ នឹងសម្ដែងនូវសេចក្ដីទុក្ខលំបាកឬបំណងយ៉ាងណា ចំពោះមុខម៉ែឪក៏បានទាំងអស់ បើធ្វើយ៉ាងនោះហើយ នឹងអាចធ្វើឲ្យកូនសប្បាយចិត្តឡើងបាន ឪពុកម្ដាយរីករាយ នឹងស្ដាប់រីករាយ នឹងដឹង ឪពុកម្ដាយព្រមទទួលនូវសេចក្ដីទុក្ខរបស់កូនជានិច្ច ចូរកូនកុំឃើញឪពុកម្ដាយជាអ្នកដទៃ ផ្សេងណាឲ្យសោះ ។

ភាពធុញថប់ ការតានតឹងចង្អៀតចង្អល់ ទុក្ខកង្វល់ទាំងអស់របស់កូន គឺកូនគួរមកក្អួត ឬបន្ទោបង់ដាក់ឪពុកម្ដាយចុះ កុំទុកឲ្យតឹងណែនក្នុងខ្លួនកូនតែម្នាក់ឯងនោះ ឪពុកម្ដាយព្រមធ្វើជាកន្ថោរ ឬជាបង្គន់របស់កូនជានិច្ចតាំងតែពីកូននៅក្នុងផ្ទៃម្ដាយម្ល៉េះ ។

## ៣១-ភ្លើងច្រណែន

កូនជាទីស្រឡាញ់

មានធម្មជាតិម្យ៉ាង នៅពេលកើតដល់អ្នកណា ហើយនឹងធ្វើឲ្យអ្នកនោះក្ដៅធំក្នុងចិត្ត កើតការញាប់ញ័រ ក្នុងទ្រូងនិងឈឺផ្សា ធម្មជាតិដែលថាមកនេះ គឺការ ច្រណែន ឬឫស្យា ។

ការច្រណែនកើតឡើងក្នុងចិត្ត នៅពេលឃើញអ្នកដទៃបានល្អជាងខ្លួន ក្រៃលែងមែនទែន គឺអ្នកដែលបានល្អជាងខ្លួននោះ ជាសត្រូវ ឬជាគូប្រកួតគ្នានឹងខ្លួនឯង ដែលធ្វើឲ្យការច្រណែនរឹងរឹតតែឡើងកម្លាំងខ្លាំងឡើង ។

អ្នកដែលមាននូវការច្រណែន រមែងបាត់បង់នូវសេចក្ដីសុខដោយមិនដឹងខ្លួន ឃើញអ្វីៗចេះតែទាស់មុខ ទាស់មាត់ទាស់ភ្នែកទាស់ត្រចៀកទាំងអស់ គឺជាការដូរផ្លាស់ពីទឹកចិត្តមេត្តាករុណា មកជាចិត្តគុណធម៌ មានការបង្អៀតបង្អល់នឹងអ្នកដទៃជានិច្ច ។

ការច្រណែននេះអាចសាហាវ និងក្ដៅខ្លាំងណាស់កូនអើយ រហូតដល់ថ្នាក់សម្លាប់គ្នា ដូច្នេះហើយទើបហៅ ថាភ្លើង ។ ភ្លើងច្រណែននេះ នៅពេលឆេះឡើងហើយ រមែងដុតចិត្តមនុស្សឲ្យក្ដៅរោលរាលរហូតគ្រប់ពេល ។

ភ្នក់ភ្លើងនេះពិតមែនតែជានឹងឆេះឡើងបានងាយៗ ប៉ុន្តែក៏ដោយសារឃើញសត្រូវ ឬគូប្រជែងបានល្អប៉ុណ្ណោះ ប្រសិនបើ អ្នកដែលបានល្អនោះជាមនុស្សដែលខ្លួនឯង ស្រឡាញ់វិញ បាបធម៌ឥស្សាគឺការច្រណែននឹងមិនកើតឡើងឡើយ ។

ពេលកូនបានដឹងដូច្នេះហើយ កូនត្រូវប្រយ័ត្នឲ្យណាស់ ចំពោះបាបធម៌ប្រភេទនេះ ដើម្បីកុំឲ្យកើតឡើងបាន កូនត្រូវហ្វឹកហាត់ឲ្យជាមនុស្សចិត្តទូលាយ ។ អ្នកដទៃ មិនថាជាមិត្ត ឬជាសត្រូវ មិនថាជាមនុស្សដែលកូនស្រឡាញ់ ឬស្អប់ឡើយ គឺគេមានសិទ្ធបានទទួលនូវសេចក្តីសម្រេច
ក្នុងរឿងផ្សេងៗដូចជាមនុស្សទូទៅដែរ ។ បើកូនត្រេកអរ រីករាយជាមួយគេមិនបានទេ កូនគួរតែដាក់ចិត្តឲ្យព្រងើយ ធ្វើដូចជាមិនដឹង មិនឃើញអីចឹងទៅ ឬថាត្រឹមតែចិត្ត ឃើញត្រឹមតែចិត្ត ឮត្រឹមតែចិត្តដឹងរឿងជាដើមប៉ុណ្ណោះទៅ ទើបវាមិនត្រូវភ្លើងឆេះ ។ អ្វីៗកើតឡើងសុទ្ធតែមាន ហេតុត្រឹមត្រូវ យើងមិនដឹងជាត្រូវទៅច្រណែននឹងគេ យ៉ាងដូចម្តេចនោះឡើយ ។

កូនត្រូវចាំទុកថា "កុំចង់បានរបស់ដែលអត់ កុំជាប់ចិត្តនឹងរបស់ដែលមាន អ្វីៗកើតព្រោះមានហេតុ អ្វីៗដែលកើតឡើងហើយ សុទ្ធតែប្រែប្រួល" ។ បើកូនខ្វះគុណធម៌ កូននឹងច្រណែនចំពោះសេចក្តីល្អរបស់គេ ដូច្នេះអ្នកដែលក្តៅក្រហាយពិតៗគឺជាខ្លួនកូនមិនមែនគេទេ ។ រឿងអ្វីដែលកូនត្រូវមកបង្កាត់ភ្លើងទុកត្រង់ដើមទ្រូងឲ្យឆេះតែខ្លួនឯងគ្រប់គ្រានោះ វាជាការល្ងង់ណាស់ ។

ចូរកូនកុំជាមនុស្សល្ងង់ខ្លៅឡើយ កុំច្រណែននឹងគេ កុំដុតចិត្តដុតទ្រូងខ្លួនឯងឲ្យសោះណាកូនណា+ ។

## ៣២-គិតអ្វីឲ្យវែងកុំបែងខ្លី

កូនជាទីស្រឡាញ់

ពាក្យចាស់បុរាណបានពោលហើយគឺថា "គិតអ្វីឲ្យវែង" បានសេចក្តីថាធ្វើអ្វីក៏ដោយឲ្យមើលទៅមុខ មើលឲ្យវែងឆ្ងាយ ពោលគឺឲ្យសម្លឹងមើលអនាគតកាល ។ ពាក្យនេះមានន័យសំខាន់ណាស់ ព្រោះមនុស្សដែលសម្លឹងមើលកិច្ចការក្នុងកាលវែងឆ្ងាយនោះ រមែងនឹងបានទទួលនូវសេចក្តីសម្រេចក្នុងកិច្ចការផ្សេងៗ ដែលខ្លួនធ្វើក្នុងរយៈកាលយូរ ។

ពាក្យថា " កុំបែងខ្លី" គឺកុំគិតខ្លី ។ មនុស្សដែលមើលអ្វីខ្លីក្រញ៉ុច មើលឃើញអ្វីនៅតែនឹងមុខ មើលផលក្នុងរយៈខ្លី ប្រុសស្រីដូចនេះគេហៅថាមនុស្សគំនិតខ្លី ឬ គំនិតអុសមួយបាយ រមែងបានទទួលនូវផលសម្រេចក្នុង មួយពេលយ៉ាងខ្លីតែប៉ុណ្ណោះ មិនមានជាអ្វីសំខាន់ឡើយ រួចហើយក៏ត្រូវជួលចុះអស់ទីពឹង ។ ម្យ៉ាងទៀត មនុស្សគិតខ្លី រមែងធ្វើអ្វីៗដោយសេចក្តីប្រមាទធ្វើដោយប្រញាប់ មិនគិតមុខគិតក្រោយ ធ្វើទៅតាមតែចំណង់ រមែងក្តៅក្រហាយក្នុងកាលជាខាងក្រោយអស់មួយជីវិត ។ មនុស្សខ្លះគិតខ្លីពេកក៏ក្លាយទៅជាឃាតករ មនុស្សខ្លះទៀតធ្វើអត្តឃាត ។ល។

កាលកូននឹងធ្វើនូវកិច្ចការអ្វីក៏ដោយ កូនត្រូវសម្លឹងឲ្យវែងឆ្ងាយ ដូចពាក្យថា "បិទភ្នែកឲ្យជិត សម្លឹងឲ្យឆ្ងាយ" បើការងារនោះរឹតតែធំដុំ និងសំខាន់បំផុតក្នុងជីវិត កូនក៏ត្រូវតែគិតឲ្យវែងឆ្ងាយជាទីបំផុតផងដែរ ហើយត្រូវមានស្មារតីរក្សាឲ្យខ្ជាប់ខ្ជួន ។ កូនមានគិតឃើញទេថា មានការងារខ្លះមានតម្លៃជាងជីវិតរបស់យើងរាប់ជងមិនអស់ទៅទៀត ។

ជាមួយនឹងការងារកូនត្រូវចាំទុកថា :

-ខ្លាចលំបាកតែខ្ជិល មិនព្យាយាម មិនរួចពីសេចក្តីលំបាកឡើយ ។

-ខ្វះសេចក្តីអត់ធន់ ការងារមិនបានល្អ ។

-ខ្វះការតស៊ូ ការងារមិនសម្រេច ។

-រវល់តែរឿងស្នេហា កាន់ការងារធំមិនបាន ។

-ព្រោះសេចក្តីប្រហែសធ្វេស ការងារដែលចេះស្ទាត់ហើយនោះ ត្រឡប់ទៅជាទទួលបរាជ័យដូចបុគ្គលល្ងង់ខ្លៅ ។

-រស់នៅដើម្បីធ្វើការ មិនមែនធ្វើការដើម្បីត្រឹមតែរស់នោះទេ ។

-មិនមានអ្នកណាគាំទ្រយើងឲ្យខ្ពង់ខ្ពស់ក្រៅអំពីខ្លួនឯងដែលគោរពនូវការងាររបស់ខ្លួននោះឡើយ ។

-កុំជាមនុស្សពិការទាំងដែលមាននូវអវៈយវៈគ្រប់គ្រាន់ឲ្យសោះ ។

-ការងារអាក្រក់នាំទៅរកភពងងឹត ឯការងារល្អនាំទៅរកភពភ្លឺស្វាង ។

-ការងារដែលប្រាសចាកទោសជាមង្គលដ៏ឧត្តម ។

-ការងារជាអាយុជីវិត ជាកិត្តិយស ។ល។ ការងារមានតម្លៃជាងអ្វីៗទាំងអស់ ព្រោះការងារនាំឲ្យរួចផុតចាកទុក្ខទាំងពួង ។ សេចក្ដីទាំងប៉ុន្មានដែលបានពោលហើយ នេះសម្រាប់ឲ្យកូនរៀនគិតឲ្យវែងក្នុងជីវិត ។

**កាព្យបុរាណ**

គិតអ្វីឲ្យវែងកុំបែងខ្លី វិស័យចង់ស្រីមើលឫកពា
ផ្គាប់ស្ដេចតោងតាមព្រះហទយា ផ្គាប់រាស្ត្រដូចគ្នាតោងមើលចិត្ត។
ក្បៀវមកតោងមើលអាការចេញ ពោលពាក្យម្ដេចមិញគង់ឃើញពិត
ពាក្យស្ងែងក្រែងស្ងួតជូនជាមិត្ត ពាក្យពិតជូនពាលមមាលមិញ ។

។ល។

ស្មៀកសសាងព្រតចិត្តនៅខ្មៅ បោលប្រាជ្ញតាមខ្មៅចង់ចៀសបាប
យកវែកឲ្យជីងសេប្រែសាប យកខ្សាច់មកគាបបានប្រេងឬ ។
ឫស្សីធ្វើក្លាក់ដាក់គ្មានថ្នាំង គងស្គរគាំងវាយមិនឮ
សុរិយាមិនយកជាពន្លឺ ជឿធីអំពិលអំពែកសត្វ ។

≈📖≈

-

# ៣៣-ការត្រៀមខ្លួនទុកជាមុន

កូនជាទីស្រឡាញ់

ក្នុងជីវិតមួយថ្ងៃៗនៃមនុស្សយើងនេះ រមែងតែងតែមានរឿង ដែលនឹងត្រូវឲ្យដោះស្រាយជារឿយៗ បន្តិចរឿងនេះ បន្តិចរឿងនោះ ពេលខ្លះក៏បាននាំនូវសេចក្ដីលំបាកយ៉ាប់យ៉ឺនមកប្រគល់ឲ្យទៀតផង ព្រោះដោះស្រាយមិនបាន ។ កូនក៏ធ្លាប់ជួបប្រសព្វរឿងយ៉ាងនេះមកខ្លះហើយក្នុងសេចក្ដីនេះ កូនត្រូវត្រៀមខ្លួនឲ្យដល់ព្រម ពោលគឺត្រៀមការពារទុកជាមុន ដូចពាក្យថា “ការពារទុកមុន ស្រណុកជាងដោះស្រាយ” ។

ប្រៀបដូចជាការដើរផ្លូវឆ្ងាយអ៊ីចឹងឯង គឺត្រូវត្រៀមរៀបចំអ្វីៗទុកជាមុនឲ្យសព្វគ្រប់ មិនថាជាការដាក់ផែនការ ឬស្បៀងអាហារសំពត់អាវអ្វីឡើយ គឺត្រូវតែឲ្យដល់ព្រមទាំងយានពាហនៈ ទាំងមាសទាំងប្រាក់សម្រាប់ចាយវាយ ។ល។ លុះដល់ពេលវេលាហើយ ក៏ចាប់យកអ្វីៗដែលបានត្រៀមរៀបចំជាស្រេចនោះដើរផ្លូវទៅទាន់ពេល ដល់ដើរទៅហើយ មិនមានខ្វះអ្វីឡើយ ។

ការត្រៀមរៀបចំឲ្យដល់ព្រម គឺជាកិច្ចការពារ និងដោះស្រាយបញ្ហាដែលល្អជាទីបំផុត កាលបើមានបញ្ហាកើតឡើង ក៏ដោះស្រាយបានទាន់ពេលវេលា ប្រៀបម្យ៉ាងទៀតដូចជាត្រៀមទឹក

-

សម្រាប់លត់ភ្លើង ឬត្រៀមថ្នាំដែលចាំបាច់សម្រាប់ព្យាបាល ដូច្នោះឯង ។

ក្នុងការរស់នៅកូនត្រូវត្រៀមកាយ ត្រៀមចិត្ត ត្រៀមទាំងគំនិតគិតទុកជាមុន គឺថាតទៅនឹងជាយ៉ាងណា បើយ៉ាងនោះមែនតើត្រូវធ្វើដូចម្ដេច ហើយឥឡូវនេះត្រូវធ្វើអ្វីដូចនេះជាដើម ។

ការត្រៀមរៀបចំទុកជាមុនដូចនេះ ព្រះសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ថា "មិនប្រមាទ" ។ មនុស្សដែលមិនមានប្រមាទ គឺមនុស្សដែលមិនមានការធ្វេសប្រហែស មិនអាងថាមិនអី តែងត្រៀមអ្វីៗក្នុងដំណើរជីវិតទុកជាស្រេច សូម្បីរឿងចាស់ឈឺស្លាប់ រឿងការព្រាត់ប្រាស និងរឿងផលកម្ម ដែលតែងតែមានជាប្រចាំគ្រប់ៗគ្នា អ្នកមិនប្រមាទក៏បានគិតទុកជាស្រេចហើយដែរ ដល់ពេលរឿងនោះមកដល់ ចិត្តរមែងស្ងប់រម្ងាប់មិនញាប់ញ័រ ។

ចូរកូនកុំប្រមាទក្នុងជីវិត កុំធ្វើឲ្យប្រយោជន៍បាត់បង់ទៅជាមួយនឹងពេលវេលាឲ្យសោះ បើប្រយោជន៍មិនបាត់បង់ទេ គឺនៅជាប់តាមខ្លួនកូនជានិច្ចនោះ កូននឹងជាមនុស្សល្អរហូត ចូរកូនចាំចុះថា "មិនមានអ្នករួមដំណើរណាក្នុងជីវិត ដែលនាំមកនូវការរីករាយឲ្យដូចជាខ្លួនកូនឯងជាមនុស្សល្អនោះឡើយ" ដូច្នេះកូនត្រូវតែរួមដំណើរ ជាមួយនឹងខ្លួនឯងជាមនុស្សល្អ ។ កូនត្រូវតែត្រៀមរៀបចំនូវប្រយោជន៍គឺអំពើល្អគ្រប់យ៉ាងក្នុងជីវិតកូន ។

## ៣៤-ទឹកចិត្តពិតជាសំខាន់

កូនជាទីស្រឡាញ់

ពុកនិងម៉ែធ្លាប់ប្រាប់កូនមកខ្លះហើយថា មនុស្សយើងកាលនឹងទៅនៅក្នុងទីណាហើយ នៅជាមួយអ្នកណាក៏ដោយ សូមឲ្យជាមនុស្សមានទឹកចិត្ត ។ កូនអើយ ខ្វះអ្វីអាចខ្វះបាន កុំតែខ្វះទឹកចិត្តគឺកុំមានចិត្តចង្អៀតចង្អល់ គិតតែពីបានខ្លួនឯង មិនគិតគេផងនោះ ។

មនុស្សយើងបើខ្វះទឹកចិត្តហើយ គឺមិនមានអ្នកណាចង់មកនៅឬមកគប់រកឲ្យពិតប្រាកដឡើយ ដែលគេចេះតែទ្រាំនៅក៏ព្រោះមកអំពីគេមិនទាន់រកផ្លូវទៅបានតែប៉ុណ្ណោះ ។ ប្រៀបដូចទីកន្លែងដែលក្រទឹកដូច្នោះឯង មនុស្សសត្វមិនប្រាថ្នានឹងរស់នៅឡើយ ចង់តែទៅនៅទីណា កន្លែងណាដែលមានទឹកបរិភោគ និងប្រើប្រាស់គ្រប់គ្រាន់ប៉ុណ្ណោះ ។ ចំណែកមនុស្សដែលមានទឹកចិត្តរមែងតែងតែមាននូវពពួកជនមកពឹងពាក់ពំនាក់អាស្រ័យ បាននៅហើយមិនប្រាថ្នានឹងចេញចាកទៅឡើយ សូម្បីដល់ទៅថា ទីកន្លែងចង្អៀតក៏ចេះតែនៅបាន ដូចពាក្យថា "ចង្អៀតកាយ កុំតែចង្អៀតចិត្ត" ។

កូនដឹងយ៉ាងនេះហើយ គួរព្យាយាមធ្វើខ្លួនឲ្យជាមនុស្សមានទឹកចិត្ត ជាពិសេសនោះគឺជាមួយមនុស្សនៅជិតគ្នានឹងកូន

មនុស្សដែលកូនត្រូវពឹងពាក់អាស្រ័យគេឲ្យជួយធ្វើការងារ ដូចជាកូនឈ្នួល ឬកូនចៅនៅក្រោមឱវាទ ជាដើម ។ អ្វីដែលកូនអាចជួយបានកូនជួយគេទៅ កូនត្រូវចាំថា “មនុស្សដែលមានតម្លៃគឺមនុស្សដែលគេត្រូវការ” អ្វីក៏ដោយឲ្យតែគេត្រូវការរមែងមានតម្លៃជាសំខាន់ទៅទេឲ្យតតីរបស់ក្រ ។

មនុស្សមានទឹកចិត្ត កម្ររកណាស់នៅក្នុងលោក ថែមទាំងអ្នកណាៗក៏ត្រូវការមនុស្សដែលមានទឹកចិត្តដែរៗ ក្នុងគ្រួសារ ក្នុងភូមិស្រុក ទាំងក្នុងសង្គមជាតិ សុទ្ធតែត្រូវ ការមនុស្សដែលមានទឹកចិត្តនេះណាស់ ដូច្នេះកូនត្រូវតែជាមនុស្សមានទឹកចិត្ត ។ អ្នកណាដែលធ្លាប់បានធ្វើល្អ ធ្វើប្រយោជន៍ដល់កូន កូនត្រូវកុំភ្លេចគុណបុណ្យអ្នកនោះ កូនត្រូវតបស្នងសងគុណដោយទឹកចិត្តប្រកបដោយកតញ្ញូតាធម៌ ។ កូនត្រូវមានវង្វាន់ មានកម្លាំងចិត្តឲ្យដល់អ្នកដទៃ ដែលគេធ្លាប់បានល្មើនូវសេចក្ដីល្អមកលើកូននោះយ៉ាងហោចណាស់ ក៏កូនត្រូវសរសើរចំពោះសេចក្ដីល្អរបស់គេដើម្បីឲ្យគេបានរីករាយចិត្តផងដែរ ។ ការអើពើដោយទឹកចិត្តនេះឯងណា+កូន គឺជាមន្តដ៏វិសេសសម្រាប់ចក់ស្រូបអ្នកដទៃឲ្យគេមកស្រឡាញ់រាប់អានកូន ទន់ភ្លន់ចំពោះកូនៗ

ទឹកចិត្តគឺជារបស់វិសេសណាស់កូនអើយ ជាគុណសម្បត្តិដ៏ស័ក្តិសិទ្ធិ ដូចជាកែវមណីដែលអាចធ្វើមនុស្សរូបមិនស្អាតឲ្យទៅជារូបស្អាតបាន ដូច្នោះឯង មិនត្រឹមតែប៉ុណ្ណោះ សូម្បីសេចក្ដីល្អជាបុណ្យកុសលផ្សេងៗ ក៏ធ្លាក់ចុះមកចូលក្នុងចិត្តសន្ដានរបស់មនុស្សដែលមានទឹកចិត្តនេះដែរ ។ ទឹកចិត្តគឺជាសិរីសួស្ដីនៃជីវិតណា+កូនសម្លាញ់ ។

✍🕮✍

## ៣៥-ទប់ទល់ជាមួយទុក្ខ

*កូនជាទីស្រឡាញ់*

*រាងកាយមាំមួន រមែងមិនត្រូវរោគភ័យបៀតបៀនបាន ដោយងាយឡើយ ភាពរឹងប៉ឹងមាំមួននៃរាងកាយអាចទប់ទល់នឹងរោគផ្សេងៗបាន ឈ្មោះថាទប់ទលបាននឹងទុក្ខផ្លូវកាយ ធ្វើឲ្យកាយជាសុខ ។ មានទំនងដូចគ្នាដែរ គឺថាបើមិនត្រូវការឲ្យចិត្តមានទុក្ខទេ ត្រូវសាងភាពរឹងប៉ឹងឲ្យដល់ចិត្ត សម្រាប់ទប់ទល់ជាមួយនឹងទុក្ខផ្លូវចិត្តឲ្យបានល្អ ។*

*ការពិត ទុក្ខផ្លូវចិត្តនោះ មានហេតុមកអំពីការនឹក គិតតាក់តែងនៃចិត្តខ្លួនឯងជាសំខាន់ គឺចិត្តបានចាប់យក រឿងរ៉ាវផ្សេងៗអំពីការដែលបានឃើញខ្លះ ឮខ្លះជាដើម ហើយចេះតែយកមកនឹកគិតតាក់តែងឲ្យជាយ៉ាងនេះ ឲ្យជាយ៉ាងនោះតាមការសោយអារម្មណ៍របស់ខ្លួន ។ រឿងរ៉ាវដែលចិត្តចាប់យកមកបាននោះ បើចិត្តខ្លួនឯងនឹកគិត សេពសោយទៅឆ្ងាញ់ ពោលគឺពេញចិត្ត ក៏កើតបានទៅជាសេចក្តីសុខក្នុងចិត្តហ្នឹងទៅ តែបើនឹកគិតសេពសោយទៅមិនឆ្ងាញ់ទេ មិនពេញចិត្តទេ ក៏នាំឲ្យកើតទុក្ខនៅក្នុងចិត្តសន្តានបានដូចគ្នាដែរ ។*

*រឿងតែម្យ៉ាងជាមួយគ្នា អាចធ្វើឲ្យមនុស្សម្នាក់មានចិត្តជាសុខ ហើយមនុស្សម្នាក់ទៀតកើតទុក្ខរោលរាលក្នុងចិត្តសន្តាន*

-

*បាយមិនបានសម្រាន្តមិនលក់ នេះមកអំពីការនឹកគិតតាក់តែងរបស់ចិត្តរៀងៗខ្លួន ។*

*ព្រោះហេតុដូចពោលមកនេះ កាលបើកូនមិនត្រូវការឲ្យទុក្ខមករុករានទន្ទ្រានចិត្តសន្តានរបស់កូនទេ កូនគប្បីព្យាយាមសាងភូមិឋានឲ្យបានមាំ សម្រាប់ទប់ទល់ ជាមួយទុក្ខ ។ កូនត្រូវតាំងសតិឲ្យល្អ នៅពេលជួបប្រសព្វរឿងអ្វីក៏ដោយចុះ ត្រូវចោលបានក៏ចោល កុំចាំបាច់យកមកត្រិះរិះគិតតាក់តែង ពោលគឺកុំយកមកជាអារម្មណ៍ តែបើយកមកជាអារម្មណ៍ គឺកូនត្រូវគិតដោយយ៉ាងមានសតិជាទីបំផុត គិតឲ្យសព្វគ្រប់ហើយច្បាស់លាស់សិនកុំប្រញាប់សម្រេចសេចក្តីដោយងាយៗ ។*

*ចិត្តដែលប្រកបដោយសតិសម្បជញ្ញៈក្នុងការទទួលអារម្មណ៍ មានយោនិសោមនសិការគ្រប់គ្រាន់ នោះឯងគឺជាភូមិឋានមាំទាំ ដែលសម្រាប់ទប់ទល់ជាមួយទុក្ខ គឺជាសុខភាពផ្លូវចិត្តដែលអាចរារាំងនូវទុក្ខកង្វល់បាន ។*

*ភូមិឋានមាំទាំជាជំរំសេតិ និងជាសុខភាពរបស់ចិត្ត នេះមិនងាយនឹងកសាងបានឡើយ កូនត្រូវហ្វឹកហាត់ជារឿយៗ ហ្វឹកហាត់ឲ្យយូរ ហើយហ្វឹកហាត់ជារៀងរហូតតទៅ ដូច្នេះទើបអាចមានផលកាន់តែប្រសើរឡើង ។*

-

ចូរកូនកុំភ្លេចថា ការងារសំខាន់បំផុត គឺហ្វឹកហាត់ឲ្យចិត្ត មានសុខភាព និងកុំភ្លេចគិតឲ្យខ្លួនឯងរស់នៅជាសុខ មានកូមិឋាន ព្រះធម៌ក្នុងចិត្តផង ។

-

## ៣៦-ស្គាល់មុខតែមិនស្គាល់ចិត្ត

កូនជាទីស្រឡាញ់

មានភាសិតខ្មែរយើងបានពោលថា "មនុស្សយើង ស្គាល់មុខគ្នា តែមិនស្គាល់ចិត្ត " ជាពាក្យដែលត្រឹមត្រូវគ្រប់កាល គ្រប់វេលា ទាំងជាពាក្យដាស់តឿនស្មារតីឲ្យចេះ ប្រយ័ត្នចំពោះ មនុស្សទៀតផង ។ មនុស្សអាចសាងភាពបោកបញ្ឆោតបន្លំភ្នែក អ្នកដទៃយ៉ាងពូកែ មើលខាងក្រៅល្អសមសួន តែខាងក្នុងវាជារឿង ផ្សេង ដូចរូបដែលគេគូរ ជាមួយនឹងរូបពិតអ៊ីចឹងឯង ។ រូបគូរ ច្រើនតែល្អស្អាត ស្រស់បស់គួរមើលជាងរូបពិត ព្រោះមានការ តាក់តែងទៅដោយពណ៌ជាដើម ។

មនុស្សដែលសាងភាពខ្លួនឯងឲ្យល្អមើល គឺចាំបាច់ត្រូវ តែងទឹកមុខ អាកប្បកិរិយានិងការសម្តែងចេញផ្សេងៗទៀត ព្រម ទាំងពាក្យសម្តី ដើម្បីបិទបាំងខាងក្នុងដែលមិនល្អ ដូច្នេះហើយទើប កើតមានពាក្យថា "ស្គាល់មុខ តែមិនស្គាល់ចិត្ត " នេះឡើង ។

ដូចពោលមកនេះ កាលបើកូននឹងសេពគប់ជាមួយ អ្នកណា ទុកចិត្តអ្នកណា ឬធ្វើការងារហ៊ុនជាមួយអ្នកណា ត្រូវ មើលឲ្យល្អ សង្កេតឲ្យយូរ កុំមើលត្រឹមតែមុខខាងក្រៅ ត្រូវមើល ទៅដល់ការធ្វើ ការរស់នៅ និងគម្រោងការរបស់គេ ។

-

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា គប្បីដឹងសីលដោយការនៅរួម គប្បីដឹងសេចក្ដីស្អាតដោយបានស្ដាប់សម្ដី គប្បីដឹងកម្លាំងពេលមានឧបសគ្គ និងគប្បីដឹងបញ្ញាដោយការសន្ទនា ។

កូនត្រូវយល់ដូចតទៅ :

ដឹងសីលដោយការនៅរួម គឺនៅជាមួយយូរសង្កេតពិនិត្យដោយការយកចិត្តទុកដាក់ ព្រមទាំងមានបញ្ញាយល់ការច្បាស់លាស់ផង ។

ដឹងសេចក្ដីស្អាតដោយការស្ដាប់សម្ដី គឺស្ដាប់ពាក្យនិយាយមុននិងពាក្យនិយាយក្រោយសមគ្នាទេ ម្យ៉ាងទៀតស្ដាប់ពាក្យនិយាយចំពោះមុខ និងកំបាំងមុខដូចគ្នាដែរទេ។

ដឹងកម្លាំងពេលមានឧបសគ្គ គឺកម្លាំងចិត្ត កម្លាំងគំនិតប្រាជ្ញា កម្លាំងគុណធម៌ ញាប់ញ័រឬក៏ស្ងប់រម្ងាប់ពេលមានវិបត្តិភយន្តរាយ ។

ដឹងបញ្ញាដោយការសន្ទនា គឺបញ្ញាក្នុងការសួរ បញ្ញាក្នុងការឆ្លើយ ។

បើកូនមិនមើលមុខមើលក្រោយឲ្យល្អទេ ប្រទ្បាំទៅគប់រកឬទុកចិត្តទុកថ្លើម ឲ្យការគោរពរាប់អានពេញជឹង វានឹងធ្វើឲ្យកូនមាននូវសេចក្ដីសោក ព្រោះតែខកចិត្តត្បិតសង្ឃឹមខ្លាំងពេកហ្នឹងឯង ។



ចំណែកកូនខ្លួនឯងវិញ ត្រូវតែស្មោះចំពោះមនុស្សទាំងឡាយ ជាពិសេសអ្នកដែលទុកចិត្ត សង្ឃឹមជឿជាក់ទាំងស្រុងមកលើកូននោះឯង ។ កូនកុំបោកប្រាស់ចិត្តអ្នកណាឲ្យសោះស្រឡាញ់គ្នាហើយត្រូវតែស្មោះ ។ កូនត្រូវរស់ជាមួយនឹងសុចរិតធម៌ ត្រូវសម្ដែងទឹកចិត្តឲ្យអ្នកដទៃបានយល់ និងត្រូវឲ្យគេស្គាល់ចិត្តជាពិតជាគ្នាឯង ។

## ៣៧-ចិត្តយើងចិត្តគេ

កូនជាទីស្រឡាញ់

ការនៅរួមជាមួយអ្នកដទៃ មិនថានៅរបៀបជាកិរិយាស្វាមីជាគ្រួសារមាតាបិតាកូនប្រុសស្រី ជាញាតិ មិត្ត ជាអ្នករួមការងារ ឬជាអ្នករួមសង្គមនោះឡើយ គឺកូនត្រូវរំពឹងដល់ចិត្តបំណង សេចក្តីប្រាថ្នារបស់អ្នកដទៃនោះៗ នេះជាការសំខាន់យ៉ាងក្រៃលែង ។ នឹងនៅជាមួយគ្នាបាន យូរឬមិនយូរ សុខសប្បាយឬក្តៅក្រហាយ គឺនៅត្រង់ ចំណុចសំខាន់នេះឯង ។ ការយកចិត្តគេមកប្រៀបនឹងចិត្ត យើងនិងយកចិត្តយើងទៅប្រៀបនឹងចិត្តគេ នេះជាកិច្ចដែលគួរធ្វើ ។ យើងធ្វើអ្វីក៏ដោយ ត្រូវរំពឹងដល់ផលប៉ះពាល់ដែលនឹងកើតឡើងដល់អ្នកដទៃផង ពេលខ្លះយើងគិតថា យើងធ្វើហើយយើងនឹងបានផលប្រយោជន៍ តែអ្នកដទៃគេអាចក្តៅក្រហាយព្រោះការធ្វើរបស់យើងក៏មានដែរ ។ ទើបគួរជៀសវាងនូវចំណុចនេះឲ្យបាន មិនត្រូវសាងសេចក្តីសម្រេចលើសេចក្តីក្តៅក្រហាយនៃអ្នកដទៃឡើយ អ្នកដទៃគេមិនពេញចិត្តឲ្យយើងទៅធ្វើឲ្យគេក្តៅក្រហាយដូចតែគ្នា ត្រូវនឹកដល់ចិត្តយើងចិត្តគេជានិច្ច។

មនុស្សដែលគិតតែពីបាន គេហៅថា មនុស្សឃើញតែខ្លួនឯង មនុស្សឃើញតែខ្លួនឯង រមែងដើរប៉ះគេជាធម្មតា ពោលគឺប្រព្រឹត្តនូវអំពើដែលមានផលប៉ះពាល់ដល់អ្នកដទៃ ។

-

កូនអើយ កើតជាមនុស្សណា៎កូន ពេលយើងបានឆ្អែតក៏គួរនឹកដល់អ្នកដែលគេឃ្លានខ្លះផង ពេលយើងបាន សុខក៏គួរគិតដល់អ្នកដែលមានទុក្ខផង ហើយពេលយើងមានបានក៏ត្រូវគិតដល់អ្នកដែលក្ររហេមរហាមផងដែរ ។ កូនគិតបានយ៉ាងនេះ កូននឹងជាអ្នកលះបង់ មើលឃើញអ្នកដទៃ យល់ចិត្តគេ ជួយគេ នឹងបានជាទីស្រឡាញ់រាប់អាននៃមនុស្សទូទៅ ។

ប្រសិនបើកូនជាមនុស្សឃើញតែពីខ្លួនឯង កូននឹងនៅតែឯង ព្រោះខ្វះការរាប់អានពីអ្នកជិតខាងជាដើម ។ ពេលកូនមានទុក្ខមានវេលា មិនមានអ្នកណាមកឈឺឆ្អាលឡើយ ចាំទុកណា៎កូនសម្លាញ់ ។

ចិត្តយើងចិត្តគេ	កូនត្រូវរិះរេ	គ្នាន់គ្នេរឲ្យច្បាស់
កុំតាមចិត្តពាល	តាមព្រះតម្រាស់ ព្រះធម៌ល្អណាស់
	កូនត្រូវបដិបត្តិ ។
ចិត្តគេចិត្តយើង	បើមានះឡើង	កូនត្រូវកម្ចាត់
បើចង់សុខចិត្ត	កូនត្រូវហ្វឹកហាត់ រស់ដោយប្រយ័ត្ន
	ទើបផុតអន្តរាយ ។
ខ្លួនជាឧបមា	ចម្រើនមេត្តា	ទោសារំសាយ
ឲ្យសុខខ្លួនឯង	និងសត្វទាំងឡាយ សុខនៅមិនឆ្ងាយ
	រកឃើញក្នុងចិត្ត ។

## ៣៨-គិតសិនសឹមនិយាយ

កូនជាទីស្រឡាញ់

មាត់មនុស្សនោះនាំសុខមកឲ្យក៏បាន នាំទុក្ខមកឲ្យក៏បាន ខ្មែរយើងមានពាក្យជាស់តៀនច្រើនណាស់ទាក់ទងនឹងមាត់ ដូចជា រនាបបាក់យករនាបជួស សម្ដីហួសរកអ្វីជួសគ្មាន, មាត់មានគ្រប ដបមានឆ្នុក, ដើរឲ្យមាន៣ ស្ដីឲ្យមាន៤, មនុស្សយកសម្ដី ដំរីយកភ្លុក, បង្វិលអណ្ដាតជប់ជុំសិនសឹមនិយាយ, អណ្ដាតជាអាទិ៍កន្ទង បានសុខទុក្ខផង ក៏ព្រោះអណ្ដាត, សម្ដីជាឯក លេខជាទោ, ខ្វែកស្លាប់ព្រោះអាចម៍ កំភ្លាញស្លាប់ព្រោះមាត់ជាដើម ។

កាលបើកូនគប់រកអ្នកណាក៏ដោយ ធ្វើការងារទីណាក៏ដោយ អ្វីដែលកូនត្រូវប្រយ័ត្នឲ្យណាស់នោះ គឺមាត់ លោកបានពោលថា “មនុស្សល្ងង់ទុកបេះដូងនឹងអណ្ដាតមនុស្សឆ្លាតទុកអណ្ដាតនឹងបេះដូង” ។ បើកូនចង់និយាយអ្វីៗ ត្រូវទុកដាក់សម្ដីក្នុងចិត្តគំនិត គិតហើយសឹមនិយាយ កុំនិយាយរួចហើយទើបគិត កុំនិយាយអ្វីៗតាមតែចិត្តចង់ កូនអើយនិយាយច្រើនខុសច្រើន និយាយតិចខុសតិច ។ កាលចាំបាច់ត្រូវនិយាយ កូនត្រូវនិយាយយ៉ាងមានសតិ និយាយល្មមប្រមាណ ស្គាល់កាលស្គាល់ពេល ដឹង កាលៈទេសៈ និយាយតាមធម៌តាមវិន័យ ជាសម្ដីមានប្រយោជន៍ ។

-

មនុស្សសម័យនេះពូកែនិយាយ និងនិយាយបានច្រើនណាស់ ប៉ុន្តែកូនត្រូវពិចារណាឲ្យល្អ ក្នុងបណ្ដាមនុស្សដែលពូកែនិយាយនោះ តើមានប៉ុន្មាននាក់ដែលនិយាយដោយមិនលំអៀង និយាយនាំឲ្យកើតការព្រមព្រៀង ធ្វើឲ្យមនុស្សគ្រប់ផ្នែកកើតការសប្បាយចិត្ត ។ យើងមិនអាចទៅហាមអ្នកណាថា កុំឲ្យនិយាយដូច្នោះបានដោយ សព្វគ្រប់ឡើយ គេនឹងនិយាយល្អ ឬមិនល្អយ៉ាងណា និយាយអួសទាញ និយាយចាក់ដោត និយាយអួតខ្លួន និយាយដោយល្ងង់យ៉ាងណាៗ គឺសិទ្ធិផ្ទាល់ខ្លួនរបស់គេ កាលបើគេនិយាយហើយ គេជាអ្នកទទួលខុសត្រូវ សំខាន់កុំតែកូននិយាយដូចគេទៅបានហើយ កូនត្រូវគិតឲ្យល្អមុន និយាយជាពិសេសនៅពេលកូននិយាយដល់អ្នកដទៃ កូនត្រូវតែប្រយ័ត្នឲ្យណាស់ ។

ចំពោះអ្នកដទៃ យើងមិនអាចដឹងរឿងគេបាន ដោយសព្វគ្រប់ឡើយ ។ យើងមិនដឹងក្នុងក្រៅរបស់គេ ហើយយើងទៅគិតគ្មាន់គ្នេរដោយខ្លួនឯងថា គេយ៉ាងនេះ យ៉ាងនោះមិនបានឡើយ ល្អបំផុត គឺកុំនិយាយពីគេដោយមិនដឹងរឿងច្បាស់ ។ សូម្បីដឹងច្បាស់ក៏មិនត្រូវចេះតែនិយាយដែរ បើនិយាយត្រូវឲ្យមានមេត្តា កុំចេះតែកុសលាយើង អកុសលាគេ ឲ្យកុសលាគេ អកុសលាយើងខ្លះផង ហើយបើយ៉ាងត្រឹមត្រូវនៅក្នុងផ្លូវកណ្ដាល

-

នោះគឺ កុសលា ធម្មា អកុសលា ធម្មា អព្យាកតា ធម្មា ណា៎កូន ។

✎📖✍

-

## ៣៩-មនុស្សចិត្តខ្វាក់

កូនជាទីស្រឡាញ់

កូនធ្លាប់បានឮពាក្យនេះហើយគឺ “ ឲ្យសម្លឹងមើលសេចក្តីល្អរបស់អ្នកដទៃ ” ។ ពាក្យនេះប្រាប់ឲ្យយើងហាត់ សម្លឹងមើលផ្នែកល្អរបស់មនុស្សដែលយើងស្គាល់មនុស្ស ដែលយើងគប់រក ឬមនុស្សដែលនៅរួមជាមួយយើង ។

មនុស្សយើងដែលនៅមានកិលេសនេះ សុទ្ធតែមានចំណុចខ្វះខាតក្នុងខ្លួនគ្រប់គ្នាទាំងអស់ មិនមានអ្នកណាដែលបរិសុទ្ធផូរផង់គ្រប់យ៉ាងរកកន្លែងតិះដៀលមិនបាននោះឡើយ ។ កាលបើកូនស្រឡាញ់រាប់អាន និងគប់រកអ្នកណាហើយ កូនត្រូវសម្លឹងរកចំណុចល្អរបស់អ្នកនោះឲ្យច្រើន ។ ចំណែកចំណុចមិនល្អវិញ បើគ្រាន់តែបន្តិចបន្តួចទេ ត្រូវរំលងចោលទៅ លើកយកចំណុចល្អ ដែលមានច្រើនជាងឲ្យមកប្រាកដ ។ ដូច្នេះរមែងធ្វើឲ្យលុបបាត់នូវចំណុចខ្វះខាតរបស់គេ ឬក៏សាបរលាបទៅបន្តិចម្តងៗ មិនប្រាកដឡើងនូវការទាស់ចិត្ត ការស្អប់ ឬ គំនុំគុំកួនក្នុងចិត្តកូនឡើយ ។

តាមពិត មនុស្សយើងគ្រប់គ្នា តែងតែមាននូវ ចំណុចល្អ បើយើងមើលដោយចិត្តធម៌សប្បុរស ។ មនុស្សដែលមានចិត្តប្រកបដោយធម៌សប្បុរស រមែងមើលឃើញសេចក្តីល្អរបស់អ្នក

-

ដទៃបានដោយងាយ ។ ចំណែកមនុស្ស ដែលមានចិត្តមិនប្រកបដោយធម៌សប្បុរស ឬថាព្រោះខ្វះយុត្តិធម៌ សូម្បីអ្នកដទៃមានសេចក្ដីល្អធំធេងប្រាកដដូចជា ភ្នំធំនៅនឹងមុខក៏ដោយ ក៏មើលមិនឃើញដែរ ។ មនុស្សភ្នែកល្អធម្មតា តែថាមើលមិនឃើញសេចក្ដីល្អរបស់អ្នកដទៃ គេហៅថាមនុស្សចិត្តខ្វាក់ ។

មនុស្សចិត្តខ្វាក់ រមែងមើលមិនឃើញសេចក្ដីល្អរបស់អ្នកណាឡើយ ព្រោះខ្នាចអគតិទាំង ៤ គឺការ លំអៀងព្រោះស្រឡាញ់ ១ ព្រោះស្អប់ ១ ព្រោះល្ងង់ ១ និងព្រោះភ័យខ្លាច ១ ស្ថិតនៅក្នុងខ្លួនគេជានិច្ច ដូច្នេះយើងរកយុត្តិធម៌ពីមនុស្សចិត្តខ្វាក់បានដោយលំបាក សូម្បីតែខ្លួនគេផ្ទាល់ក៏មិនដឹងថា ខ្លួនឯងមានចិត្តខ្វាក់យ៉ាងណាដែរ ។ ការគប់រកមនុស្សខ្វាក់ភ្នែកមិនជាអ្វីឡើយ តែបើគប់រកមនុស្សចិត្តខ្វាក់ ពិតជាមិនល្អទេ ។ ធ្វើល្អជាមួយមនុស្សចិត្តខ្វាក់កូនត្រូវដឹងឲ្យហើយថា គេមិនអាចនឹងមើលឃើញសេចក្ដីល្អរបស់កូនឡើយ ។

ដែលម៉ែឪប្រាប់កូនដូចពោលមកហើយនេះ គឺដើម្បីឲ្យកូនដឹងថា មនុស្សយើងច្រើនស្គាល់តែមុខគ្នា ប៉ុន្តែមិនស្គាល់ចិត្តពិតប្រាកដ ។ កូនត្រូវសិក្សាឲ្យស្គាល់មនុស្សដល់ជម្រៅចិត្តរបស់គេ កាលបើស្គាល់យ៉ាងណាហើយ កូននឹងបានប្រយ័ត្នប្រយែងខ្លួនឯងផង រៀបចំចិត្តឲ្យត្រូវល្អផង ដូចពាក្យចាស់ពោលថា “ ផ្គាប់ស្ដេចគោងតាមព្រះហទយា ផ្គាប់ភស្ត្រដូចគ្នាគោងមើលចិត្ត ” ព្រមជាមួយគ្នានោះ កូនត្រូវកុំធ្វើខ្លួនឲ្យជាមនុស្សចិត្តខ្វាក់ ប៉ុណ្ណឹងជាការស្រេច ។

## ៤០-ដួលហើយត្រូវក្រោក

កូនជាទីស្រឡាញ់

ផ្លូវនៃដំណើរជីវិតនោះ មិនមែនសុទ្ធតែរាបស្មើទៅទាំងអស់នោះទេ ។ ជីវិតមានឡើងមានចុះ មានសុខ មានទុក្ខជាគូគ្នាទៅរហូត ដោយចំពោះក្នុងកិច្ចការងារ បើរឹតតែការងារធំរឹតតែមានឧបសគ្គ ។ ប្រសិនបើកូនធ្វើការងារអ្វីមួយ ដែលកូនបានគិតសព្វគ្រប់ហើយថា ជាការងារល្អត្រឹមត្រូវ ជាការងារដែលអាចនាំឲ្យចម្រើនទៅមុខបាន ប៉ុន្តែកាលបើធ្វើទៅៗការងារនោះបែរជាត្រូវរាំងស្ទះ មិនប្រព្រឹត្តទៅតាមដូចដែលបានគិតទុកទេ ពោលគឺ មានឧបសគ្គ កូនត្រូវពុះពារនូវឧបសគ្គនោះ ទៅឲ្យបានដោយសតិបញ្ញា ដោយការអត់ធន់ និងព្យាយាមកុំស្ទន់ស្ទោត្រូវចាត់ចែងដោះស្រាយឲ្យស្រួលបួល កុំរួញថយដោយអស់កម្លាំងចិត្តជាមុននោះ ។

សភាវៈដែលសំខាន់ជាទីបំផុត នៅពេលដែលកូនជួបនូវបញ្ហាជាឧបសគ្គក្នុងជីវិតគឺកម្លាំងចិត្ត ចូរកូនកុំឲ្យកម្លាំងចិត្តធ្លាក់ចុះឲ្យសោះ ។ បើការងារ ឬប្រាក់កម្រៃត្រូវធ្លាក់ចុះយ៉ាងណា ក៏ដោយកុំតែកម្លាំងចិត្តធ្លាក់ចុះតាមវាមិនជាអ្វីឡើយ ។

កូនត្រូវថែរក្សាចិត្ត ផ្គងចិត្តឲ្យល្អ ត្រូវប្រយ័ត្នកុំឲ្យបាក់ទឹកចិត្តជាដាច់ខាត ដូចពាក្យថា “ ដួលហើយត្រូវក្រោក ” បានសេចក្ដីថា កាលភ្លាត់ជើងរអិលដួលទៅ គឺត្រូវក្រោកឡើងហើយដើរតទៅទៀត មានតែអ្នកដែលក្រោកឡើងហើយដើរតទៅទៀតប៉ុណ្ណោះ ដែលអាចទៅដល់គោលដៅបាន យ៉ាងណាមិញ កាលបើកូនមានការខកចិត្ត ព្រោះជួបនូវវិបត្តិអ្វីមួយ កូនត្រូវតាំងចិត្តឲ្យមាំផ្គងចិត្តឲ្យរឹងប៉ឹង ទាញខ្លួនឯងចេញពីការខកចិត្តនោះឲ្យបាន ហើយព្យាយាមតស៊ូជាបន្ត ដើម្បីឲ្យបានដល់នូវ សេចក្ដីសម្រេចសមតាមប្រាថ្នាក៏យ៉ាងនោះដែរ ។

កូនសម្លាញ់ត្រូវដឹងថា ការខកចិត្តកើតមកពីការមានសង្ឃឹមជាហេតុ ដូច្នេះក្នុងជីវិតរាល់ថ្ងៃកូនត្រូវចេះ ប្រយ័ត្នចំពោះសេចក្ដីសង្ឃឹម ដែលមានក្នុងចិត្តកូនផង ។ ពិតមែនហើយថាការសង្ឃឹមវានាំឲ្យមានកម្លាំងចិត្ត ប៉ុន្តែវាក៏នាំឲ្យខកចិត្តផងដែរ ព្រោះតែមិនបានសម្រេចដូចប្រាថ្នា ដូច្នេះកូនត្រូវហ្វឹកហាត់អប់រំឲ្យកើតឡើងនូវកុសល ឆន្ទៈ គឺការពេញចិត្តក្នុងអំពើប្រាសចាកទោស ។ កុសល ឆន្ទៈនាំឲ្យកូនបានសុខចិត្តក្នុងការងារដែលកំពុងធ្វើ ព្រោះកូនគិតថា ធ្វើការឲ្យអ្នកដទៃបានសុខ ម៉្លោះហើយកូនរីករាយនឹងធ្វើការ ដោយមិនចាំបាច់សង្ឃឹមផលអ្វីទៀតឡើយ ។ បើផលបានសម្រេចក៏សម្រេចដោយប្រាសចាកទោស តែបើមិនសម្រេចទេ ក៏មិនខកចិត្តដែរ គឺកូនសប្បាយចិត្តនឹងធ្វើជាបន្តទៀត និងសប្បាយចិត្តក្នុងការងារដែលប្រាសចាកទោសនោះៗ ។

ដូចពោលមកនេះ កូនពិតជាមិនបេះអស់ទឹកចិត្តក្នុងការងារផង មានកម្លាំងចិត្តធ្វើបន្តផង បាកនទទួលនូវសេចក្តីសុខចិត្តទាន់ពេលដែលកំពុងធ្វើការងារនោះផង ។

✍📖✍

-

## ៤១-ស្រឡាញ់វែងឲ្យកាត់ ស្រឡាញ់ខ្លីឲ្យត

កូនជាទីស្រឡាញ់

កូនចូរចាំទុកនូវពាក្យនេះគឺ “ ស្រឡាញ់វែងឲ្យកាត់ស្រឡាញ់ខ្លីឲ្យត ” មានសេចក្តីសំខាន់សម្រាប់ជីវិតណាស់ កូនត្រូវយល់ដូចតទៅ :

ស្រឡាញ់វែងឲ្យកាត់ គឺធម្មតាមនុស្សយើងចង់មាននូវអនាគតល្អ មានជីវិតរស់នៅជាសុខ ឋិតនៅក្នុងឋានៈ សមរម្យជាប់លាប់រហូតវែងឆ្ងាយតទៅ ដូច្នេះត្រូវលះ ត្រូវកាត់ផ្តាច់នូវអ្វីៗដែលមកទម្លាយអនាគតដ៏ភ្លឺស្វាង ធ្វើជីវិតដែលធ្លាប់តែសុខសប្បាយឲ្យធ្លាក់ចុះដុនដាប អ្វីៗនោះគឺ អបាយមុខ ៨ យ៉ាង បានដល់ លេងស្រី ១ បរិភោគទឹកស្រវឹង សេពគ្រឿងញៀនផ្សេងៗ ១ ដើរស៊ីចាយសប្បាយ បរិភោគខ្ជះខ្ជាយ ១ លេងល្បែងស៊ីសងល្បែងភ្នាល់ផ្សេងៗ ១ ត្រាច់ទៅតាមប្រកល្អករឿយៗនៅពេលយប់ ១ ដើរមើលមហោស្រពល្បែងរបាំរាំរែករឿយៗ ១ ប្រកបរឿយៗនូវសេចក្តីខ្ជិលច្រអូស ១ និងសេពគប់បាបមិត្ត១។ កាលបើកាត់ផ្តាច់នូវអបាយមុខទាំងអស់នេះឲ្យចេញពីជីវិតបានហើយ អនាគតនឹងរុងរឿងស្រស់បស់ ជាប់លាប់ មាំមួនទាំងទ្រព្យសម្បត្តិទាំងកិត្តិយសកេរ្តិ៍ឈ្មោះ ឯចំណែកគុណធម៌វិញមានតែចម្រើនទៅមុខ ។

-

ស្រឡាញ់ខ្ជីឲ្យត អបាយមុខទាំងអស់ មិនមែននាំវិនាសតែទ្រព្យសម្បត្តិទេ វាថែមទាំងបញ្ចុះតម្លៃនៃជីវិតរបស់ខ្លួន និងគ្រួសាររបស់ខ្លួន កាត់បន្ថយនូវស្មារតីដែលជារបស់មានតម្លៃបំផុតសម្រាប់ជីវិតមនុស្សទេឲ្យតផង ។ អបាយមុខជាខ្លោងទ្វារនៃនរក ជាមេរោគ ជាបាបមិត្ត ដឹកនាំឲ្យធ្វើការងារប្រកបដោយទោស ជាប្រធាននៃសេចក្ដីវិនាសគ្រប់យ៉ាង ។ បើមិនស្រឡាញ់អនាគតវែងឆ្ងាយទេ ប្រាថ្នាការស្រណុកសុខសប្បាយតែក្នុងបច្ចុប្បន្ន គិតតែពេលខ្លីៗ យកសុខស្រួលតែមួយថ្ងៃៗប៉ុណ្ណោះ ចង់អនាគតយ៉ាងណាក៏ដោយចុះ បើអ៊ីចឹងចូរសេពអបាយមុខតទៅទៀតទៅ អនាគតក៏នឹងអាប់ឱនរស្មីរហូតដល់ងងឹតសូន្យសុង ជីវិតរុងរឿងត្រូវដាច់បង់ ។

សេចក្ដីដូចពោលមកនេះ កូនក៏គង់បានជួបប្រទះមកហើយ ។ មនុស្សខ្លះ ដើមឡើយគេមានជីវិតក្រលំបាក ប៉ុន្តែដោយការខំប្រឹងប្រែង ចេះធ្វើការ ចេះទុកដាក់ ចេះបរិភោគ ប្ដីមានគំនិតប្រពន្ធមានមារយាទ ឬមានគំនិត មារយាទទាំងអស់គ្នា និងមិនប៉ះពាល់អបាយមុខ មិនយូរប៉ុន្មានគេក៏តាំងជំហរបាន មានជីវិតសុខសប្បាយ អនាគតភ្លឺថ្លា ។ ផ្ទុយមកវិញ មនុស្សខ្លះមានជីវិតសុខសប្បាយក្នុងកាលជាខាងដើម ។ ម៉ែឪរកមាសប្រាក់ទ្រព្យសម្បត្តិទុកដាក់ឲ្យច្រើនសន្ធឹកសន្ធាប់ តែគេជាមនុស្សគិតខ្លី ធ្វើអ្វីៗ

-

សមតែចិត្តខ្លួនឯងចង់ មិនស្គាល់គុណតម្លៃនៃទ្រព្យសម្បត្តិ ជាមរតក ចាយវាយខ្ជះខ្ជាយ។ ក៏មិនយូរប៉ុន្មានដែរជីវភាព ត្រូវស្រុតចុះ រស់នៅលំបាកលំបិន ខូចអស់អនាគត ។ គួរឲ្យស្ដាយជំនួសម៉ែឪរបស់គេ ដែលប្រឹងប្រែងរកទ្រព្យ សម្បត្តិមកជិតមួយជីវិតតែកូនបែរជាបំផ្លាញអស់មិនជាប៉ុន្មានឆ្នាំឡើយ ។

កូនអើយ អបាយមុខមិនជាបក្សពួកនៃមនុស្សណាទេ វាដូចជាបិសាចអ៊ីចឹង វានឹងកម្ទេចនូវអនាគតមនុស្សគ្រប់គ្នាដែលទៅវង្វេងជាមួយវា ។ ចូរកូនកុំភ្លេច ពាក្យម៉ែ ពាក្យឪណា⁺ គឺថា “ស្រឡាញ់វែងឲ្យកាត់ ស្រឡាញ់ខ្លីឲ្យត ” បើកូនស្រឡាញ់វែងកូនត្រូវតែកាត់ មាតាបិតាមិនប្រាថ្នា ឲ្យកូនស្រឡាញ់ខ្លីដូចពោលមកហើយនោះឡើយ ណា⁺ះកូន ណា⁺ ។

ស្រឡាញ់វែងឲ្យកាត់ ជាកំណាត់កុំបន្ត
គឺវែងផ្នែកខាងល្អ កុំបន្តអបាយមុខ ។
ស្រឡាញ់ខ្លីឲ្យត ជាតំណចរសេម្រុក
គឺខ្លីផ្នែកខាងសុខ ត្រូវសម្រុកមុខអបាយ ។

✎📖✍

-

## ៤២-ហាត់ឲ្យច្រើនជាងហាត់សូម

*កូនជាទីស្រឡាញ់*

*“អ្នកឲ្យរមែងជាទីស្រឡាញ់ ឯអ្នកសូមរមែងជាទី រង្កៀស” ពាក្យនេះពិតប្រាកដណាស់កូន មើលតែខ្លួនឯងក៏អាចឃើញបាន ។ បើមានអ្នកណាមកសូមអ្វីពីកូន មុនដំបូងកូនអាចមិនទាស់ចិត្តបាន តែបើគេសូមរឿយៗ សូម្បីតែវត្ថុចាំបាច់ក៏ដោយ កូនក៏មានការដឹងខ្លួនថាមិនពេញចិត្តដែរៗ ផ្ទុយមកវិញ បើមានអ្នកណាយកអ្វីមកឲ្យកូនរឿយៗ កូនបែរជាចូលចិត្តគេ សូម្បីតែរបស់នោះ មិនជាចាំបាច់ គ្រាន់តែបន្តិចបន្តួច មិនមានតម្លៃអ្វីច្រើនក៏ដោយ គង់តែកូនពេញចិត្តគេដែរ ។*

*ក្នុងន័យនេះ បើកូនធ្វើខ្លួនឲ្យជាអ្នកបរិច្ចាគច្រើនជាងជាអ្នកសូមបាន កូនក៏នឹងជាទីស្រឡាញ់រាប់អានរបស់ មនុស្សក្នុងទីនោះៗ គេមិនរង្កៀសចំពោះកូនឡើយ កូននឹងមានគ្នីគ្នាច្រើន គេនឹងព្រមទទួលកូន និងពេលខ្លះគេអាចលើកកូនឲ្យធ្វើជាអ្នកដឹកនាំពួកគេទៀតផង ។*

*ការដែលនៅរួមគ្នាជាពួកជាគណៈ កូនត្រូវគិតថា “ យើងនឹងឲ្យអ្វីដល់គេខ្លះ ” កូនត្រូវគិតយ៉ាងនេះឲ្យច្រើនជាងដែលកូនគិតថា “ យើងនឹងបានអ្វីអំពីគេខ្លះ ” ។ ផ្ដើមគិត ផ្ដើមធ្វើឲ្យបានរឿយៗ យូរទៅក៏ក្លាយជាទម្លាប់ នឹងជួយអ្វី នឹងឲ្យអ្វីដល់អ្នកដទៃក៏ធ្វើបានដោយស្រួលដែរ ឥតមានអល់អែករារែកអ្វីឡើយ ។ មនុស្សដែលគិតដល់អ្នកដទៃច្រើនជាងខ្លួនឯងយ៉ាងនេះ នឹងបានទទួលផលដូចដែលបានពោលពីខាងដើមហើយ ។*

*តាមពិតនោះ ក៏មិនផុតពីការគិតឲ្យខ្លួនឯងដែរ តែគិតឲ្យខ្លួនជាមនុស្សល្អ គិតឲ្យមានប្រយោជន៍ជាខ្លឹមសារនៃជីវិត ដូចនេះឈ្មោះថា ធ្វើនូវប្រយោជន៍ទាំងពីរខាង គឺខ្លួនឯង និងអ្នកដទៃ ។*

*ផ្ទុយមកវិញ បើធ្វើខ្លួន ឲ្យជាមនុស្សនិយមសូម ចូលចិត្តទទួលច្រើនជាងចូលចិត្តឲ្យ នឹងក្លាយជាមនុស្សចិត្តចង្អៀត ជាមនុស្សឃើញតែពីខ្លួនឯង ។ មនុស្សដែលឃើញតែពីខ្លួនឯង ចូលចិត្តតែសូមដូចនេះ នឹងជាទីរង្កៀសនៃមនុស្សទូទៅ រកគ្នីគ្នាបានដោយលំបាក ។ ទោះជាមានមនុស្សមកគប់រកខ្លះ ក៏គេមកគ្រាន់តែដើម្បីបានផលប្រយោជន៍របស់គេប៉ុណ្ណោះ នឹងរកឲ្យច្បាស់លាស់ពិតប្រាកដនោះមិនងាយមានឡើយ ។*

*ចូរកូនមានធម៌ ៤ យ៉ាងប្រព្រឹត្តទៅជាមួយមនុស្សទាំងឡាយ ។ ៤ យ៉ាងគឺ :*

*១-បើគួរឲ្យកូនត្រូវឲ្យ*

*២-បើគួរនិយាយពីរោះ កូនត្រូវនិយាយពីរោះ*

*៣-បើគួរជួយការជាប្រយោជន៍ កូនត្រូវជួយ*

៤-បើគួរឲ្យកិត្តិយសដល់អ្នកដែលនៅជុំវិញ កូនត្រូវឲ្យមិនត្រូវវាយឫកតម្កើងខ្លួនឡើយ ។

-

## ៤៣-ត្រូវប្រើប្រាក់ កុំឲ្យប្រាក់ប្រើ

កូនជាទីស្រឡាញ់

សម័យនេះអ្នកណាៗ ក៏ឃើញប្រាក់ថាជាព្រះជាម្ចាស់ដែរ ព្រោះឃើញថាប្រាក់ជារបស់បណ្ដាលឲ្យបាននូវអ្វីៗគ្រប់យ៉ាងសូម្បីតែចិត្តមនុស្សក៏គេអាចទិញបានដែរ ។ មើលចុះ មនុស្សរាល់ថ្ងៃនេះគឺសំដៅរកតែប្រាក់ គ្រប់ផ្លូវដែលបានប្រព្រឹត្តគ្រប់វិធី ទោះបីត្រូវធ្វើអាក្រក់ទុច្ចរិត ខុសច្បាប់ខុសទម្លាប់យ៉ាងណា ក៏ព្រមធ្វើទាំងអស់ឲ្យតែបានប្រាក់ ។

ព្រោះហេតុដូច្នេះហើយ ទើបក្នុងលោកយើងនេះ ត្រូវឡើងកម្ដៅ ទាំងកម្ដៅចិត្ត ទាំងកម្ដៅថ្ងៃ ។ ប្រាក់សំខាន់ក៏ពិតមែនហើយណា+កូន ប៉ុន្តែចូរកូនកុំឲ្យសេចក្ដីសំខាន់ដល់ប្រាក់ រហូតដល់ភ្លេចសេចក្ដីល្អ ភ្លេចនូវគុណធម៌នោះ ។ កាលបើកូនឲ្យសេចក្ដីសំខាន់ដល់ប្រាក់ច្រើន ពេកទៅ ប្រាក់នឹងត្រូវក្លាយជាចៅហ្វាយលើកូនដោយពិត។ កាលបើមានប្រាក់ជាចៅហ្វាយហើយ ប្រាក់ក៏នឹងប្រើកូន បង្អាប់កូនឲ្យធ្វើនេះ ឲ្យធ្វើនោះ ។ កូនអាចពិនិត្យមើលខ្លួនឯងបាន គឺនៅពេលមិនទាន់មានប្រាក់ កូនក៏មិនគិតចង់បានអ្វីច្រើនប៉ុន្មាននោះដែរ ចង់បាន ចង់ញ៉ាំ ចង់ទិញ ចំពោះតែរបស់ចាំបាច់ប៉ុណ្ណោះ លុះដល់កូនមានប្រាក់ច្រើន កូនក៏ចាប់ផ្ដើមចង់ញ៉ាំចង់ប្រើរបស់ដែលល្អៗ ប្លែកៗ ថ្លៃៗលើសពីការចាំបាច់ គឺមនុស្ស

-

យើងត្រូវប្រាក់ បង្វិលឲ្យវិលខួរក្បាលអស់ ដោយមិនដឹងខ្លួនទៀតផង ។

មនុស្សយើងកាលមិនទាន់មានប្រាក់អាចមានពេល ដេកពួន សម្រាកសម្រាន្តសុខស្រួលរាល់ព្រឹក តែដល់ពេលមានប្រាក់ត្រឡប់ទៅជាមិនមានពេលដេកពួនស្រួលបួល រកថ្ងៃសម្រាកក៏មិនមាន សឹងតែរកពេលបរិភោគអាហារឲ្យស្រួលមិនបានផង ។ នៅពេលមានប្រាក់តិច អាចនៅជាមួយក្រុមគ្រួសារបាន តែដល់ពេលមានប្រាក់ច្រើនបែរជាមិនមានពេលគ្រប់គ្រាន់សម្រាប់គ្រួសារទៅវិញ ធ្វើឲ្យគ្រួសារខ្វះការកក់ក្ដៅ ។ នេះឯងណា កូនប្រាក់វាប្រើមនុស្ស ព្រោះហេតុតែមនុស្សយើងទៅវង្វេងជាមួយវា ។

កូនមើលចុះ មនុស្សខ្លះនៅពេលមានប្រាក់ ក៏គិតការធំដុំ ហ៊ានជួលគេឲ្យទៅសម្លាប់មនុស្សដែលខ្លួនស្អប់ ចិញ្ចឹមក្រុមអ្នកលេងកាប់ចាក់ មុខរបរទុច្ចរិត ផិតក្បត់ក្នុងគូគ្រងរបស់ខ្លួន ប្រព្រឹត្តអនាចារលើបុត្រកិរិយារបស់អ្នកដទៃ ។ល។ ប្រាក់វាប្រើឲ្យធ្វើទាំងអស់ បើមិនមានប្រាក់ទេ គេអាចមិនគិតធ្វើយ៉ាងនោះ ឬគេមិនអាចធ្វើបានឡើយ ។

ដូច្នោះ កូនត្រូវតែប្រយ័ត្ន ត្រូវរៀនឲ្យយល់ពីចិត្តលោភចិត្តលង់ ត្រូវកុំឲ្យប្រាក់មកជាចៅហ្វាយឬជាបញ្ជាការប្រើកូនឲ្យសោះ ។ កូនត្រូវតែជាម្ចាស់លើប្រាក់វិញ ជាអ្នកប្រើប្រាក់និងប្រើក្នុងផ្លូវត្រូវយ៉ាងនេះ ទើបកូនមិនក្ដៅក្រហាយស្ដាយក្នុងកាលជាខាងក្រោយឡើយ ។

## ៥៥-គំនុំសងសឹក

កូនជាទីស្រឡាញ់

កូនធ្លាប់មើលភាពយន្តចិន មានរឿងពិភពគុន ហាត់ចម្រើនកម្លាំងធាតុដើម្បីប្រយុទ្ធស្លាប់រស់ ដោយកាន់យកគតិមួយថា គំនុំឈាមត្រូវតែយកឈាមមកសង ឬគំនុំត្រូវតែសងសឹក ជាចុងក្រោយ បក្សពួកទាំងពីរខាងត្រូវស្លាប់ស្ទើរតែទាំងអស់ ។ នោះគ្រាន់តែជាភាពយន្ត តែបើគិតឲ្យល្អ នាំឲ្យបានទូវគំនិតមួយថា គំនុំនិងការសងសឹកនោះមិនល្អឡើយ ។

ជាការពិតណាស់កូនអើយ គំនុំសងសឹកវាមិនល្អឡើយ ។ បើមានអ្នកណាមកធ្វើឲ្យកូនទាស់ចិត្ត រហូតដល់ធ្ងន់ធ្ងរយ៉ាងណា បើកូនទ្រាំបានល្អណាស់កូន គឺកូនត្រូវតែទ្រាំ។ កូនចាំបាច់យកចិត្តទុកដាក់ជ្រមុជជ្រមុលទៅក្នុងរឿងសងសឹកនោះធ្វើអ្វី វាធ្វើឲ្យតែកូនញាប់ញ័រក្តៅក្រហាយចិត្ត ខឹងក្រោធពុះកញ្ជ្រោលរហូតរកសុខរកស្ងប់មិនបាន និងអស់ពេលវេលាទៅទទេដោយឥតប្រយោជន៍ ។ កូន អើយគំនុំគឺជាភ្លើង វាដុតរោលចិត្តនិងគំនិតរបស់យើងឲ្យក្តៅរោលរាលគ្រប់ពេលវេលា ធ្វើឲ្យយើងងប់ជ្រប់នៅតែ ជាមួយនឹងគំនិតគិតសងសឹកជានិច្ច ជាបិសាចបំផ្លាញពេលវេលា និងសេចក្តីសុខក្នុងជីវិតយើង ព្រមទាំងគ្រួសាររបស់យើងយ៉ាងពិតប្រាកដតែម្តង ។

-

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា "អ្នកឈ្នះតែងប្រទះ នូវពៀរ អ្នកចាញ់រមែងដេកជាទុក្ខ ឯអ្នកដែលស្ងប់រម្ងាប់ បានលះបង់នូវការឈ្នះចាញ់ចោលហើយ រមែងនៅជាសុខគ្រប់ឥរិយាបថទាំង ៤" ។

កូនអើយ បើអ្នកណាមកធ្វើឲ្យកូនខឹងក្រោធ កូនអាចចោលបានក៏ចោលទៅ ឲ្យអភ័យបានក៏ឲ្យអភ័យទៅ ចិត្តកូននឹងបានសប្បាយ មិនខូចសុខភាពរបស់ចិត្តឡើយ។ ការគិតតែពីរឿងសងសឹក គ្រាន់តែដើម្បីឲ្យអស់គំនុំ ដើម្បីឲ្យសមចិត្តនោះ ពេលខ្លះអាចធ្វើឲ្យសមចិត្ត និងសប្បាយចិត្តបាន ប៉ុន្តែបានត្រឹមមួយពេលមួយរយៈប៉ុណ្ណោះ ព្រោះផលនៃការសងសឹកបាននោះ នៅមានទៀត តែលើកក្រោយនោះកាចសាហាវណាស់ វាតាមមកឲ្យយើងមានទុក្ខខ្លាំងក្លាអាចរហូតមួយជីវិតក៏បានដូចជា សងសឹកហើយត្រូវរត់គេច មិនអាចរស់នៅក្នុងកន្លែងដើមបាន សងសឹកហើយ ខ្លួនឯងត្រូវទៅដេកនៅក្នុងគុកដប់ឆ្នាំ ម្ភៃ ឆ្នាំ ឬរហូតអស់មួយជីវិត ដូច្នេះមិនប្រសើរឡើយ ហើយត្រូវជាប់ ពៀរវេរានឹងគ្នាទៅជាតិក្រោយៗទៀតផង ។

ការដែលនឹងពន្លត់ភ្លើងគំនុំបាននោះ នៅត្រង់ការឲ្យអភ័យ និងនៅត្រង់ការមិនចងពៀរ មិនមែននៅត្រង់ការចងពៀរនោះទេ ព្រោះពៀរវេរាត្រូវស្ងប់ដោយសារ ការមិនចងពៀរជាប្រាកដ បើ

-

ភ្លើងគំនុំនៅមិនទាន់រលត់ទេ គឺមិនអាចរកសេចក្ដីសុខស្ងប់ក្នុងជីវិតបានឡើយ ។

## ៤៥-ទូន្មានចិត្តបាន ទើបនៅជាសុខ

*កូនជាទីស្រឡាញ់*

*ពេលដែលយើងកើតទុក្ខ កើតការមិនសប្បាយចិត្ត ឬមានបញ្ហាជីវិតកើតឡើង វិធីដោះស្រាយដែលល្អជាទីបំផុត ហើយចាំបាច់ត្រូវឲ្យសម្រេចជាដំបូងគឺ "ការទូន្មានចិត្ត " ។ យើងត្រូវទូន្មានចិត្តឲ្យបានជាមុនសិន ទើបបន្តទៅដោះស្រាយបញ្ហាផ្សេងៗតាមក្រោយ រឿងខ្លះគ្រាន់តែទូន្មានចិត្តបានប៉ុណ្ណឹង គ្រប់យ៉ាងត្រូវបានបញ្ចប់ជាស្រេច។ បើយើងមិនទូន្មានចិត្តជាមុនទេ រួចហើយមកដោះស្រាយបញ្ហា វាអាចធ្វើឲ្យរឹតតែលំបាក ព្រោះថា បើយើងមិនទូន្មានចិត្តទេនោះ យើងត្រូវដោះស្រាយបញ្ហាដោយលោភៈ ទោសៈ មោហៈ ឬដោយកាយទុច្ចរិត វចីទុច្ចរិត និងមនោទុច្ចរិត ជាពិតប្រាកដពុំខាន ។*

*វិធីទូន្មានចិត្ត គឺគប្បីតាំងសតិឲ្យបានល្អ រំសាយនូវភាពមួហ្មងក្នុងចិត្ត ពិចារណាទៅតាមការពិតដោយល្អិតល្អន់ ពិនិត្យសាឡើងវិញនូវរឿងដែលកើតឡើង មើលឲ្យឃើញការពិតថា តើរឿងឬបញ្ហាដែលកើតឡើងនោះ វាកើតឡើងដល់យើងតែម្នាក់ឯងឬដល់អ្នកដទៃផងដែរ ។ គិតមើលៗ ឃើញអ្នកដទៃខ្លះគេមានបញ្ហាធំដុំធ្ងន់ធ្ងរជាងយើងទៅទៀតដែរទេ ហើយរឿងបែបនេះ វាជារឿងប្រក្រតីធម្មតានៃគ្រប់ជីវិតមែនឬមិនមែន ។ បើយើងគិតផ្ទៀងផ្ទាត់*

ពិចារណាសព្វគ្រប់ ឃើញច្បាស់តាមគតិរបស់សង្ខារឃើញថា វាជារឿងក្នុងលោក និងជារឿងរបស់លោក ដូចនេះឈ្មោះថា មើលឃើញសេចក្តីពិត ។ លុះដល់បានជួបនូវសេចក្តីពិតដោយខ្លួនឯងហើយក៏នឹងចូលដល់ការទូន្មានចិត្តបាន ឯលទ្ធផលរឿងធំក៏ក្លាយជារឿងតូច ចំណែករឿងតូចក៏ក្លាយទៅជាមិនមានរឿង ហើយយើងក៏បាសប្បាយចិត្ត ព្រោះអាចដោះស្រាយបញ្ហាបានដោយគំនិតនិងសតិបញ្ញារបស់ខ្លួនឯង ។

កូនអើយ ដែលទុក្ខកង្វល់នោះវាកើតឡើងក្នុងចិត្ត ព្រោះចិត្តហ្នឹងឯងព្រមទទួលហើយប្រកាន់ទុក ម៉្លោះហើយទុក្ខកង្វល់សព្វគ្រប់ទើបបានអាស្រ័យនៅនឹងចិត្តដ៏យ៉ាងស្រួលបំផុត ។ ទុក្ខកង្វល់នៅក្នុងចិត្តបានដោយស្រួល យើងអាចនិយាយបានថា នៅបានតាមសប្បាយ តែចិត្តខ្លួនឯងដែលនៅជាមួយទុក្ខកង្វល់ រមែងជាទុក្ខ នេះព្រោះហេតុតែចិត្តព្រមទទួលយកទុក្ខ រែកទុក្ខ ទូលទុក្ខនោះឯង។ បើចិត្តយើងមិនព្រមទទួលទុក្ខ មិនចាប់យកនូវសេចក្តីទុក្ខមកទុកដាក់ទេ តើចិត្តយើងនឹងជាទុក្ខបានដូចម្តេចទៅ ។

តាមពិតពាក្យថា ទូន្មានចិត្ត គឺចម្រើនបញ្ញាឲ្យមានក្នុងចិត្តនោះឯង បើចិត្តអត់បញ្ញា គឺដូចពាក្យថា “ធ្វើខ្លួនឲ្យលំបាកឥតប្រយោជន៍ ” មានការអត់អាហារជាដើម ដូច្នេះបើកូនមិនត្រូវការយកទុក្ខមកដាក់ក្នុងចិត្តទេ កូនត្រូវហ្វឹកហាត់ឲ្យមានបញ្ញា ដើម្បីទូន្មានចិត្តឲ្យបានកុំខានឡើយ ។

## ៨៦-មនុស្សដែលគេទុកចិត្ត

កូនជាទីស្រឡាញ់

កូនត្រូវធ្វើខ្លួនឲ្យដូចពាក្យនេះគឺ "នៅឲ្យគេទុកចិត្ត ចាកចេញពិតគេរលឹក " ម្យ៉ាងទៀត "នៅឲ្យគេស្រឡាញ់ លុះចាកចេញគេអាល័យ " ។ កូននៅក្នុងទីណា នៅជាមួយអ្នកណា ធ្វើការកន្លែងណា ធ្វើជាមួយអ្នកណា យូរឬមិនយូរក៏ដោយចុះ ការសំខាន់ជាដំបូងដែលកូនគួរធ្វើ គឺសាងនូវភាពកក់ក្ដៅ ការទុកចិត្តជាគ្នាឯងនិងសាងការ ពេញចិត្តឲ្យដល់អ្នកដទៃ កុំសាងនូវភាពក្ដៅក្រហាយជ្រួលច្របល់ចលាចល គឺកុំធ្វើឲ្យមានបញ្ហាដល់មនុស្សដែលកូនទៅសំណាក់ ឬទៅធ្វើការជាមួយឲ្យសោះ ។ បើកូនសាងនូវភាពកក់ក្ដៅ និងការទុកចិត្តឲ្យដល់អ្នកដទៃ កូននឹងរស់នៅក្នុងកិត្តិយស មានច្រើនសុទ្ធតែជាអ្នកស្រឡាញ់ចូល ចិត្តសម្បូណ៌មិត្ត ខ្វះសត្រូវ ។ ផ្ទុយមកវិញ បើកូនសាងនូវបញ្ហាគឺការក្ដៅក្រហាយឲ្យដល់គេ កូនមានតែគេរង្កៀស គេភ័យខ្លាចគេធុញទ្រាន់ សាបសូន្យកិត្តិយស និងរស់នៅជាទុក្ខ ។

វិធីសាងនូវភាពកក់ក្ដៅ ការពេញចិត្ត និងការទុកចិត្តនោះគឺ ការចេះលះបង់ មិនឃើញតែពីខ្លួនឯង និយាយស្ដីឲ្យល្អចេះជួយទុក្ខធុរៈអ្នកដទៃ ជាគ្នាឯងជាមួយមនុស្សគ្រប់គ្នា មានកិរិយាមារយាទរាបសា រៀបរយ ស្លូតបូតត្រឹមត្រូវ មិនប្រកាន់ខ្លួននិងមិនអួតខ្លួន គឺជាការរក្សាជានិច្ចនូវសម្បត្តិមនុស្សល្អ ។

កូនត្រូវចាំពាក្យនេះថា :

ញញឹមរកគ្នា តាំងចិត្តសន្ទនា វាចាពីរោះ
ពេលគេមានទុក្ខ ត្រូវជួយសង្គ្រោះ បានអ្វីដាក់ពោះ
កុំរស់តែឯង ។

ត្រូវចេះលះបង់ ទាំងចេះស្មោះត្រង់ ចិត្តចង់ចេះក្រែង
ទេសនាពីរោះ សង្គ្រោះក្រៃលែង មិនអួតខ្លួនឯង
មិនហែងទឹកចិត្ត ។

ទឹកចិត្តទឹកមាស ចេះដូងមានព្រះ មន្តស្នេហ៍ស័ក្ដិសិទ្ធិ
ញាតិច្រើនកន្ទង អ្នកផងទុកចិត្ត លុះចាកចេញពិត
ញាតិមិត្តអាល័យ ។

ចេះប្រើខ្លួនឯង ព្រមទាំងចេះក្រែង អ្នកផងអាស្រ័យ
ប្រឹងជួយការងារ ពេញជើងពេញដៃ ញាតិមិត្តអាល័យ
ពេលក្ស័យជីវា ។

ចេះអានខ្លួនឯង ព្រះធម៌សម្ដែង ឲ្យចេះសិក្សា
ដឹងតួនាទី មិនចោលកិច្ចការ ចេះស្គាល់អាត្មា
មនុស្សម្នាចូលចិត្ត ។

ចេះគៀនខ្លួនឯង ទាំងចេះប្រឹងប្រែង អ្នកផងអាណិត

-

-

កុំចាំគេប្រើ ការងារល្អពិត វិរិយៈសណ្ឋិត
ញាតិមិត្តត្រូវការ ។

~~~~~

-

# ៤៧-ការមិនប្រកាន់ខ្លួន

កូនជាទីស្រឡាញ់

ការប្រកាន់ខ្លួន សំដៅដល់ការគិតយកខ្លួនទៅប្រៀបជាមួយអ្នកដទៃ ឬយកអ្នកដទៃមកប្រៀបជាមួយខ្លួន ។ ការប្រកាន់ខ្លួនមាន ៣ ប្រការ គឺ គិតថាខ្លួនឯងប្រសើរជាងអ្នកដទៃ ១ គិតថាខ្លួនឯងអន់ជាងអ្នកដទៃ ១ និងគិតថាខ្លួនឯងស្មើនឹងអ្នកដទៃ ១ ។ ការគិតទាំង ៣ ប្រការនេះ សុទ្ធតែមិនល្អទាំងអស់ ។

គិតថាខ្លួនឯងប្រសើរជាងអ្នកដទៃ រមែងធ្វើឲ្យកើតការតម្កើងខ្លួន ដោយសំគាល់ថា មិនមានអ្នកណាស៊ូជាមួយខ្លួនបាន និងធ្វើឲ្យកើតការឃ្នើសឃ្នងព្រហើន ហានក្លា ធ្វើអ្វីៗស្រេចតែចិត្តខ្លួនឯង សម្តែងអាកប្បកិរិយា មើលងាយមើលថោកអ្នកដទៃ ។

គិតថាខ្លួនឯងអន់ជាងអ្នកដទៃ រមែងធ្វើឲ្យកើតការ រួញរាក្នុងការងារអស់កម្លាំងចិត្ត បាក់ទឹកចិត្ត លែងប្រឹងប្រែងតទៅទៀត បណ្តោយជីវិតទៅតាមយថាកម្មដូចចកអណ្តែតទឹក ធ្វើឲ្យគេមើលងាយមើលថោកបាន ព្រោះតែខ្វះការតស៊ូប្រឹងប្រែង ។

គិតថាខ្លួនឯងស្មើនឹងអ្នកដទៃ រមែងធ្វើឲ្យកើតការ ក្រអឺតក្រទម មិនក្រែងចិត្តអ្នកណា និងមិនគោរពអ្នកដទៃ ព្រមទាំងមិនត្រូវការស្តាប់អ្នកណាៗទាំងអស់ ព្រោះប្រកាន់ថា អ្នកដទៃប្រហែលតែនឹងខ្លួនដែរ ។

-
~~~~~

ក្នុងផ្លូវដែលត្រឹមត្រូវ គឺមនុស្សយើងគប្បីគោរព ជឿស្តាប់ ទន់ភ្លន់ ប្រព្រឹត្តទៅតាមទំនៀមទម្លាប់ប្រពៃណីដែលសមរម្យ គឺ ដល់ពេលត្រូវគោរពក៏គោរព ដល់ពេលត្រូវស្តាប់ក៏ស្តាប់ ដល់ពេលត្រូវទន់ភ្លន់ក៏ទន់ភ្លន់ ដល់ពេលត្រូវរឹងប៉ឹងក៏រឹងប៉ឹង រៀបចំខ្លួនឲ្យចូលចុះជាមួយនឹងអ្នកដទៃ សមរម្យជាមួយនឹងស្ថានការណ៍ ។

មនុស្សដែលឆ្លាតក្នុងការរៀបចំខ្លួន លោកហៅថា អ្នកធ្វើខ្លួនឲ្យបានសមរម្យ អាចចងចិត្តមនុស្សដែលនៅជុំវិញខ្លួនបាន ។

ការមិនប្រកាន់ខ្លួននេះ ជាមហាកុសលផ្នែកខាង ការគោរព

និងទន់ភ្លន់ឱនលំទោន ប្រឆាំងជាមួយនឹងមានះ ជាមង្គលដ៏ឧត្តម ។
មនុស្សទន់វាចាមេត្តាក្នុងចិត្ត ពោលមិនវិបរិតគំនិតទូន្មាន
ខ្លឹមសារសម្តីមាននយដូចស្ពាន ឬដូចជាយានទាំអ្នកដំណើរ ។
មនុស្សទន់រឹះគន់តែទោសកំហុស ត្រង់ត្រូវវិញនោះតែងដាក់ជណ្តើរ
តម្លើងមនុស្សល្អឲ្យរឹតប្រសើរ នាំអ្នកដំណើរដើរក្នុងផ្លូវត្រូវ ។
គារវោ ច និវាតោ ច ពីរនេះស្មោះស្មគ្រ័ជាអ្នកនាំផ្លូវ
មង្គលឧត្តមផុតរឿងអាស្រូវ នាំអ្នកដើរផ្លូវទៅទីខ្ពង់ខ្ពស់ ។
មួយគឺគារវៈគោរពកោតក្រែង ពីរព្រះសម្តែងមានន័យពីរោះ
និវាតោ ច នាំចេញជម្លោះ រួចផុតចាកគ្រោះព្រោះដាក់ខ្លួនទាប។
ទាបទន់ភ្លន់ពិតគំនិតឧត្តម រៀបកាយសមរម្យនិយមសុភាព
មិនមែនទន់ខ្សោយសូមឲ្យបានជ្រាប នេះគឺគុណភាពជីវិតពិតហោង ។

## ៤៨-មនុស្សដែលស្រឡាញ់យើងពិត

កូនជាទីស្រឡាញ់

មនុស្សដែលស្រឡាញ់យើងពិត ឬមិនពិតនោះ កុំមើលត្រឹមតែសំបកក្រៅ ឬស្តាប់ត្រឹមតែពាក្យសម្តីរបស់គេប៉ុណ្ណោះឲ្យសោះ ។ អាកប្បកិរិយាគេអាចធ្វើបាន ឯពាក្យសម្តីវាគ្រាន់តែជាខ្យល់មាត់ អាចផ្លាស់ប្តូរយ៉ាងណា ឬមិនដូចចិត្តយ៉ាងម៉េច គឺចេះតែប្រព្រឹត្តទៅបានទាំងអស់ ។ មនុស្សដែលពោលថាស្រឡាញ់យើង ស្គាល់ចិត្តស្គាល់ថ្លើម យើងនិងគោរពរាប់អានយើងនោះ អាចគ្រាន់តែជាទឹកអប់ ដែលបាញ់ដាក់មកឲ្យយើងសប្បាយចិត្តតែប៉ុណ្ណោះ ចិត្តពិតរបស់គេអាចស្អប់យើងក៏បាន ប៉ុន្តែដើម្បីប្រយោជន៍ អ្វីមួយទើបធ្វើឲ្យគេនិយាយ ឬមានអាកប្បកិរិយាយ៉ាងនោះឯង ។

មនុស្សដែលមិនធ្លាប់និយាយថាស្រឡាញ់យើង សូម្បីតែម្តងមិនធ្លាប់អួតសរសើរយើងម្តងណាសោះ តែគេអាចជាមនុស្សស្រឡាញ់យើងដោយពិតស្មោះត្រង់ ជាមួយយើងជាប្រាកដ ក៏មានដែរ ។

ដែលពោលមកនេះ មិនមែនបានន័យថា អ្នកដែលប្រាប់ថាស្រឡាញ់យើងទាំងអស់សុទ្ធតែមិនស្រឡាញ់យើង ដោយពិត ឬពួកអ្នកដែលមិនធ្លាបប្រាប់ថាស្រឡាញ់យើងម្តងសោះ សុទ្ធតែ

ស្រឡាញ់យើងដោយពិតនោះឡើយ គ្រាន់តែចង់ប្រាប់ឲ្យកូនដឹងថា អ្នកណាស្រឡាញ់ ឬមិនស្រឡាញ់យើងដោយពិតនោះ មិនមែននៅត្រង់សំបកក្រៅ និងខ្យល់មាត់នោះទេ គឺនៅត្រង់ការធ្វើពិតៗដែលយើងត្រូវសង្កេតពិនិត្យក្នុងកាលយូរ ។

មនុស្សដែលល្អចំពោះយើង រមែងល្អទាំងចំពោះមុខ ទាំងកំបាំងមុខ គឺតែងតែជួយយើង រក្សាយើង ទំនុកបម្រុង និងការពារយើង មិនថាយើងនឹងទៅជាយ៉ាងណា គេនៅតែស្មោះស្មើដើមជាមួយយើង នោះឯងដែលជាការស្រឡាញ់ពិត ត្រង់ដែលគេនិយាយថាស្រឡាញ់យើង ឬមិននិយាយនោះវាមិនសំខាន់ឡើយ ។

ឯចំណែកមនុស្សដែលល្អតែនឹងមុខយើង ក្រោយខ្នងនិន្ទាយើង មិនទំនុកបម្រុងយើង មិនគាំទ្រយើង និយាយពីរោះជាមួយគ្រាន់តែដើម្បីពឹងពាក់ ឬប្រើយើង មាត់និងចិត្តប្រព្រឹត្តទៅផ្សេងគ្នា នោះឯងគឺជាអ្នកដែល មិនស្រឡាញ់យើងពិត ទោះបីមាត់គេប្រាប់ថា យើងល្អយ៉ាងនេះ ល្អយ៉ាងនោះ ក៏មិនអាចជឿបានឡើយ ។

ក្នុងរឿងនេះ កូនត្រូវប្រយ័ត្នចិត្តខ្លួនឯង កុំវង្វេងប្រឡំទៅរីករាយជាមួយពាក្យសម្ដីរបស់អ្នកបោកប្រាស់ទាំងនោះ នាំឲ្យខូចខ្លួនផង អស់ទ្រព្យផង ព្រមទាំងត្រូវខកចិត្តដ៏ក្រៃលែងផង ។

## ៤៩-សុខភាពរាងកាយ

កូនជាទីស្រឡាញ់

មនុស្សយើងគ្រប់គ្នារមែងត្រូវការឲ្យមានអាយុវែង និងការមិនមានរោគាព្យាធិគ្រប់គ្នាទាំងអស់ ។ អាយុវែង រោគាព្យាធិមិនមានទៅបាននោះ មួយចំណែកកើតមកអំពី ការថែរក្សាសុខភាពរាងកាយ មិនមែនគ្រាន់តែប្រាថ្នាត្រូវការហើយ ក៏ចេះតែបណ្ដោយឲ្យសុខភាពរាងកាយទៅតាមយថាកម្មនោះទេ ។ មនុស្សដែលថែរក្សាសុខភាពរាងកាយបានល្អ រមែងមានឱកាសបាននូវអាយុវែង និងមិនមានរោគភ័យ ច្រើនជាងមនុស្សដែលមិនបានមើលថែ ។

កូនគួរប្រយ័ត្នសុខភាពរាងកាយ ត្រូវថែរក្សាឲ្យល្អ កុំធ្វើការធ្ងន់ឲ្យហួសកម្លាំង ត្រូវមានពេលសម្រាក កុំបណ្ដោយឲ្យរាងកាយទ្រុឌទ្រោមបាក់កម្លាំង ព្រោះបណ្ដាលឲ្យកើតរោគបានដោយងាយ មានរោគហើយក៏មិនងាយនឹងព្យាបាលឲ្យបានជាដូចដើម គឺវាខាតច្រើនមុខណាស់ ។

ក្នុងរឿងការថែរក្សាសុខភាពនេះ ការធ្វើតាមពាក្យណែនាំរបស់លោកគ្រូពេទ្យ គឺល្អបំផុត ដូចជាត្រូវបរិភោគអាហារដែលមានប្រយោជន៍ ត្រូវហាត់ប្រាណឲ្យបានទៀងទាត់ ត្រូវនៅក្នុងទីដែលមានខ្យល់អាកាសចេញចូលបានល្អ ត្រូវរក្សាចិត្តឲ្យស្រស់ថ្លា កុំចេះតែបណ្ដោយឲ្យចិត្ត ក្ដៅក្រហាយក្នុងរឿងផ្សេងៗ ត្រូវកុំធ្វើការ

ឲ្យបាក់កម្លាំង កុំបរិភោគទឹកស្រវឹង កុំជាប់គ្រឿងញៀន និងត្រូវឲ្យទៀងទាត់ក្នុងការបរិភោគ ការទទួលទានដំណេកជាដើម។ កាលធ្វើឲ្យសុខភាពរាងកាយបានមាំមួនល្អហើយ ក៏អាចទប់ទល់ជាមួយរោគាព្យាធិបាន ហើយនឹងជាផ្នែកមួយដែលនាំឲ្យមានអាយុវែង ។

មនុស្សយើងបើមានសុខភាពល្អហើយ ឈ្មោះថា មានទ្រព្យ ដើមទុនក្នុងដំណើរជីវិត គឺអាចធ្វើអ្វីៗបានដោយខ្លួនឯង រឹងប៉ឹងមាំមួន រហ័សរហួនក្នុងការងារចិញ្ចឹមជីវិត ។ ផ្ទុយមកវិញ បើសុខភាពរាងកាយទន់ខ្សោយ មួយថ្ងៃកាត់ មួយថ្ងៃកោរ គឺជាឧបសគ្គនៃជីវិតដោយពិត ព្រោះមិនអាចតស៊ូជាមួយនឹងការងារបាន ពេលខ្លះក៏ធ្វើឲ្យបាក់ទឹកចិត្ត អស់សង្ឃឹមមិនចង់រស់ទៀតផង ។

ការថែរក្សាសុខភាពរាងកាយបានល្អជានិច្ចរហូតទៅ រមែងធ្វើឲ្យអ្វីៗច្រើនយ៉ាងបានចម្រើនទៅមុខ ។

**អារោគ្យបរមា លាភា　　សន្តុដ្ឋិបរមំ ធនំ**

**វិស្សាសបរមា ញាតី　　និព្វានំ បរមំ សុខំ ។**

ការមិនមានរោគ ជាលាភយ៉ាងប្រសើរ ការចេះគ្រប់គ្រាន់ក្នុងចិត្តដោយធម៌សន្តោស ជាទ្រព្យដ៏ប្រសើរ ការស្និទ្ធស្នាលនឹងគ្នាជាញាតិដ៏ប្រសើរ ព្រះនិព្វានជាបរមសុខ ។

-

## ៥០-សុខភាពរបស់ចិត្ត

កូនជាទីស្រឡាញ់

កាលពោលដល់រឿងសុខភាព យើងច្រើនតែនឹកដល់សុខភាពរាងកាយ នឹកដល់ភាពរឹងប៉ឹង និងការមិនមានរោគនៃរូបរាងកាយតែប៉ុណ្ណោះ ការពិតសុខភាពផ្លូវចិត្តមានសេចក្តីសំខាន់ជាងសុខភាពរាងកាយទៅទៀត ។ ចិត្តដែលមានសុខភាពល្អ ក៏នឹងប្រព្រឹត្តទៅដោយសេចក្តីធ្លាត ស្រឡះថ្លា មិនមួម៉ៅក្តៅក្រហាយ ឬរវើរវាយឡើយ។ ដូច្នេះការរក្សាសុខភាពផ្លូវចិត្តឲ្យល្អ ទើបជាការចាំបាច់ណាស់ ។

សុខភាពនៃចិត្តនឹងល្អទៅបាន ក៏ដោយសារការថែរក្សាដែរ គឺកុំចេះតែប្រមូលរឿងរ៉ាវយកមកសន្សំទុកក្នុងចិត្តដោយអយោនិសោមនសិការ ។ អយោនិសោមនសិការបានដល់ការគិតខុស ម៉្លោះហើយអារម្មណ៍ជារឿងរ៉ាវផ្សេងៗ ដែលចិត្តបានទទួលយកមកទុកដោយការចាំនោះ ក៏ទៅជាស្អុយរលួយ បណ្តាលឲ្យខូចសុខភាពរបស់ចិត្ត ។

មិនមានរឿងអ្វីដែលអាក្រក់នោះទេ បើកូនមិនគិតថាអាក្រក់ ។ រឿងតែមួយយ៉ាង អាក្រក់សម្រាប់មនុស្សម្នាក់ ព្រោះគេគិតថាអាក្រក់ តែមិនអាក្រក់សម្រាប់មនុស្សម្នាក់ទៀតឡើយ ព្រោះគេមិនបានគិតដូច្នោះ ។ សេចក្តីពិតដូចនេះ សម្តែងឲ្យឃើញថា

-

*អាក្រក់ ឬមិនអាក្រក់មិនបាន នៅនឹងរឿងខាងក្រៅឡើយ គឺនៅនឹងការគិតរបស់មនុស្សម្នាក់ៗ ។ កាលបើដូច្នេះ កូនព្រមឲ្យគំនិតរបស់កូនធ្វើអាក្រក់ឲ្យខ្លួនកូនធ្វើអ្វី ។*

*ក្នុងលោកនេះ មិនមានអ្វីដែលសំខាន់សម្រាប់កូន ជាងកូនជាមនុស្សល្អនោះឡើយ ។ ជំនួសការដែលកូនចង់ឲ្យអ្នកដទៃធ្វើសេចក្តីល្អដល់កូន គឺកូនត្រូវព្យាយាមធ្វើសេចក្តីល្អឲ្យខ្លួនឯងទៅតាមដែលកូនត្រូវការ ព្រោះថា ក្នុងលោកនេះមិនមានអ្នកណាធ្វើសេចក្តីល្អជំនួសកូនបានឡើយ ។ សេចក្តីល្អដែលកូនធ្វើដោយខ្លួនឯង ទើបមានអានុភាពដល់ចិត្តជាពិតប្រាកដ គឺធ្វើឲ្យចិត្តបានសុខស្ងប់ ។ កាលចិត្តសុខស្ងប់ហើយ អ្វីៗជាខាងក្រៅក៏រៀបរយទៅផងដែរ ។*

*មនុស្សមានសុខភាពផ្លូវចិត្តល្អ រមែងធ្វើជាម្ចប់ឲ្យជីវិតខ្លួនឯង ។ មនុស្សយើងសំខាន់សម្រាប់ខ្លួនឯងណាស់ ចូរកូនរស់នៅជាមួយខ្លួនឯងជាមនុស្សល្អ ។ មនុស្សល្អ រមែងថែរក្សាចិត្តឲ្យមានសុខភាពល្អ ។*

**បវិវេករសំ បិត្វា រសំ ឧបសមស្ស ច**

**និទ្ទរោ ហោតិ និប្បាបោ ធម្មបីតិរសំ បិវំ ។**

*បុគ្គលក្រេបជញ្ជក់នូវរស ដែលកើតពីវិវេក និងរសព្រះនិព្វានដែលជាទីចូលទៅស្ងប់រម្ងាប់ ក្រេបជញ្ជក់នូវរសបីតិដែលកើតពីធម៌ ជាអ្នកមិនមានសេចក្តីក្រហល់ក្រហាយ និងជាអ្នកមិនមានបាប ។*

## ៥១-បរិស្ថាន

*កូនជាទីស្រឡាញ់*

*មនុស្សយើង ក្រៅអំពីថែរក្សាសុខភាពផ្លូវកាយនិងសុខភាពផ្លូវចិត្តឲ្យល្អហើយ បរិស្ថានគឺអ្វីៗដែលនៅក្នុងទី ជុំវិញយើងក៏សំខាន់ណាស់ កូនត្រូវយល់និងត្រូវថែរក្សាឲ្យបានល្អ ។ បរិស្ថានល្អនឹងធ្វើឲ្យសុខភាពរាងកាយព្រមទាំង សុខភាពរបស់ចិត្តនៃយើងគ្រប់គ្នាបានល្អទៅផងដែរ ។*

*បរិស្ថានខ្លះមានតាមធម្មជាតិដូចជា ដើមឈើ ភ្នំ ស្ទឹង ទន្លេ អាកាសធាតុ ។ល។ បរិស្ថានខ្លះ មានទៅតាមដែលយើងសាងឡើងដូចជា ទីនៅអាស្រ័យ បរិវេណជុំវិញផ្ទះ ដំណាំដាំដុះ ផ្លូវថ្នល់ជាដើម ។ បរិស្ថានទាំងអស់ នេះសុទ្ធតែអាចឲ្យគុណឲ្យទោសដល់មនុស្សយើងបាន បើយើងមើលថែនិងចាត់ការបានល្អ ក៏ឲ្យគុណ ថាបើយើងមិនបានថែទាំនិងមិនចាត់ការឲ្យល្អទេ ក៏ឲ្យទោស ។*

*ដូច្នោះ កូនគួរមើលថែនិងចាត់ការនូវបរិស្ថានឲ្យបានល្អ ដើម្បីប្រយោជន៍ដល់ខ្លួនកូនផង និងដល់អ្នកជិតខាងផង ។ កូនត្រូវចាប់ផ្តើមតាំងពីទីនៅអាស្រ័យ បន្ទប់ ដេក ផ្ទះបាយ បន្ទប់ទឹក គឺត្រូវចាត់ការមើលថែឲ្យស្អាត ប្រាសចាកក្លិនមិនល្អ និងភាពអួអាប់ ត្រូវកុំឲ្យសុកមម៉ុកសម្បុកកណ្តុរដែលជាហេតុនាំឲ្យកើតរោគផ្សេងៗ ។ បរិវេណផ្ទះ កូនត្រូវមើលថែឲ្យស្អាត ដាំផ្កា ដាំឈើជាម្លប់ កម្ចាត់ភាពស្តុកថ្កុកទឹកដែលនាំឲ្យកើតមូស សម្អាតឲ្យស្អាត កុំឲ្យមានរុយ កុំចោលសំរាមសំណល់អាហារ និងរបស់ស្មោកគ្រោកផ្សេងៗទៀត ក្នុងទីមិនសមគួរ កុំធ្វើឲ្យហុយ ធូលីហុយផ្សេងអាក្រក់ ក្លិនស្អុយ សំឡេងខ្លាំងៗ ដែលនាំឲ្យរំខានដល់អ្នកជិតខាង ។*

*ការថែរក្សារៀបចំនូវបរិស្ថានឲ្យល្អ មិនធ្វើឲ្យបរិស្ថានធម្មជាតិខូចខាតបាត់បង់ សុទ្ធតែជាប្រយោជន៍ដល់យើងទាំងអស់គ្នា ។ កាលបើចាត់ការរៀបចំបរិស្ថានបានល្អ ផ្ទះយើងក៏គួរនៅ បរិវេណផ្ទះក៏ស្អាត តាមផ្លូវថ្នល់ក៏ស្អាត តាមផ្លូវទឹកក៏ស្អាត ។ល។ ភូមិស្រុកពិតជារុងរឿង ។ ផ្ទុយមកវិញ បើយើងមិនមើលថែ និងចាត់ការឲ្យល្អទេ មានតែទម្លាយនូវបរិស្ថានដែលល្អឲ្យបាត់បង់ខូចខាតទៅវិញ មនុស្សយើងនឹងមានបញ្ហា ឬមានការក្តៅក្រហាយពិតៗ ព្រោះត្រូវបរិស្ថានដាក់ទោស ហាក់ដូចជាសងសឹកមកលើមនុស្សលោកវិញដូច្នោះឯង ។*

**ឧទកំ ហិ នយន្តិ នេត្តិកា**
**ឧសុការា នមយន្តិ តេជនំ**
**ទារុំ នមយន្តិ តច្ឆកា**
**អត្តានំ ទមយន្តិ សុព្វតា ។**

ធម្មតាអ្នកស្រែ តែងបាចទឹកបញ្ចូលស្រែ ជាងព្រួញតែងពត់ព្រួញឲ្យត្រង់ ជាងឈើតែងចាំងឈើឲ្យត្រង់ អ្នកមានវត្តប្រតិបត្តិល្អតែងអប់រំខ្លួន ។

✍📖✍

## ៥២-ប្រដៅខ្លួនឯងឲ្យបាន

កូនជាទីស្រឡាញ់

មានការប្រព្រឹត្តដើម្បីកសាងខ្លួនឲ្យចម្រើនតាមគោលធម៌ ៣ ប្រការ ៖

១-ប្រដៅខ្លួនឯងឲ្យបាន

២-អានខ្លួនឯងឲ្យដឹង

៣-ប្រឹងខ្លួនឯងឲ្យដល់

ក្នុងប្រការទី ១ គឺ "ប្រដៅខ្លួនឯងឲ្យបាន" ដោយសេចក្តីថា តាមប្រក្រតីមនុស្សយើង ច្រើនតែមិនសូវបាន ប្រដៅខ្លួនឯងឬដាស់តឿនខ្លួនឯងឡើយ ប៉ុន្តែបែរជាប្រដៅអ្នកដទៃ ដាស់តឿនអ្នកដទៃបានដោយសព្វគ្រប់ ។ ប្រដៅឲ្យគេធ្វើយ៉ាងនេះ ដាស់តឿនឲ្យគេធ្វើយ៉ាងនោះ ប្រដៅបាន តឿនបាន ចំណែកខ្លួនឯងត្រឡប់ជាមិនព្រមប្រដៅ មិនព្រមដាស់តឿន ទើបបានជាភ្លាំងភ្លាត់ប្រព្រឹត្តខុស ជួបប្រទះនូវទុក្ខលំបាកក្នុងជីវិត ។ តាមដែលពិត ខ្លួនយើងនេះឯង ដែលប្រដៅទូន្មានបានដោយលំបាកជាទីបំផុត ហ្វឹកហាត់ក៏លំបាក និងកែឧបនិស្ស័យអាក្រក់ផ្នែកណាមួយ ក៏លំបាកទៅទាំងអស់ ។

ជាធម្មតានៃការងារ កាលបើធ្វើហើយ រមែងភ្ញាំងភ្ញាត់ ឬខ្វះខាតទៅបាន ហើយមនុស្សយើងម្នាក់ៗក៏ រមែងមានការខុសឆ្គង ភ្ញាំងភ្ញាត់ និងខ្វះខាតដូចគ្នាដែរ ប៉ុន្តែកាលបើជួបប្រទះនូវរឿងខ្វះខាតជាដើម ហើយក៏ប្រដៅខ្លួនឯង ដាស់តឿនខ្លួនឯងថា មិនត្រូវធ្វើយ៉ាងនោះទៀតឡើយ ។ ព្យាយាមដាស់តឿនខ្លួនឯងរឿយៗ ដូច្នេះ រមែងធ្វើឲ្យគិតកែខៃដោះស្រាយ រៀបចំចាត់ចែងការងារ និងរៀបចំចាត់ចែងខ្លួនឯងឲ្យល្អត្រឹមត្រូវ ជាផ្លូវឲ្យកើតសេចក្តីសម្រេចក្នុងឱកាសតទៅទៀតបាន ។

បើមិនមានអ្នកដទៃណាមកប្រដៅយើងទេ និងខ្លួនឯងក៏មិនប្រដៅខ្លួនឯងដែរ ឬមិនព្រមដាស់តឿនខ្លួនឯង ព្រោះគិតថាខ្លួនឯងឆ្លាតហើយ មុខតែរកផ្លូវត្រូវមិនឃើញឡើយ មានតែឆ្ពោះមុខទៅរកសេចក្តីវិនាសតែម្យ៉ាងប៉ុណ្ណោះ គួរឲ្យខ្លាចមែនទែន ។

កូនត្រូវហ្វឹកហាត់ដាស់តឿនខ្លួនឯង ឲ្យជាប្រចាំរាល់ថ្ងៃ នឹងរង់ចាំឲ្យអ្នកដទៃគេមកដាស់តឿននោះ ពិតជាមិនសមគួរឡើយ ។ មានអ្នកណាគេមកយាមកូន និងដឹងរឿងកូនឲ្យបានដោយសព្វគ្រប់ទៅ ណាមួយផ្លូវចិត្ត ផ្លូវគំនិត ដែលមិនមានរូបឲ្យគេឃើញទៀត ដូច្នេះ បើកូនដាស់តឿនខ្លួនឯងបាន គឺជាការល្អបំផុត ។

**អត្តនា ចោទយត្តានំ បដិមំសេតមត្តនា**

**សោ អត្តគុត្តោ សតិមា សុខំ ភិក្ខុ វិហាហិសិ ។**

អ្នកចូរចោទខ្លួនដោយខ្លួនឯង ចូរពិចារណាខ្លួនដោយខ្លួនឯង ម្នាលភិក្ខុ អ្នកនោះជាអ្នកមានសតិរក្សាខ្លួនប្រាណហើយ នឹងរស់នៅជាសុខសប្បាយ ។

## ៥៣-អានខ្លួនឯងឲ្យដឹង

កូនជាទីស្រឡាញ់

គោលធម៌សម្រាប់ប្រព្រឹត្តដើម្បីកសាងខ្លួនប្រការទី ២ គឺ "អានខ្លួនឯងឲ្យដឹង" ដោយសេចក្ដីថា ត្រូវសិក្សាខ្លួនឯង ត្រួតត្រាពិនិត្យខ្លួនឯង ដើម្បីឲ្យដឹងនូវការពិតនៃជីវិតរបស់ខ្លួន ពោលគឺត្រូវស្គាល់ខ្លួនឯងឲ្យបានច្បាស់ ។ ត្រូវស្គាល់ថាខ្លួនឯងមានការចេះដឹងមានសមត្ថភាព មានសតិបញ្ញាត្រឹមណា មានកម្លាំងប៉ុនណា និងដែលសំខាន់ជាទីបំផុត ត្រូវដឹងចិត្តខ្លួនឯងថា ត្រូវការអ្វីជាប្រាកដក្នុងជីវិតនេះ ។ ត្រូវអានខ្លួនឯងឲ្យបានច្បាស់ ដូចអានសៀវភៅ ឬអានគម្ពីរធម៌អ៊ីចឹង ។ ត្រូវយល់ពីខ្លួនឯងឲ្យសព្វគ្រប់ប្រៀបដូចជាមនុស្សដើរផ្លូវឆ្ងាយបានមើលផែនទីស្គាល់ផ្លូវច្បាស់ ឬដូចជាងធ្វើផ្ទះបានមើលគំរូផ្ទះយល់ច្បាស់ដូច្នោះឯង ។

ដំណើរជីវិត ឬដំណើរការងារយ៉ាងណាមួយក៏ដូចគ្នានឹងការដើរផ្លូវ ឬការសាងសង់ផ្ទះនោះឯង គឺអានខ្លួនឯងឲ្យបានច្បាស់លាស់ រឹតតែច្បាស់រឹតតែល្អ ។ ជីវិតនិង ការងារប្រព្រឹត្តទៅបានល្អព្រមទាំងសេចក្ដីសម្រេចដែល នឹងសម្រេចបានដោយល្អនោះព្រោះមកអំពីការស្គាល់ខ្លួននេះឯង ។

-

បើសូម្បីតែខ្លួនឯងក៏មិនយល់ពីខ្លួនឯង និងមិនស្គាល់ខ្លួនឯងផងនោះ នឹងធ្វើការងារអ្វីបានទៅ ដូចអ្នកដើរផ្លូវអត់មានផែនទីទោះបីជាដើរទៅបានមែន ក៏មុខជាវង្វេង ឬខាតពេលខាតកម្លាំងជាពិតប្រាកដ ព្រោះតែខ្លួនមិនស្គាល់ផ្លូវនោះឯង ។ ដូច្នោះមុននឹងធ្វើនូវកិច្ចការងារណា កូនត្រូវសិក្សាអំពីខ្លួនឯងឲ្យបានច្បាស់លាស់ជាមុនសិន គឺជាការអានខ្លួនឯងដូចជាការអានសៀវភៅអ៊ីចឹង រួចហើយសឹមធ្វើនូវកិច្ចការងារនោះ ។ កាលបើយ៉ាងនេះ ការខ្វះខាត ឬការភ្លាំងភ្លាត់ឆ្គាំឆ្គងនឹងមិនបានកើតឡើងឡើយតាំងពីដំបូងតែម្ដង ។

ក្រៅអំពីដឹងថា ខ្លួនឯងមានការចេះដឹងប៉ុនណា មានសមត្ថភាពប៉ុនណា មានសតិបញ្ញាប៉ុនណា មានកម្លាំងប៉ុនណា និងមានបំណងប្រាថ្នាក្នុងជីវិតយ៉ាងណា ហើយនោះកូនត្រូវស្គាល់នូវតួនាទីជាដើមរបស់ខ្លួនទៀតផង គឺស្គាល់តាមសេចក្ដីពិតថាខ្លួនមានតួនាទី មានឋានៈ មានភេទ មានជំនាញ និងមាននូវគុណធម៌យ៉ាងណា ហើយត្រូវប្រព្រឹត្តឲ្យបានសមរម្យទៅតាមតួនាទីជាដើមនោះ និងឲ្យបានសមស្របទៅតាមផ្លូវល្អ ផ្លូវចម្រើន ដើម្បីកុំឲ្យធ្លាក់ខ្លួនចូលទៅក្នុងផ្លូវនៃសេចក្ដីវិនាស ។

**អត្តា ហិ អត្តនោ នាថោ អត្តា ហិ អត្តនោ គតិ**
**តស្មា សញ្ញម អត្តានំ អស្សំ ភទ្រំវ វាណិជោ។**

-

ខ្លួនជាទីពឹងរបស់ខ្លួនឯង ខ្លួនជាគតិរបស់ខ្លួនឯង ព្រោះហេតុនោះ អ្នកចូររក្សាខ្លួនឲ្យដូចជានាយពាណិជ ថែរក្សានូវសេះដែលល្អយ៉ាងដូច្នោះឯង ។

-

## ៥៤-ប្រឹងខ្លួនឯងឲ្យដល់

កូនជាទីស្រឡាញ់

គោលធម៌សម្រាប់ប្រព្រឹត្តដើម្បីកសាងខ្លួនប្រការទី ៣ គឺ “ប្រឹងខ្លួនឯងឲ្យដល់” ដោយសេចក្ដីថា មនុស្សយើងចូលចិត្តឲ្យអ្នកដទៃមកលើកតម្កើងខ្លួន ប៉ុន្តែមនុស្សដែលនឹងមានគេមកស្រឡាញ់រាប់អាន និងលើកតម្កើងនោះ គឺត្រូវតែជាមនុស្សមានមន្តស្នេហ៍ស័ក្តិសិទ្ធិក្នុងខ្លួន ។ មនុស្សដែលខ្វះមន្តស្នេហ៍នឹងមានអ្នកណាមកស្រឡាញ់ មករាប់អានទៅ ។ វិធីម្យ៉ាងសម្រាប់សាងស្នេហ៍ឲ្យមនុស្សស្រឡាញ់ គឺប្រឹងខ្លួនឯង ឬប្រើខ្លួនឯង ។ ការប្រឹងខ្លួនឯង ឬប្រើខ្លួនឯង គឺការដាស់តឿនខ្លួនឯងឲ្យធ្វើការងារ គិតធ្វើការដោយខ្លួនឯង គិតជួយអ្នកដទៃដោយខ្លួនឯង និងធ្វើខ្លួនឲ្យជាប្រយោជន៍ ។ ចំពោះការងារមិនចាំបាច់ឲ្យអ្នក ណាមកប្រើមកបង្គាប់ឡើយ ឃើញសមគួរយ៉ាងណា ហើយក៏ធ្វើទៅដោយខ្លួនឯង គ្រាន់តែការងារខ្វះត្រូវសួរអ្នកដទៃ ដើម្បីឲ្យត្រូវតាមបំណងរបស់គេផងប៉ុណ្ណោះ ។

មនុស្សដែលប្រើខ្លួនឯងបានពូកែយ៉ាងនេះ គឺឃើញការងារដែលជាការងារល្អ ជាការងារត្រឹមត្រូវ និងជាការងារមានប្រយោជន៍ហើយនោះ ក៏ប្រើខ្លួនឯងឲ្យធ្វើ គេហៅថាជាមនុស្សមាន

-

នូវអត្តសម្បទា គឺមានខ្លួនចម្រើនដល់ព្រមដោយទឹកចិត្ត ។ មនុស្សដូចពោលមកនេះ គេមិនព្រមនៅស្ងៀម មិនព្រមនៅទំនេរឡើយ ឃើញអ្នកដទៃធ្វើការអ្វី គេអាចជួយបានក៏ជួយភ្លាម ។

បើកូនត្រូវការឲ្យបានដល់សេចក្ដីសម្រេច និងត្រូវការឲ្យខ្លួនជាមនុស្សមានមន្ដស្នេហ៍ កូនត្រូវចេះប្រើខ្លួនឯង តាមដូចដែលបានពោលហើយ ។ កូនកុំនៅស្ងៀម កុំធ្វើព្រងើយក្នុងការដែលត្រូវជួយអ្នកដទៃ កូនត្រូវជួយដោយទឹកចិត្ត កុំជាមនុស្សអត់ទឹកចិត្តឲ្យសោះ ។ កូនកុំជាមនុស្ស ឃើញតែពីខាងបាននូវសម្បត្តិក្រៅខ្លួននោះ ព្រោះមនុស្សដែលអត់ទឹកចិត្ត គិតតែពីខ្លួនឯង ចង់បានតែសម្បត្តិទ្រព្យក្រៅខ្លួនប៉ុណ្ណោះ គេហៅថាមនុស្សមានស្នៀត មិនមែនមានស្នេហ៍ទេ មិនគួរឲ្យរាប់អានឡើយ គឺជាមនុស្សដែលគួរឲ្យវង្វៀសចំពោះមនុស្សទូទៅ ។

កូនអើយ សាងស្នេហ៍ល្អជាងសាងស្នៀត សាងស្នេហ៍នោះវាមិនមែនលំបាកខ្លាំងណាស់នោះទេ គ្រាន់តែព្យាយាមជាស់តឿនចិត្តខ្លួនឯង កុំឲ្យជាមនុស្សស្ងួតអត់ទឹកចិត្តប៉ុណ្ណឹងទៅសមគួរហើយ ។

**ទីឃា ជាគរតោ រត្តិ ទីឃំ សន្តស្ស យោជនំ**

**ទីឃោ ពាលានំ សំសារោ សទ្ធម្មំ អវិជានតំ ។**

យប់យូរសម្រាប់អ្នកដែលដេកមិនលក់ យោជន៍ឆ្ងាយដាច់ស្រយាល សម្រាប់អ្នកដែលស្ពាយកម្លាំងហើយ វដ្ដសង្សារវែងឆ្ងាយ សម្រាប់បុគ្គលពាលទាំងឡាយ ដែលមិនដឹងច្បាស់នូវព្រះសទ្ធម្ម ។

## ៥៥-សេចក្តីប្រកាន់

កូនជាទីស្រឡាញ់

ជីវិតនៃមនុស្សម្នាក់ៗនោះ រមែងជួបប្រទះនូវសេចក្តីក្តៅក្រហាយ ខ្វាយខ្វល់រវល់ក្នុងចិត្តសន្ទឹកសន្ទាប់រាប់ជងមិនអស់ ច្រើនបែបច្រើនយ៉ាង ។ ក្នុងបណ្តាសេចក្តីក្តៅក្រហាយនោះ មានសេចក្តីក្តៅក្រហាយ ព្រោះសេចក្តីប្រកាន់នៃខ្លួនឯងរួមជាមួយផង ។ សេចក្តីប្រកាន់ដែលពោលមកនេះ គឺការដែលមនុស្សយើងទៅចាប់យកមកហួងហែងនូវអ្វីណាមួយ រហូតទាល់តែខ្លាំងហួស ដូចជាចាប់យកនូវមនុស្សទាំងឡាយណារបស់ទាំងឡាយណា ការងារទាំងឡាយណា ឋានៈទាំងឡាយណា ទាំងការចេះដឹង រហូតដល់គំនិតរបស់ខ្លួនជាដើមទាំងអស់នេះ មកហួងហែងប្រកាន់មាំខ្លាំងពេកទៅ គឺនៅក្នុងសេចក្តីប្រកាន់ថាជារបស់យើង ។ សេចក្តីប្រកាន់ដូចនេះឯង ជាហេតុ ជាដើមចមនៃសេចក្តីក្តៅក្រហាយ និងទុក្ខសោកក្រៀមក្រំ ដែលតែងតែមានក្នុងមនុស្សម្នាក់ៗ ។ ប្រកាន់ក្នុងអ្វីណា ក៏នឹងទុក្ខសោកក្តុកក្តួលក្នុងអ្វីនោះ ។ បើមិនប្រកាន់ក្នុងអ្វីណាទេ ក៏នឹងមិនទុក្ខសោក មិនក្តុកក្តួល និងមិនក្តៅក្រហាយក្នុងអ្វីនោះឡើយ ។

បើកូនត្រូវការឲ្យមានជីវិតរស់នៅជាសុខពិតៗ កូនត្រូវព្យាយាមលះលែងក្នុងចិត្តនូវអ្វីៗនោះ ឲ្យថយចុះនូវសេចក្តីប្រកាន់ កូនត្រូវចាំទុកនូវពាក្យនេះគឺ “កុំចង់បានរបស់ដែលអត់ កុំជាប់ចិត្តនឹងរបស់ដែលមាន អ្វីៗសុទ្ធតែកើតពីហេតុ អ្វីៗដែលកើតឡើងហើយ សុទ្ធតែត្រូវប្រែប្រួលទាំងអស់” ។ កូនកុំទៅទូលដុំថ្ម កុំទទួលនូវភារៈអ្វីឲ្យធ្ងន់ហួស ។ ជាធម្មតានៃភារៈដែលរែកទូល វារមែងធ្ងន់រឿយៗ លុះដល់ដាក់ចុះទម្លាក់ចោលបាន វារមែងអស់ធ្ងន់ និងអស់ការនឿយហត់តទៅទៀតដែរ ។

ភារៈដែលចិត្តទទួលរែកពុន ឬប្រកាន់ទុកនេះ វាមិនងាយនឹងដាក់ចុះបានដោយងាយឡើយ ដូច្នេះហើយ ទើបវាធ្វើឲ្យធ្ងន់នៅក្នុងចិត្ត និងក្តៅក្រហាយជានិច្ចកាល។ បើទោះបីថាមានភារៈ ឬទូលរែកនូវភារៈអ្វីទៅនោះដោយ មិនប្រកាន់ចំពោះភារៈនោះខ្លាំងពេកទេ ពេលណាគួរដាក់ក៏ដាក់ ពេលណាគួរទូលរែកក៏ទូលរែកទៅ ធ្វើបានដូចនេះ វាគ្រាន់ធូរទ្រូងខ្លះ អាចមានជីវិតជាសុខតាមសមគួរដែរ ល្អជាងរែកទូលគ្រប់គ្រាគ្រប់ពេលវេលា ។

ចំពោះសេចក្តីប្រកាន់ក្នុងចិត្ត ដែលជាភារៈធ្ងន់ដូចពោលហើយនេះ បើដាក់ចុះបានខ្លះ ក៏នឹងមានសេចក្តីសុខខ្លះ បើដាក់ចុះបានទាំងអស់ក៏នឹងមានសេចក្តីសុខទាំងអស់

នេះជាសច្ចធម៌ណា៎កូនណា៎ ។

## ៥៦-យកឈ្នះគ្នាដោយហេតុផល

កូនជាទីស្រឡាញ់

ការយកឈ្នះគ្នាដោយពាក្យនិយាយ ឬដោយការជជែកប្រកែកនោះ សូម្បីប្រព្រឹត្តទៅដោយហេតុផល ពេលខ្លះក៏មិនអាចធ្វើឲ្យហេតុការណ៍ផ្សេងៗល្អឡើងបាន ដែរអាចធ្វើឲ្យខូចពេល និងរឹតតែធ្វើឲ្យបែកបាក់គ្នាក្រៃលែងឡើងទៀតផង ។ ពាក្យនិយាយដែលមានហេតុផល មិនមែនសុទ្ធតែអាចប្រើបានគ្រប់គ្រា គ្រប់ករណីទៅនោះទេ ដោយចំពោះក្នុងការនៅរួមគ្នាជាគ្រួសារ ឬជាពួកក្រុម ។ ការដែលយល់ត្រូវគ្នា ការបន្ទន់ចិត្តគ្នាទៅវិញទៅ មកនិងការនៅស្ងៀមដោយសេចក្តីអត់ធន់ជាដើម ក៏អាចដោះស្រាយបញ្ហាគ្រួសារឬពួកក្រុមបានដូចគ្នាដែរ សូម្បីមើលទៅហាក់ដូចជាមិនសូវយកហេតុផលមកដោះស្រាយក៏ដោយ ប៉ុន្តែវាជាហេតុផលដែលនាំឲ្យទាំងពីរខាង គឺខ្លួនឯងនិងអ្នកដទៃ ព្រមព្រៀងគ្នា មិនទុកគ្នាជាគូបដិបក, រលាយចូលគ្នាដោយសន្តិវិធី បើយ៉ាងនេះបានយើងមិនចាំបាច់អាងហេតុផលយកមកប្រកែកគ្នា ឬឈ្លោះគ្នានោះឡើយ ។

មានកិរិយាស្វាមីច្រើនគូ ដែលត្រូវបែកផ្លូវគ្នាដើរ ព្រោះម្នាក់ៗសុទ្ធតែអាងហេតុផលរៀងៗខ្លួន សំដៅយកត្រង់ការឈ្នះគ្នា

-

ដោយហេតុផលដែលខ្លួនមាន ដោយប្រកាន់ថា ហេតុផលរបស់ខ្លួនឯងត្រឹមត្រូវ ម្ខាងទៀតមិនមានហេតុផលអ្វីឲ្យត្រឹមត្រូវឡើយម៉្លោះហើយទីបំផុតចុងក្រោយក៏ត្រូវបែកគ្នា ។ ហេតុផលគឺពិតជារបស់ល្អហើយ តែត្រូវប្រើឲ្យសមជាមួយគ្នានឹងករណីនិងពេលវេលាផង ។

ក្នុងពេលនៅរួមគ្នា ឬធ្វើការជាមួយគ្នា មានការឲ្យអភ័យការព្រមស្តាប់គ្នា ការអត់ធន់ ការមិនប្រកាន់ក្នុងរឿងបន្តិចបន្តួចមើលទៅហាក់ដូចជាមិនត្រឹមត្រូវ ឬមិនសមហេតុផលដែលត្រូវឲ្យអភ័យជាដើមសោះ ប៉ុន្តែបើអាចព្រមព្រៀងគ្នាបាន ឬអាចការពារនូវភាពបែកបាក់គ្នាបាន គឺពិតជាល្អជាងការប្រើហេតុផលហើយឈ្លោះទាស់ទែងគ្នា គុំគួនគ្នា ។ ដូចជាការធ្វើដំណើរតាមទីក្រុង ពិតមែនតែភ្លើងចរាចរណ៍បៃតងហើយក៏ដោយ ក៏ត្រូវតែមើលឆ្វេងស្តាំផង ព្រោះវាអាចមានអ្នកប្រញាប់ ឬអ្នកមិនគោរពច្បាប់ចរាចរនោះផងដែរ បើយើងចេះតែប្រកាន់អាងហេតុផលរបស់យើងថាត្រឹមត្រូវ គឺភ្លើងបៃតងវាអាចឲ្យយើងគ្រោះថ្នាក់ដល់ស្លាប់ក៏បាន យ៉ាងណារឿងក្នុង ជីវិតក៏ត្រូវគិតឲ្យយល់យ៉ាងនោះដែរ គឺកុំអាងខ្លួនត្រូវហើយ នាំឲ្យខ្លួនមាននូវគ្រោះថ្នាក់ ឬវិបត្តិបែកបាក់គ្នានោះ ។

-

ក្នុងរឿងសេចក្តីស្រឡាញ់ និងក្នុងការគ្រប់គ្រងផ្ទះ ពេលខ្លះគឺនាំហេតុផលមកជជែកមិនបានឡើយ ព្រោះរឿងរ៉ាវ វានៅពីលើហេតុផលដែលយើងចង់និយាយទៅទៀត ដូច្នេះមានតែការសម្រួលមានតែសម្បទាន និង ការយល់ដឹងអំពីសេចក្តីពិតហើយព្រមទទួលប៉ុណ្ណោះ ទើបវាជាការល្អ ។ បើមានការក្ដៅក្រហាយអ្វី កុំចេះតែមកបន្ទោសគ្នា ប្រកែកគ្នា ត្រូវមានគុណធម៌ប្រចាំចិត្តសម្រាប់ដោះស្រាយបញ្ហាផង ។

-

## ៥៧-សតិនាំ បញ្ញាតាម

កូនជាទីស្រឡាញ់

បើកូនមិនត្រូវការសេចក្តីក្តៅក្រហាយ មិនត្រូវការឲ្យកើតនូវសេចក្តីក្តៅក្រហាយក្នុងការធ្វើ ឬការនិយាយទៅហើយនោះទេ កូនត្រូវគិតឲ្យល្អមុនធ្វើ ឬមុននិយាយនោះឯង ។ ការគិតបានត្រឹមត្រូវមុនធ្វើមុននិយាយ ដើម្បីការពារនូវកំហុសនោះ នេះជាលក្ខណៈរបស់សតិ ។ សតិ គឺជាគុណធម៌មួយយ៉ាង ដែលចាំបាច់បំផុតក្នុងដំណើរជីវិត ។ មនុស្សដែលខ្វះសតិ បើនឹងធ្វើអ្វីនិយាយអ្វីច្រើនតែក្តៅក្រហាយ ឬក៏ភ្លេចនេះភ្លេចនោះ ឬម្យ៉ាងទៀតនឹងនាំមកនូវសេចក្តីវិនាសប្រយោជន៍ ត្រូវខាតពេលដើម្បីដោះស្រាយបញ្ហា ឬត្រូវបាត់បង់នូវរបស់សំខាន់ក្នុងជីវិត ដែលលំបាកនឹងដោះស្រាយបាន ម្ល៉ោះហើយមានតែលំបាកឡើងៗ ។ ការមានសតិទើបជាគ្រឿងការពារនូវសេចក្តីក្តៅក្រហាយ និងសេចក្តីវិនាសដ៏សំខាន់ក្រៃលែង ។

សតិជាគុណជាតិនាំមុខបញ្ញា សតិប្រៀបដូចជា ផាល ឯបញ្ញាប្រៀបដូចជាផ្កៀងនង្គ័ល បញ្ញាចម្រើនទៅបាន ក៏ព្រោះមកអំពីហ្វឹកហាត់អប់រំសតិហ្នឹងឯង ។

-

មនុស្សមានបញ្ញាពីកំណើតមកហើយ ថែមទាំងជាមនុស្សឆ្លាត ព្រោះបានរៀនសូត្រច្រើន ចេះដឹងគ្រប់មុខវិជ្ជា ប៉ុន្តែបើខ្វះសតិ ឬក៏ប្រមាទធ្វេសប្រហែស រមែងគ្រោះថ្នាក់ដូចជាមនុស្សល្ងង់ខ្លៅ អត់ចេះអ្វីសោះអីចឹង ។ ដល់ពេលខុសភ្លាត់ ឬត្រូវក្តៅក្រហាយស្តាយក្រោយមកដល់ ក៏ច្រើនតែគិតថា "បើដឹងដូចនេះអាត្មាអញមិនធ្វើឡើយ" ។ ដូច្នេះមនុស្សយើងគឺមិនត្រូវអាងឆ្លាត ឬអាងថាអញរៀនបានច្រើន ហើយធ្វើអ្វីនិយាយអ្វីមិនគិតមុខមិនគិតក្រោយនោះឡើយ ។ កុំយកឆ្លាតនាំមុខសតិឲ្យសោះ ត្រូវឲ្យមានសតិនាំមុខវិញ ទើបអ្វីៗគ្រប់យ៉ាងរៀបរយ មិនលំបាកដោះស្រាយតាមក្រោយអំពើរបស់ខ្លួនឯង។ សតិនិងបញ្ញា ជាគុណជាតិមានឧបការៈច្រើនក្នុងការងារគ្រប់យ៉ាងគឺត្រូវឲ្យមានជាគូគ្នារហូតតទៅ។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់សម្តែងថា "បើបុគ្គលបានដឹងថាខ្លួនឯងជាទីស្រឡាញ់របស់ខ្លួន គប្បីរក្សាខ្លួនឲ្យជាការរក្សាដ៏ល្អ"។ មនុស្សយើងគ្រប់គ្នាសុទ្ធតែស្រឡាញ់ខ្លួន ប៉ុន្តែបើមិនបានកំណត់ដឹងរបស់ដែលជាទីស្រឡាញ់ គឺខ្លួននោះឲ្យច្បាស់លាស់ទេ ការតាំងចិត្តរក្សារមែងមិនមាន ។ បើការតាំងចិត្តរក្សាខ្លួនមិនមានទេ នេះឈ្មោះថា បុគ្គលមាននូវធម៌ប្រមាទ គឺការធ្វេសប្រហែស ដូច្នេះដំណើរជីវិតពិតជាមិនបានល្អឡើយ ។

តាមពិត មនុស្សគ្រប់គ្នារមែងរស់នៅជាមួយនឹងខ្លួនឯងរហូត តាំងពីកើតដល់ស្លាប់ ស្លាប់ហើយត្រូវបន្តការរស់នៅជាមួយនឹងខ្លួនឯងទៀតជារៀងរហូត ទាល់តែជីវិតត្រូវបានបញ្ចប់ក្នុងសង្សារវដ្ត បើយើងមិនបានរក្សាខ្លួនឲ្យល្អទេ យើងរមែងរស់នៅជាមួយនឹងខ្លួនឯងដែលជាមនុស្សមិនល្អរហូតតទៅ ។

ចូរកូនកុំប្រមាទ កុំធ្វេសប្រហែសឡើយ ចូរកូនហ្វឹកហាត់ឲ្យមានសតិជាប្រចាំក្នុងចិត្ត ដើម្បីកូននឹងមិនបានធ្វើអ្វីខុសឆ្គងដូចជាមានអ្នកយាមចាំចាប់មនុស្សខូចដូច្នោះឯង ។ កូនត្រូវពិចារណាតាមកំណាព្យនេះ :

**ហីនំ ធម្មំ ន សេវេយ្យ** ទំនាស់កាប់ចាក់រំលោភឈ្លានពាន
ល្មើសគុណម៉ែឪទ្រុស្តព្រះទ្រង់ញាណ ទ្រុស្តនៅត្រង់ហ៊ានបំពានសិក្ខា ។
ធម៌ថោកទាំងនេះគឺសែនហីនំ ស៊ីបាយបោកផ្ទាំងខ្នាំងនឹងសាសនា
កូនឪមិនត្រូវសេពគប់ឡើយណា បាលីពោលថា **ន សេវេយ្យ**។
ធម៌ថោកមានច្រើនកើតកើនខ្លាំងណាស់ ទាំងក្មេងទាំងចាស់ប្រព្រឹត្តអាក់
សេពគប់ធម៌ខ្មៅចាញ់អំណាចប្រាក់ ជាប់ខ្នោះប្រវាក់អន្ទាក់កាមគុណ។
**បមាទេន ន សំវសេ** កូនត្រូវរិះរកគិតទុកជាមុន
រៀបចំជីវិតឲ្យផុតទារុណ បុណ្យជាដើមទុនរួចចាកធម៌ថោក។
កូនឪមិនត្រូវរស់ដោយប្រមាទ ត្រូវខំសង្វាតកុំឲ្យចាញ់បោក
តណ្ហាក្នុងចិត្តបង្កើតទុក្ខសោក កូនព្យាយាមក្រោកសម្លឹងធម៌ពិត។
បើកូនមិនក្រោកពិតជាលំបាក បញ្ឆោតស្រោកធាកល្ងោនជីវិត

កំព្រាទីពឹងក្នុងកពងឆឹត មោហរូបរឹតពិតជាវង្វេង ។
ចូរកូនសម្លាញ់ស្តាប់តាមម៉ែពុក កូនកុំជាប់គុកនៅក្នុងបទភ្លេង
ត្រូវចេះស្តាប់ធម៌កុំចេះតែលេង ស្រីស្រាកែវពែងជាល្បែងគ្រោះថ្នាក់។

## ៥៨-ជីវិតមានតម្លៃ

កូនជាទីស្រឡាញ់

កូនដឹងទេថា "ជីវិតមានតម្លៃថ្លៃក្រៃលែង" មិនថាជីវិតរបស់យើងឬរបស់អ្នកដទៃ សុទ្ធតែមានតម្លៃទាំងអស់ គឺមានតម្លៃទាំងដល់ខ្លួនឯង ទាំងដល់អ្នកដទៃ ។ ដូច្នេះហើយ ទើបក្នុងសីល ៥ បានលើកយកការវៀរចាកនូវការសម្លាប់សត្វទុកជាសិក្ខាបទទី ១ ព្រោះមកអំពីជីវិតជារបស់សំខាន់ហ្នឹងឯង ។

មនុស្សយើងសំខាន់សម្រាប់ខ្លួនឯងណាស់ សត្វដទៃ បុគ្គលដទៃ សុទ្ធតែសំខាន់សម្រាប់ខ្លួនគេគ្រប់ៗគ្នា រៀងៗខ្លួន ដូច្នេះទើបមិនគួរសម្លាប់ មិនគួរបៀតបៀនជីវិតគ្នាឡើយ ។

កាលបើកូនដឹងថាជីវិតកូនមានតម្លៃថ្លៃ និងសំខាន់សម្រាប់ខ្លួនកូនហើយ កូនត្រូវរក្សានិងថ្នាក់ថ្នមជីវិតឲ្យល្អ។ កូនត្រូវធ្វើអំពើជាប្រយោជន៍ឲ្យដល់ខ្លួនឯងផង ឲ្យដល់អ្នកដទៃផង ឲ្យច្រើនជាទីបំផុត ។ អំពើអាក្រក់ដែលជាបាបកម្មនាំឲ្យមានពៀរវេរា កូនកុំឲ្យជីវិតនេះទៅប្រឡាក់ប្រឡូសឲ្យសោះ ។

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា ជីវិតដែលមានសីលមានការសម្លឹងពិនិត្យ សូម្បីរស់នៅតែមួយថ្ងៃ ក៏ប្រសើរជាងជីវិតដែលអត់សីល អត់មានការតម្កល់ឲ្យល្អ រស់នៅអស់រយៈឆ្នាំទៅទៀត។

ដើម្បីឲ្យសមនឹងការដែលយើងយកជីវិតដ៏មានតម្លៃបង់ពន្ធឲ្យមច្ចុរាជ ក្នុងមួយថ្ងៃ ២៤ ម៉ោង យើងត្រូវធ្វើការក្នុងមួយថ្ងៃឲ្យបានកម្រៃថ្លៃជាងជីវិត ២៤ ម៉ោងទៅទៀត។ កូនដឹងទេថា ការបំពេញបុណ្យបារមីដើម្បីឲ្យរួចផុតចាកទុក្ខ គឺជាការងារដែលមានតម្លៃជាងជីវិតឆ្ងាយណាស់ ដូច្នេះកូនត្រូវប្រយ័ត្នកុំឲ្យខាតថ្លៃពន្ធឲ្យសោះក្នុងមួយថ្ងៃៗ ។

-

## ៥៩-មនុស្សយើង
## សំខាន់សម្រាប់ខ្លួនឯងណាស់

កូនជាទីស្រឡាញ់

នៅក្នុងលោកនេះ តើអ្វីដែលល្អជាងគេសម្រាប់មនុស្សយើង? គឺខ្លួនយើងជាមនុស្សល្អហ្នឹងឯង ។ បើយើងជាមនុស្សអាក្រក់មានចិត្តបាប ប្រព្រឹត្តទុច្ចរិត អត់គោរពវិន័យ បៀតបៀនអ្នកដទៃ ទោះបីយើងមាននូវដុំពេជ្រ ក្អមមាស និងសម្បត្តិផ្សេងៗទៀតពោរពាសយ៉ាងណាក៏ដោយ ក៏យើងមិនអាចល្អបានដែរ ព្រោះយើងជាមនុស្សអាក្រក់ស្រេចទៅហើយ ។

មនុស្សយើងរមែងស្រឡាញ់ខ្លួនឯង តែងគាំទ្រខ្លួនឯងតម្កល់ខ្លួនឯងក្នុងកន្លែងគ្រាន់បើ ឬកន្លែងខ្ពស់ ប៉ុន្តែនៅក្នុងសភាពបែបនេះ កូនត្រូវប្រយ័ត្នឲ្យណាស់ ចំពោះគំនិតម្យ៉ាងដែលគិតថា "បើយើងមានប្រាក់ច្រើន យើងនឹងគ្រាន់បើ" ។ ព្រោះបើកូនមិនបានប្រយ័ត្នចំពោះគំនិតនេះទេ កូននឹងធ្លាក់ចុះក្នុងទីដ៏ថោកទាបដោយសារការប្រព្រឹត្តនូវទុច្ចរិតក្នុងបំណងរកប្រាក់ ។

កូនត្រូវប្រយ័ត្នចំពោះគំនិតរបស់កូន នៅក្នុងរឿងផ្សេងៗទៀតច្រើនណាស់ ត្រូវប្រយ័ត្នគំនិតចង់សប្បាយ ត្រូវប្រយ័ត្ន

-

ចិត្តស្រឡាញ់ជាដើម ព្រោះថា មនុស្សយើងសំខាន់សម្រាប់ខ្លួនឯងដ៏ក្រៃលែង ។ កូនត្រូវពិចារណានូវកំណាព្យម៉ែឪប្រដៅកូន :

ប្រាប់ឲ្យកូនធ្វើល្អ ស្មៀកពាក់សគឺចិត្តស្មោះ
ប្រដៅឥតមានខ្ចោះ ដូចគេប្រោះយកទឹកថ្លា ។
អប់រំក្រើនរំលឹក ទោះល្ងាចព្រឹកឪទេសនា
ប្រាប់ឲ្យកូនឧស្សាហ៍ ធ្វើកិច្ចការជាកល្យាណ ។
សុចរិតថ្លៃជាងពេជ្រ កុំបំភ្លេចចោលខ្លួនប្រាណ
មនុស្សថ្លៃពន់ប្រមាណ កុំចោលប្រាណដូរយកប្រាក់។
ចោលប្រាណស្មើលក់ខ្លួន ម៉ែពោលជូនឲ្យប្រចក្ស
មនុស្សយើងថ្លៃជាងប្រាក់ ត្រូវទុកដាក់ខ្លួនឲ្យល្អ ។

✍📖✍

-

## ៦០-ខ្លួនជាទីស្រឡាញ់នៃខ្លួនឯង

កូនជាទីស្រឡាញ់

ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ថា "បើបុគ្គលបានដឹងថាខ្លួនឯងជាទីស្រឡាញ់របស់ខ្លួន គប្បីរក្សាខ្លួនឲ្យជាការ រក្សាដ៏ល្អ" ។

ពាក្យថា "ខ្លួន" ក្នុងទីនេះ បានដល់ដំណើរជីវិតរបស់យើង ដំណើរជីវិតគឺជាក្រសែរបស់ចិត្ត ដូច្នេះដែលថារក្សាខ្លួនបានដល់ការរក្សាចិត្តហ្នឹងឯង ។

ពាក្យថា "រក្សាខ្លួន" បានសេចក្តីថា រក្សាចិត្ត ទូន្មានចិត្តគ្រប់គ្រងដំណើរជីវិត អប់រំព្រហ្មចរិយធម៌ ឲ្យមានភាពភ្លឺស្វាងរុងរឿង និងឿនជួបប្រសព្វចំពោះសេចក្តីសុខក្សេមក្សាន្ត ។

ឪពុកម្តាយបានបញ្ជាក់ប្រាប់កូនហើយ ថាកូនត្រូវប្រយ័ត្នចំពោះគំនិតគិតចង់បានសប្បាយ ព្រោះបើមិនបានប្រយ័ត្នចំពោះគំនិតនេះទេ វានឹងនាំឲ្យកូនរកការសប្បាយក្នុងផ្លូវបិសាច ហើយកូនត្រូវប្រយ័ត្នចំពោះចិត្តស្រឡាញ់របស់កូនរៀងរាល់ថ្ងៃទៀតផង ទោះជាស្រឡាញ់អ្វីក៏ដោយ ព្រោះចិត្តស្រឡាញ់នាំឲ្យមានការហួងហែង ការហួងហែងជាមាត់ជ្រោះដ៏រអិល គឺថាវាងាយនឹងធ្វើឲ្យកូនធ្លាក់ចុះទៅ ក្នុងជម្ពោះឈ្មោះទាស់ទែង ពោលនូវពាក្យ

-

*អាក្រក់ ពាក្យកុហក ពាក្យញុះញង់ និងប្រព្រឹត្តការបៀតបៀន ដោយអំពើឃោរឃៅផ្សេងៗណាស់ ។*

*បើកូនដឹងថា ខ្លួនជាទីស្រឡាញ់របស់ខ្លួនកូនពិត ប្រាកដហើយ កូនត្រូវតែប្រយ័ត្នប្រយែងឲ្យណាស់ ចំពោះកិលេសដែលមានក្នុងចិត្តកូនខ្លួនឯង ។ កូនត្រូវពិចារណានូវព្រះពុទ្ធភាសិតមួយបាទនេះ :*

**ចិត្តំ គុត្តំ សុខាវហំ** *ព្យាយាមដេញខ្មាំងពីចិត្តសន្តានគ្រប់គ្រងស្លួនចិត្តដោយកម្មកល្យាណ នាំសុខមកបានក្សេមក្សាន្តពេកក្រៃ។*

-

## ៦១-សុខឬទុក្ខកើតពីគំនិតខ្លួនឯង

*កូនជាទីស្រឡាញ់:*

*មនុស្សដែលមិនមានប្រមាទ រមែងមិនបណ្តែតបណ្តោយសូម្បីតែគំនិត គឺជាអ្នកមាននូវស្មារតីគ្រប់គ្រងគំនិតរបស់ខ្លួនមិនឲ្យភ្លាត់គំនិត ដូចជាការដើរដួលក្នុងផ្លូវអិលឡើយ ។*

*ជាធម្មតាក្នុងជីវិតរាល់ថ្ងៃរមែងមានសុខ មានទុក្ខក្នុងចិត្តទៅតាមគំនិតរបស់ខ្លួន ព្រោះហេតុដូច្នេះហើយ ទើបព្រះសម្មាសម្ពុទ្ធទ្រង់បង្រៀនឲ្យមនុស្សយើងស្វែងរក នូវសេចក្តីសុខតាមផ្លូវចិត្តដោយការប្រយ័ត្ននូវគំនិតខ្លួនឯង ។ បើគ្រប់គ្រងគំនិតមិនបានទេគំនិតហ្នឹងហើយដែល តែងតែបៀតបៀននូវចិត្តខ្លួនឯង នាំមកនូវទុក្ខរឿយៗឲ្យដល់ចិត្តសន្តាន រហូតដល់ហ៊ានប្រព្រឹត្តនូវអំពើឃោរឃៅ។*

*គំនិតប្រៀបដូចជាភ្លើងអុស បើគ្រប់គ្រងបានល្អក៏ជាប្រយោជន៍ តែបើគ្រប់គ្រងមិនបានល្អទេ រមែងឆេះផ្ទះ ឆេះភូមិឆេះស្រុក ដូច្នេះហើយ ទើបបុគ្គលដែលមិនមានប្រមាទ រមែងប្រយ័ត្ននូវគំនិតនេះណាស់ ឯផលកម្រៃដែលត្រូវបាន គឺសេចក្តីសុខស្ងប់ច្រើនៗ ។*

-

*សូមកូនខំប្រឹងស្វែងរកនូវសេចក្តីសុខអំពីគំនិត របស់ខ្លួនឯង ។ កូនគប្បីកំណត់ដឹងថារឿងរ៉ាវទាំងឡាយ ដែលមកដល់ជីវិតនេះ មិនមែននាំមកនូវសុខ ឬទុក្ខចូលដល់សន្តានចិត្តតែម្តងនោះទេ គឺវាអាស្រ័យនៅលើគំនិតឆ្លាត ឬល្ងង់របស់ខ្លួន ដែលជាអង្គប្រកបខាងក្នុង សម្រេចឲ្យសុខ ឬទុក្ខក្នុងចិត្តកើតឡើង ។*

*ក្រោកព្រឹកឡើង កូនត្រូវប្រាថ្នាសច្ចាក្នុងចិត្តថា នឹងធ្វើល្អ និយាយល្អ គិតល្អឲ្យបានប្រសើរជាងពីថ្ងៃមុន។*

✎📖✍

-

## ៦២-ធានិងមាន់

*កូនជាទីស្រឡាញ់*

*មានមនុស្សពីរនាក់ឃើញទាផង ឃើញមាន់ផង ។ មនុស្សម្នាក់គិតចង់ឲ្យមាន់ក្លាយទៅជាទា គិតចង់ឲ្យទាក្លាយជាមាន់ រឿងនេះវាមិនអាចប្រព្រឹត្តទៅបានឡើយ ក្នុងមួយអត្តភាពនៃសត្វទាំងពីរមុខនោះ ។ បើមនុស្សនោះ គិតយ៉ាងនេះមិនឈប់ទេ គឺត្រូវតែកើតទុក្ខជាប្រាកដ ។*

*មនុស្សម្នាក់ទៀតឃើញទាជាទា ឃើញមាន់ជាមាន់ មិនមានចង់ឲ្យក្លាយទៅជាអ្វីផ្សេងឡើយ នោះឯងហើយដែលមិនមានបញ្ហា យ៉ាងណាមិញ* **អនិច្ចំ** *គឺការមិនទៀង បើយើងចង់ឲ្យវាទៀង លទ្ធផលគឺការខូចចិត្ត តែបើយើងឃើញថា សង្ខារទាំងឡាយជារបស់មិនទៀងយ៉ាងនោះ យើងរមែងមានចិត្តស្ងប់ មិនមានបញ្ហា មិនមានការខូចចិត្តឡើយក៏យ៉ាងនោះឯង ។*

*មនុស្សយើងតែងតែទាស់ចិត្តចំពោះសេចក្តីពិត ដែលមិនត្រូវនឹងអធ្យាស្រ័យរបស់ខ្លួន ប្រាថ្នាដើរចេញពីសេចក្តីពិតដូចនេះ។ម្យ៉ាងទៀតសេចក្តីប្រាថ្នាចង់បានរបស់ដទៃ ឬចង់ឲ្យរបស់នេះទៅជាយ៉ាងនោះទាំងអស់នេះ រមែងនាំមកនូវការមិនស្ងប់ក្នុងចិត្ត ។*

*ទាគង់តែជាទា មិនក្លាយជាសត្វដទៃ*

-

ចង់ខុសកើតទុក្ខភ័យ ល្អប្រពៃន័យត្រង់ពិត ។
ចំណង់ឲ្យសមហេតុ ច្បាស់ក្រឡែតរឿងជីវិត
កុំចង់កែការពិត អប់រំចិត្តពិតបានសុខ ។

## ៦៣-ទឹកហូរគ្មានត្រឡប់

កូនជាទីស្រឡាញ់

ទឹកធ្លាក់ចាកភ្នំហូរតាមជ្រោះ ទឹកជ្រោះហូរចូលស្ទឹង ទឹកស្ទឹងហូរចូលទន្លេ ទឹកទន្លេហូរចូលសមុទ្រ មិនហូរត្រឡប់មកវិញឡើយ ។

ប្រសិនបើមានបុរសម្នាក់ទៅឈរនៅមាត់ទន្លេ ហើយសម្លឹង មើលក្រសែទឹកដែលហូរទៅក្រោម ដោយចង់ឲ្យទឹកនោះហូរបញ្ច្រាសឡើងលើ បុរសនោះរមែង មានទុក្ខព្រោះមិនបានសម្រេចតាមប្រាថ្នា ។

បុរសនោះមិនមាននូវសេចក្តីស្ងប់ឡើយ ទោះជាឈរក្តី ដើរក្តី អង្គុយក្តី ដេកក្តី ព្រោះអ្វី ? ព្រោះបុរសនោះគិតខុស យ៉ាងណាមិញ សភាវៈធម្មជាតិធម្មតា គ្រប់យ៉ាងរមែងប្រព្រឹត្តទៅដោយ អនិច្ចំ ទុក្ខំ អនត្តា ។ អ្នកណាមកគិតរារាំងនូវច្បាប់ធម្មជាតិនេះ ឬមិនព្រមតាមក៏ដោយ អ្នកនោះរមែងសោយសោកខ្សឹកខ្សួល កន្ទក់កន្ទេញជាប្រាកដក៏យ៉ាងនោះដែរ ។

ផ្ទុយមកវិញ អ្នកដែលមានសតិ មានបញ្ញា ដឹងទាន់ដឹងច្បាស់ប្រាកដនូវច្បាប់ធម្មជាតិបែបនេះហើយ ក៏រមែងសប្បាយចិត្ត រីករាយដោយធម្មបីតិបានកម្រៃអំពីជីវិតដ៏ថ្លៃថ្លា ។

ពពករសាត់បាត់ឆ្ងាយទៅ　　សង្ខារមិននៅទៅតាមថ្ងៃ
ទឹកធ្លាក់ចាកភ្នំពុំអាល័យ　　ជីវិតសែនថ្ងៃចាកជីវី ។
ទឹកហូរធ្លាក់ពិតឥតត្រឡប់　　ទោះធ្លាប់ដក់ទើរលើគិរី
យសខ្ពស់ញាតិរស់ជុំមូលមីរ　　ចាកទីចុះទាសវិនាសព្រាត់។
ព្រៃធំមានម្រឹគទឹកមានត្រី　　វេហាស៍បក្សីហិចហើរស្ទាត់
លោកធម៌ប្រាំបីអ្វីទៀងទាត់　　ត្រៃលក្ខណ៍ប្រាកដជ្រែកសង្ខារ។

## ៦៤-ឆ្អែតកើតរមាស់អង្គែស៊ី

កូនជាទីស្រឡាញ់

ឆ្អែតកើតរមាស់អង្គែស៊ី　　ជ្រះរោមអស់ក្នុងរដូវត្រជាក់ វារមែងជាទុក្ខ ទោះជានៅទីណាៗក៏មិនសុខមិនស្រួលឡើយ ។ ដែលវាមិនសុខមិនស្រួលនោះ មិនមែនមកអំពីទីដេកទីនៅនោះៗទេ គឺពិតជាមកអំពីរោគនៅនឹងខ្លួនរបស់វានោះឯង ។

មនុស្សទាំងឡាយក៏ដូចគ្នា ដែលមិនសប្បាយចេះតែក្តៅក្រហាយក្នុងចិត្ត មកអំពីចិត្តត្រូវទោសប្រទូស្ត ។ ចិត្តត្រូវទោសប្រទូស្ត ព្រោះមកអំពីប្រកាន់ធម៌ដែលមានពិសទុកមិនព្រមលែងមិនសង្រួមឥន្ទ្រិយ ហើយចេះតែបន្ទោសមនុស្សដទៃ និងអ្វីៗទៀតជាខាងក្រៅ ។ មិនដឹងរឿងរបស់ខ្លួនឯង ទៅណាក៏មិនត្រូវនឹងគេ នៅឯណាក៏មិនសុខ នេះព្រោះតែចិត្តខ្លួនឯងកើតស្រែងអង្គែស៊ី មិនមែនមកអំពីមនុស្សដទៃនិងកន្លែងខាងក្រៅនោះទេ ។

កូនត្រូវយល់ថា “ ហេតុកើតត្រង់ណា ផលកើតត្រង់នោះ” ដូច្នេះការក្តៅក្រហាយចិត្តព្រោះមានរោគក្នុងចិត្ត កូនត្រូវហ្វឹកហាត់កម្ចាត់ហេតុឲ្យត្រូវចំកុំឲ្យខុស ដូចពាក្យចាស់ពោលថា “ អេះឲ្យត្រូវកន្លែងដែលរមាស់ កន្លែងដែលមិនមានរមាស់កុំទៅអេះ” ។

ឆ្អែតកើតអង្គែគ្មានទេរោម　　រមាស់ស្គាំងស្គមព្រមត្រជាក់

លំបាកខ្លួនខ្លាំងតាំងញ័រញ្ញាក់　រត់បោលទទ្រាក់ធ្លាក់ដល់ភ័យ។
ទៅកាន់ទីណាក៏ស្ទាញស្ទុក　ទីនោះមិនសុខស្រុកឬព្រៃ
ទោះដេកទោះដើរដំណើរក្ស័យ　ឧបសគ្គចង្រៃអាស្រ័យខ្លួន ។
ដូចមនុស្សក្នុងលោករោគក្នុងចិត្ត ក្តៅផ្សាពេកពិតត្បិតគុំកួន
រក្សាពិសក្តៅនៅក្នុងខ្លួន　ប្រកាន់មាំមួនខ្លួនឥតសុខ ។
ហេតុកើតត្រង់ណាផលត្រង់ហ្នឹង បើបានជាដឹងប្រឹងសម្រុក
កម្ចាត់ពិសក្តៅទើបនៅសុខ　ទោះស្រុកឬព្រៃគ្មានអ្វីទាស់។

## ៦៥-ក្បាលពស់កន្ទុយពស់

កូនជាទីស្រឡាញ់

មនុស្សយើងគ្រប់គ្នាមិនត្រូវការទុក្ខ ត្រូវការតែសុខប៉ុណ្ណោះ ប៉ុន្តែព្រោះសត្វលោកត្រូវការសុខជាប់ជំពាក់ នឹងសុខទើបមិនរួចពីទុក, ។

សុខនិងទុក្ខប្រៀបដូចសត្វពស់មួយខាងក្បាលវា មានពិសចូលទៅជិតវានឹងខាំ បើចាប់កន្ទុយវាពិតជាស្រួលដែលណាស់ តែបើមិនប្រញាប់លែងទេ វានឹងបែរក្បាលមកខាំបានដូចគ្នា ព្រោះទាំងក្បាលទាំងកន្ទុយវានៅក្នុងតួពស់តែមួយជាមួយគ្នា ។

សេចក្តីទុក្ខដូចជាក្បាលពស់ ឯសេចក្តីសុខដូចជាកន្ទុយពស់ ។ សប្បាយចិត្តជាសុខ ថ្នាំងថ្នាក់ចិត្តជាទុក្ខ រមែងកើតអំពីម៉ែឪជាមួយគ្នា គឺអវិជ្ជានិងតណ្ហានោះឯង។ ដូច្នេះហើយបានជាពេលខ្លះមាននូវសេចក្តីសុខហើយ ចិត្តក៏នៅមិនសប្បាយមិនស្ងប់ ទាំងដែលបាននូវរបស់ដែលពេញចិត្តផង ដូចជាបានលាភបានយសជាដើម ។ បានមកហើយសប្បាយចិត្តក៏ពិតមែន តែវាក៏នៅមិនស្ងប់ពិតៗ ព្រោះនៅភ័យខ្លាចពីការបាត់បង់ ។ ការភ័យខ្លាចជាមូលហេតុមិនឲ្យមាននូវសេចក្តីស្ងប់ ។ ពេលខ្លះត្រូវវិនាសទៅពិតៗ ក៏រឹងរឹតតែជាទុក្ខក្រៃលែង ។ នេះសម្តែងឲ្យឃើញថាសុខ

ពិតមែនតែមានទុក្ខប្រឡូកប្រឡំជាមួយផង ហៅថាសាមិសសុខ គឺជាសុខដូចចាប់ពស់ត្រង់កន្ទុយ ឬដូចត្រីចាប់នុយនឹងផ្លែសន្ទូច ។

ក្បាលពស់ខាំផាប់ជាប់នយទុក្ខ កន្ទុយសមសុខស្រណុកចាប់
តែបើមិនលែងរមែងស្លាប់ ការចាប់ញ៉ាំងលោកឲ្យសោកា។
សប្បាយហើយទុក្ខសុខហើយសោក នេះហើយរាគរោគឫសតណ្ហា
ស្រឡាញ់ហើយឈ្លោះព្រោះកាមា អស់ទុក្ខលុះត្រាតណ្ហាក្ស័យ ។

✎📖✍

-

## ៦៦-មច្ចុរាជ-ម្ចាស់មាន់-មាន់

កូនជាទីស្រឡាញ់

សត្វមាន់រស់ដោយមិនដឹងរឿង ពេលព្រលប់រកកន្លែងដេក ព្រឹកឡើងក៏កាយដីរកស៊ីទៀត ។ ម្ចាស់មាន់បាចស្រូវឲ្យស៊ីរាល់ថ្ងៃ វាក៏មិនដឹងថាគេចិញ្ចឹមវាទុកដើម្បីអ្វីដែរ ។ មាន់ជាមួយនឹងម្ចាស់មានការគិតម្យ៉ាងម្នាក់ ។

ម្ចាស់មាន់ចេះតែគិតថា មាន់ធំហើយ ជិតល្មមប្ដឹងគីឡូហើយ ឯមាន់វិញសប្បាយនឹងចំណី តែងគិតរាល់ថ្ងៃថា ម្ចាស់ស្រឡាញ់ខ្លួន ។

មនុស្សយើងក៏មានការមិនដឹងរឿងផងដែរ មកពីណា? នឹងនៅតទៅទៀតប៉ុន្មានថ្ងៃ-ខែ-ឆ្នាំ? នឹងទៅទីណា? ហើយអ្នកណាជាអ្នកនាំទៅ? គឺមិនដឹង ។

មច្ចុរាជ គឺសេចក្ដីស្លាប់នោះឯង ដូចជាម្ចាស់មាន់អ៊ីចឹង ។ មច្ចុរាជនឹងតាមមកដល់ពេលណាគឺខ្លួនមិនដឹងឡើយ ព្រោះរវល់តែភ្លើតភ្លើនជាមួយនឹងនុយរបស់មច្ចុរាជ គឺរូប សំឡេង ក្លិន រស និងផោដ្ឋព្វៈប្រៀបដូចទឹកជំនន់ធំ បាននាំយកអ្នកដែលដេកលក់នៅមាត់ទឹកនោះទៅដូច្នោះឯង ។

មាន់គិតម្យ៉ាង ស្រោងរកស៊ី ទីជិតៗ

-

ឯម្ចាស់ពិត        គិតគីឡូ          ដូរយកលុយ
មាន់និងម្ចាស់    ច្បាស់មិនដឹង   ប្រឹងស៊ីនុយ
ស្លាប់ព្រោះលុយ នុយនុយនុយ  មច្ចុរាជ ។

## ៦៧-បន្លា

កូនជាទីស្រឡាញ់

សភាវៈទាំងឡាយទាំងពួង គឺជាសភាវៈដែលកើតមានជាធម្មតា មិនបានឲ្យទុក្ខដល់អ្នកណាៗឡើយ។ ប្រៀបដូចជាបន្លាដែលធម្មតាវាតែងស្រួច តើបន្លាឲ្យទុក្ខដល់យើងដែរទេ? អត់ទេ ។ បន្លាមិនបានឲ្យទុក្ខដល់អ្នកណាឡើយ បើយើងមិនទៅជាន់វាទេនោះ តែបើយើងជាន់ឲ្យបន្លាមុត ក៏ជាទុក្ខឈឺចុកចាប់ភ្លាមដោយពិត ។

ដូចម្តេចបានជាទុក្ខ? ព្រោះជាន់វា យ៉ាងណាមិញ សង្ខារទុក្ខ ឬឧបាទានក្ខន្ធទុក្ខ គឺជាទុក្ខពិតតាមសភាវៈ ជា ទុក្ខសច្ចៈ ដូចបន្លាអ៊ីចឹង បើយើងមិនជាន់ឲ្យបន្លាមុត ពោលគឺមិនប្រកាន់ទេ ទុក្ខក៏មិនកើតមានដល់ចិត្តដែរយ៉ាងនោះឯង ។

ព្រះធម៌ដូចជាស្បែកជើង សម្រាប់រក្សាយើងមិនឲ្យមានទុក្ខតាមផ្លូវចិត្ត ។ ដើរក្នុងព្រៃបន្លាត្រូវពាក់ស្បែកជើងយ៉ាងណា ដើរក្នុងវដ្តសង្សារត្រូវមានព្រះធម៌ ក៏យ៉ាងនោះដែរ ។

បន្លាស្រួចពិតឥតខុសអ្វីឡើយ ប្រមាទហ្នឹងហើយទើបជើងមុតជាក់
រូបសំឡេងក្លិនរសផោដ្ឋព្វៈ គឺជាអន្ទាក់បន្លាលោកីយ៍ ។
កូនកុំប្រទូស្តទាស់នឹងបន្លា ស្បែកជើងនេះណាការពារដើរព្រៃ
ដំណើរជីវិតពិតជាមានភ័យ សំវរមានន័យបីដូចស្បែកជើង ។

## ៦៨-ឆ្មា

កូនជាទីស្រឡាញ់

កិលេសដូចជាសត្វឆ្មា បើឲ្យស៊ីតាមចិត្ត វារឹតតែមករឿយៗ រួចហើយ បើថ្ងៃណាមួយយើងមិនបានឲ្យវាស៊ី ឬមិនចាប់ដាក់ឲ្យទេនោះវានឹងយំរំខាន វាខ្វាចវាក្រចៅ ដោយក្រចកជាពិតប្រាកដ ។ បើយើងពិតជាមិនដាក់ឲ្យវា ស៊ីមែន ១ ថ្ងៃ ឬ ២ ថ្ងៃប៉ុណ្ណោះ ក៏បាត់វាទៅយ៉ាងណា កិលេសក៏យ៉ាងនោះដែរ ។ កាលកិលេសមិនមករំខានយើងទេ យើងនឹងបានស្ងប់ចិត្តពិតជាប្រសើរណាស់ ។

កិលេសស្មោកគ្រោកគ្រឿងសៅហ្មង ក្តៅក្រៃកន្លងចំណងមារ
ព្រោះឲ្យចំណីធីគ្រប់គ្រា　　វារឹតទាមទារមារក្នុងចិត្ត ។
បង្អត់អាហារឆ្មាកិលេស　　កុំទាល់ចំណោះចេះអាណិត
កិលេសធាត់ធំពុំល្អពិត　　គំនិតល្អល្អិតគិតកាន់សីល ។
សង្រួមវាចារក្សាចិត្ត　　សង្រួមផ្ទៃពិតកម្ចាត់ខ្ជិល
សង្រួមឥន្ទ្រីយ៍ញាំញីខិល　　សង្រួមក្នុងសីលសុទ្ធាជីព ។

## ៦៩-ល្អផ្សេងគ្នា

កូនជាទីស្រឡាញ់

ទ្រព្យរបស់អ្នកដទៃ មិនល្អដូចទ្រព្យរបស់ខ្លួនឯង ។ ទ្រព្យរបស់ខ្លួនឯងដែលបានទទួលពីអ្នកស្លាប់ទៅ ពោលគឺទ្រព្យមរតក មិនល្អដូចទ្រព្យដែលរកបានមកដោយកម្លាំងខ្លួនឯង ។ ទ្រព្យដែលរកបានមកដោយទុច្ចរិត មិនល្អដូចទ្រព្យដែលរកបានមកដោយសុចរិត ។ ទ្រព្យខាងក្រៅខ្លួន ដែលជារូបធម៌ មិនល្អដូចរូបធម៌ខាងក្នុងខ្លួន ។ ទ្រព្យដែលជារូបធម៌ខាងក្នុងខ្លួន មិនល្អដូចនាមធម៌ដែលមានក្នុងខ្លួន ពោលគឺសេចក្តីល្អនោះឡើយ ។

កូនជាទីស្រឡាញ់ កូនចូរព្យាយាមស្វែងរកវិជ្ជា រកការចេះដឹង ។ កូនត្រូវសាងសមត្ថភាព ត្រូវចេះស្រឡាញ់សេចក្តីល្អ ។ ទាំងអស់នេះជាមង្គលដ៏ឧត្តម ជាអរិយទ្រព្យ ជាទ្រព្យក្នុងខ្លួនដែលមានតម្លៃដ៏ក្រៃលែង ។

✍📖✍

## ៧០-ធ្វើបុណ្យយកមុខ

កូនជាទីស្រឡាញ់

មានមុខលាបម្សៅ ពិតជាល្អជាងការដែលមិនមានមុខ មិនមានក្បាល ។ មនុស្សចេះមានការខ្មាសអៀន ចេះស្គាល់ខ្លួនឯង ចេះស្គាល់ក្បាល ចេះស្គាល់មុខមាត់ ចេះដឹងស្លៀកពាក់បិទបាំង គ្រឿងបដិកូល ចេះធ្វើបុណ្យប្លម យកឈ្មោះ យកមុខ គង់បាន បុណ្យដែរ ហើយល្អជាង មិនធ្វើដោយពិត ។ ប៉ុន្តែបើតាំងចេតនា ធ្វើល្អដោយកាយ វាចាចិត្ត ឲ្យជាបុណ្យកុសល ជាមង្គលទុក ក្នុងខ្លួន គឺល្អក្រៃលែង ។

ធ្វើល្អយកមុខ ល្អជាងធ្វើអាក្រក់ ប៉ុន្តែបានតែមុខហ្នឹងឯង។ ឯការធ្វើអាក្រក់វាខូចទាំងមុខ ខូចទាំងខ្លួន ខូចទាំងចិត្ត ខូចទាំង អនាគត និងខូចអ្វីៗគ្រប់យ៉ាងទៀតទាំងអស់ ។

-

## ៧១-ទាន

កូនជាទីស្រឡាញ់

កូនត្រូវសិក្សានូវចំណុចនៃទានទាំង ១០ នេះគឺ

១-ឲ្យទានមិនត្រូវសង្ឃឹមផល អ្នកទទួលមិនគួរភ្លេច ។

២-បើមិនធ្វើល្អទេរស់នៅ ១០០ ឆ្នាំក៏ពុំមានប្រយោជន៍ដែរ។

៣-បើឃើញតែពីបានទេ កុំសង្ឃឹមទឹកចិត្តអ្នកដទៃ ។

៤-កុំទុកចិត្តមនុស្សដែលគិតតែពីប្រយោជន៍ខ្លួនឯង ។

៥-មនុស្សត្រូវតែចេះឲ្យទាន បើមិនច្រើនក៏តិចដែរ ។

៦-មនុស្សល្អ រមែងពេញចិត្តជួយឲ្យគេបានសុខ ។

៧-ឲ្យទាន រមែងបានមិត្ត និងកម្ចាត់គំនុំក្នុងចិត្ត ។

៨-ឲ្យទាន ដូចជាការនាំទ្រព្យចេញពីផ្ទះដែលត្រូវភ្លើងឆេះ។

៩-ទានគឺជាស្បៀងក្នុងដំណើរផ្លូវទៅកាន់ព្រះនិព្វាន ។

១០-ចេះឲ្យទានហើយ មិនគួរបៀតបៀនសត្វទេ ។

-

## ៧២-សីល

កូនជាទីស្រឡាញ់

កូនត្រូវសិក្សានូវចំណុចនៃសីលទាំង ៩ នេះគឺ

១-សីលធម៌មិនវិនាសទេ មនុស្សទេតើដែលវិនាសពី សីលធម៌។

២-កំហុសចាត់ជាគ្រូក៏ពិត តែសូមកុំឲ្យខុសដដែលៗ ។

៣-សេចក្តីល្អមានតម្លៃជាងបរិញ្ញាបត្រ ។

៤-គុណធម៌មិននៅនឹងអណ្តាតទេ គឺឋិតនៅតែក្នុងចិត្ត។

៥-កុំខ្ជិលសាងគុណធម៌ ព្រោះគ្មានអ្នកណាល្អជំនួសគ្នាទេ។

៦-គុណធម៌មានប្រយ័ត្នជាមាតា មានការអត់ធន់ជាបិតា ។

៧-មនុស្សល្អមិនស្វែងរកសុខ លើទុក្ខនៃអ្នកដទៃឡើយ។

៨-គំនុំគុំកួនជាដំបៅនៃចិត្ត និងជាគ្រោះកាចក្នុងជីវិត ។

៩-ក្រោធខឹងគឺជាភ្លើងដុតចិត្ត មេត្តាជាទឹកដ៏ត្រជាក់ ។

## ៧៣-ភាវនា

កូនជាទីស្រឡាញ់

កូនត្រូវសិក្សានូវចំណុចនៃភាវនាទាំង ៨ នេះគឺ

១-បាបកើតពីអារម្មណ៍ណា គប្បីធ្វើចិត្តឲ្យឃ្លាតចាកពី អារម្មណ៍ នោះ ។

២-ចូរត្រេកអរក្នុងការមិនធ្វេសប្រហែស ត្រូវតាមរក្សាចិត្ត របស់ខ្លួន ។

៣-ពន្លឺភ្លឺស្វាងស្មើដោយបញ្ញាមិនមានឡើយ ។

៤-បញ្ញានាំឲ្យបានដឹងនូវគុណតម្លៃនៃអប្បមាទធម៌ ។

៥-ឈើខ្លឹមគ្រប់ដើមមិនមែនបានធំក្នុងពេលត្រឹមតែ១ឆ្នាំ នោះទេ។

៦-ព្យាយាមនិងអំណត់ ជាគ្រូបង្ហាត់ដ៏ធំក្នុងលោក ។

៧-ជីវិតគឺការដើរផ្លូវឆ្ងាយ រូបរាងកាយជាសាលាសំណាក់។

៨-ពេលវេលាទំពាស៊ីអស់សព្វសត្វព្រមទាំងខ្លួនរបស់វា។

### ៧៤-ការគោរពឱនលំទោន

កូនជាទីស្រឡាញ់

កូនត្រូវសិក្សានូវចំណុចនៃការគោរពឱនលំទោនទាំង ៧ នេះគឺ

១-មនុស្សត្រូវមានកិរិយាសុភាព ដូចផ្កាឈើដែលមានក្លិនក្រអូប ។

២-មារយាទទន់ភ្លន់ជាមិត្តនឹងគុណធម៌ ដែលមិនបែកគ្នាឡើយ ។

៣-មនុស្សល្អរមែងសាងគុណធម៌ ព្រមឲ្យអ្នកដទៃល្អជាងខ្លួន។

៤-អ្នកដែលស្គាល់ខ្លួនឯងដោយល្អ រមែងមិនលើកតម្កើងខ្លួនឡើយ ។

៥-ត្រូវចេះគោរពខ្លួនឯង ទើបអ្នកដទៃគេគោរពកោតខ្លាច ។

៦-កតញ្ញូតាធម៌ជារស្មីចាំងចែងចេញពីចិត្តខ្ពស់ចិត្តប្រសើរ។

៧-កតញ្ញូតាធម៌របស់កូន គឺជាសេចក្ដីសុខរបស់ម៉ែឪ ។

-

### ៧៥-ការជួយខ្នះខ្នែងក្នុងការងារ

កូនជាទីស្រឡាញ់

កូនត្រូវសិក្សានូវចំណុចនៃការជួយខ្នះខ្នែងក្នុងការងារទាំង ៦ នេះគឺ

១-សេចក្ដីខ្ជិលច្រអូសជាព្រៃស្មសានកប់មនុស្សទាំងរស់។

២-គ្រែដេកគឺជាគុករបស់មនុស្សកម្ជិល ។

៣-ការខ្ជិលនិងការក្រលំបាកជាមិត្តជិតដិតនឹងគ្នា ។

៤-មនុស្សយើងរួចពីនរកមក មិនមែនមកដេកខ្ជិលនោះទេ។

៥-ជីវិតនេះត្រូវបង់ពន្ធឲ្យមច្ចុរាជរាល់ថ្ងៃ ។

៦-ត្រូវធ្វើការយកប្រយោជន៍ដែលមានតម្លៃជាងជីវិត ។

-

## ៧៦-ការជូនបុណ្យ

កូនជាទីស្រឡាញ់

កូនត្រូវសិក្សានូវចំណុចនៃការជូនបុណ្យទាំង ៥ នេះគឺ

១-ជូនបុណ្យឧទ្ទិសបុណ្យ គឺជាទានម្យ៉ាងដ៏សំខាន់ ។

២-ជូនបុណ្យសម្រេចដោយទឹកចិត្តមេត្តាព្រមដោយការយល់ដឹង

៣-ត្រូវនឹកប្រាថ្នាឲ្យសព្វសត្វបានប្រយោជន៍សុខពិតៗ ។

៤-ត្រូវនឹកប្រាថ្នាឲ្យសព្វសត្វបានផុតចាកពីទុក្ខលំបាក ។

៥-កុំបង្អួតខ្លួនឯង ត្រូវប្រាថ្នាឲ្យគេត្រេកអរទទួលបុណ្យ។

-

## ៧៧-ការទទួលបុណ្យ

កូនជាទីស្រឡាញ់

កូនត្រូវសិក្សានូវចំណុចនៃការទទួលបុណ្យទាំង ៤ នេះគឺ

១-អនុមោទនាត្រេកអរជ្រះថ្លានឹងកុសលគឺជាបុណ្យ ។

២-បុណ្យដែលទទួលបាន អាចលាងជម្រះបាបក្នុងចិត្តបាន ។

៣-មានបុណ្យចូលទៅនៅក្នុងចិត្ត ប្រសើរជាងទេវតាសណ្ឋិតក្នុងខ្លួន ។

៤-អនុមោទនាទទួលបុណ្យបាន ព្រោះមិនមានមានះនិងការស្អប់ខ្ពើម ។

-

## ៧៨-ធម្មទាន

កូនជាទីស្រឡាញ់

កូនត្រូវសិក្សានូវចំណុចនៃធម្មទានទាំង ៣ នេះគឺ

១-ថ្ងៃ ១៥ កើតខែអាសាធ បន្ទាប់ពីការត្រាស់ដឹងនៃព្រះសម្មាសម្ពុទ្ធបានពីរខែ គឺជាថ្ងៃកំណើតរបស់ព្រះធម៌ទេសនា ។

២-ការសម្ដែងនូវព្រះធម៌ ជាការងារសំខាន់បំផុតរបស់ព្រះសម្មាសម្ពុទ្ធគ្រប់ព្រះអង្គ ។

៣-ធម្មទានឈ្នះអស់ទានទាំងពួង ។

-

## ៧៩-ការស្ដាប់ធម៌

កូនជាទីស្រឡាញ់

កូនត្រូវសិក្សានូវចំណុចនៃការស្ដាប់ធម៌ទាំង ២ នេះគឺ

១-ព្រះពុទ្ធដីកានៅក្នុងព្រះត្រៃបិដក បើបានអានដូចបានគាល់ពះសម្មាសម្ពុទ្ធផ្ទាល់ព្រះអង្គ ។

២-ត្រូវតែមានពេលសម្រាប់ទទួលយកព្រះពុទ្ធវាទ ក្នុងមួយថ្ងៃៗកុំខានឲ្យសោះ ។

-

## ៨០-ការយល់ត្រូវ

*កូនជាទីស្រឡាញ់*

*កូនត្រូវសិក្សាថា អ្វីៗទាំងអស់សុទ្ធតែកើតអំពីហេតុ ដូច្នេះ ហេតុផលជាចំណុចនៃការយល់ត្រូវ ។*

✍🕮✍

c b;

-